សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច
Universite Royale de Droit et des Sciences Economiques
Royal university of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

ស្រាវជ្រាវចាប់ពីថ្ងៃទី០៨ ខែមេសា ឆ្នាំ២០២៤ ដល់ថ្ងៃទី១០ ខែសីហា ឆ្នាំ២០២៤

ស្រាវជ្រាវដោយ
និស្សិតឈ្មោះ កញ្ញា **ឈឹម ឈិនា**
លោក **ភាព វាសនា**

ណែនាំដោយ
សាស្ត្រាចារ្យ **ឡឿក ពិដោរ**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី **២៤**

ឆ្នាំចូលសិក្សា ២០២០
ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំទាំងពីរនាក់ឈ្មោះ **ឈឹម ឈិនា** និង **គាត ទាសនា** ជានិស្សិតថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ឆ្នាំសិក្សា ២០២០ - ២០២៤ ជំនាន់ទី២៤។

**យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ**

**លោកឪពុក** និង **អ្នកម្តាយ** ជាទីគោរព ដែលលោកទាំងពីរមាននូវមហាឧបការគុណដ៏ឧត្តុង្គឧត្តម និងធំធេងបំផុត គ្មានអ្វីប្រៀបផ្ទឹម និងមិនអាចបំភ្លេចបានឡើយ ព្រោះលោកទាំងពីរជាអ្នកមានគុណបានផ្តល់នូវកំណើតចិញ្ចឹមបីបាច់ថែរក្សា ផ្តល់ភាពកក់ក្តៅដល់រូបកូន ព្រមទាំងទំនុកបម្រុងសព្វសារពើទាំងអស់ឱ្យកូន ចាប់តាំងពីថ្ងៃដែលកូននៅក្នុងផ្ទៃម្តាយរហូតដល់ពេញវ័យ។ មិនត្រឹមតែប៉ុណ្ណោះនោះទេ លោកអ្នកមានគុណទាំងពីរបានអប់រំ ណែនាំ ទូន្មានប្រៀនប្រដៅកូនឱ្យចេះដឹងល្អខុសត្រូវធ្វើជាមនុស្សល្អនៅក្នុងសង្គម ដែលពោរពេញទៅដោយចិត្តមេត្តា សណ្តោះប្រណីដល់រូបកូនទាំងពីរ ព្រមទាំងលោកទាំងពីរបានជំរុញទឹកចិត្តឱ្យកូនខិតខំប្រឹងប្រែងសិក្សារៀនសូត្រ ដោយបានបញ្ជូនកូនទៅរៀននៅសាលារៀន ព្រមទាំងឧបត្ថម្ភកូន គ្រប់បែបយ៉ាង ទាំងកម្លាំងកាយ កម្លាំងចិត្ត និងសម្ភារះរហូតដល់កូនបានបញ្ចប់ការសិក្សានេះដោយទទួលបានជោគជ័យ។ សូមជូនពរលោកទាំងពីរ ដែលជាអ្នកមានគុណ មានសុខភាពល្អ អាយុយឺនយូរ ជៀសផុតពីជម្ងឺ។

យើងខ្ញុំទាំងពីរនាក់ សូមថ្លែងអំណរគុណដល់ **ឯកឧត្តមបណ្ឌិត លុយ វណ្ណា សាកលវិទ្យាធិការ សាកលវិទ្យាធិការរង លោក លោកស្រី សាស្ត្រាចារ្យ បុគ្គលិកការិយាល័យសិក្សាការិយាល័យស្រាវជ្រាវ ព្រមទាំងបណ្ណារក្សទាំងអស់** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹកនាំ គ្រប់គ្រង ជ្រោមជ្រែង បង្ហាត់បង្រៀន និងចែករំលែកចំណេះដឹងជូនសិស្សនិស្សិតកន្លងមក។

សូមថ្លែងអំណរគុណ **លោកសាស្ត្រាចារ្យ ឡើក ពិដោរ** ដែលជាសាស្ត្រាចារ្យដឹកនាំ ដោយបានខិតខំប្រឹងប្រែងយកចិត្តទុកដាក់ និងផ្តល់ជាគំនិតក្នុងការជួយ ដោយអស់ពីកម្លាំងកាយ កម្លាំងចិត្ត ក្នុងការដឹកនាំគ្រប់គ្រងជួយសម្រួលយ៉ាងយកចិត្តទុកដាក់ រហូតដល់សារណានេះបានលេចចេញជារូបរាង។

ជាទីបញ្ចប់យើងខ្ញុំទាំងពីរនាក់សង្ឃឹមថា សៀវភៅសារណាមួយក្បាលនេះ និងជួយដល់មិត្តៗនិស្សិតដែលមានបំណងចង់ពង្រឹងចំណេះដឹងបន្ថែម។ សូមសម្តែងសេចក្តីគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅបំផុតចំពោះអ្នកមានគុណដែលបានជួយជ្រោមជ្រែងដល់យើងខ្ញុំទាំងពីរជាពិសេសសូមប្រសិទ្ធពរជ័យសិរីសួស្តី វិបុលសុខ បវរមហាប្រសើរដល់លោកអ្នកមានគុណទាំងអស់មានសុខភាពមាំមួន ទទួលបានជោគជ័យគ្រប់ភារកិច្ច និងមានពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

# អារម្ភកថា

សៀវភៅដែលលោកអ្នកកំពុងតែកាន់ក្នុងដៃនេះគឺជាវណ្ណៈកម្មរបស់ពួកយើងខ្ញុំជានិស្សិតបរិញ្ញាបត្រផ្នែកនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលពួកយើងខ្ញុំបានខិតខំព្យាយាមស្រាវជ្រាវឡើង ដើម្បីទុកជាស្នាដៃសម្រាប់លោកអ្នក។ ពួកយើងខ្ញុំបានព្យាយាមស្រាវជ្រាវនេះឡើងដោយពួកយើងខ្ញុំបានសម្រេចចិត្ត ក្នុងការជ្រើសរើសយកការសរសេរសារណាបញ្ចប់ការសិក្សា ជំនួសការប្រឡងចេញវិញ។ ការសរសេរសារណា យើងខ្ញុំបានខិតខំសិក្សាស្រាវជ្រាវ សរសេរឡើង ជាសមិទ្ធិផលមួយក្នុងការចែករំលែកចំណេះដឹង។

យើងខ្ញុំបានជ្រើសរើសប្រធានបទ **ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ** នេះឡើង ពីព្រោះយើងខ្ញុំបានសិក្សាស្រាវជ្រាវ ដោយមានការយកចិត្តទុកដាក់ និងមានចិត្តចង់យល់ចង់ដឹងបន្ថែមអំពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដើម្បីទុកជាស្នាដៃ ប្រកបដោយការព្យាយាមពីពួកយើងខ្ញុំ ដើម្បីទុកឱ្យប្អូនៗជំនាន់ក្រោយបានធ្វើការសិក្សាបន្ថែម និងសម្រាប់ការរៀនសូត្រ។ ទោះជានៅក្នុងការសរសេរសារណាបញ្ចប់ការសិក្សា យើងខ្ញុំបានខិតខំពិនិត្យផ្ទៀងផ្ទាត់យ៉ាងណាក៏ដោយ ក៏នៅតែមានភ្លាំងភ្លាត់ខុសឆ្គងខ្លះៗ ដោយជាអចេតនាជាពុំខាន។ ការចងក្រងឡើងនូវពាក្យពេចន៍ សម្ដីសំដៅ អត្ថបទប្រាកដជាមានការឆ្គាំឆ្គងឃ្លៀងឃ្លាតជាមិនខាន ដូចជាមានសុភាសិតមួយបានពោលថា **ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់គង់មានភ្លេច**។ ដូច្នេះយើងខ្ញុំសូមអភ័យទោសពី សំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ អ្នកអាន ដោយការគោរព ស្មោះត្រង់ពីពួកយើងខ្ញុំនូវរាល់កំហុសខុសឆ្គងទាំងឡាយណាដែលអាចកើតចេញដោយអចេតនា និងសូមខន្តីអភ័យទោសដោយការគោរព ហើយយើងខ្ញុំទទួលស្វាគមន៍ក្នុងការរិះគន់បែបស្ថាបនាដើម្បីកែលម្អបន្ថែមនូវមតិយោបល់ដើម្បីទទួលបាននូវកិច្ចការសារណាបញ្ចប់ការសិក្សាមួយដ៏ល្អ។

ជាចុងក្រោយយើងខ្ញុំជានិស្សិតនីតិសាស្ត្រ ជំនាន់ទី២៤ ឆ្នាំសិក្សា **២០២៣-២០២៤** នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច យើងខ្ញុំមានចិត្តសប្បាយរីករាយ ក្នុងការយកប្រធានបទនេះ មកធ្វើការសិក្សាស្រាវជ្រាវឡើង ដើម្បីជាចំណងដៃសម្រាប់សាលា មិត្តអ្នកអាន និងខ្លួនឯងផ្ទាល់។ ហើយពួកយើងខ្ញុំសូមប្រសិទ្ធពរដល់មិត្តអ្នកអានទាំងអស់ សិស្សនិស្សិត សាស្ត្រាចារ្យ ជួបប្រទះនូវពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ និងពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

## មាតិកា

**ទំព័រ**


**សេចក្តីផ្តើម** ........................................................................ ១

**ជំពូកទី១ បុព្វហេតុវត្ថុវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

**ផ្នែកទី១ កិច្ចការពារធម្មានុរូប ឬការអនុញ្ញាតដោយច្បាប់** ........................ ១

**១ កិច្ចការពារជាធម្មានុរូបរបស់បុគ្គល** ........................................ ៤

១.១ ការប៉ះពាល់ដល់បុគ្គល ........................................ ៤

១.២ ការប្រឆាំងបក ........................................ ៤

**២ កិច្ចការពារជាធម្មានុរូបនៃទ្រព្យសម្បត្តិ ឬការការពារស្របច្បាប់នៃទ្រព្យសម្បត្តិ** ៦

២.១ ការប៉ះពាល់ដល់ទ្រព្យសម្បត្តិ ........................................ ៧

២.២ ការប្រឆាំងបក ឬការតដៃ ........................................ ៨

**ផ្នែកទី២ ស្ថានភាពចាំបាច់** ........................................ ៩

**១ លក្ខខណ្ឌនៃស្ថានភាពចាំបាច់** ........................................ ១១

១.១ គ្រោះថ្នាក់ ........................................ ១១

១.១.១ បច្ចុប្បន្ន ឬនឹងកើតឡើង ........................................ ១១

១.១.២ ភាពមិនស្របច្បាប់ ........................................ ១២

១.២ ប្រតិកម្មចាំបាច់ សមាមាត្រការការពារបុគ្គល ឬទ្រព្យសម្បត្តិ ........................................ ១២

**ផ្នែកទី៣ បញ្ជាប់របស់អាជ្ញាធរស្របច្បាប់** ........................................ ១៤

**១ ការបញ្ជាដោយអាជ្ញាធរសាធារណៈ** ........................................ ១៤

**២ ការផាត់ចេញនៃការបញ្ជាខុសច្បាប់ជាក់ស្តែង** ........................................ ១៥

២.១ ការវាយតម្លៃជាវត្ថុវិស័យនៃលក្ខណៈខុសច្បាប់ជាក់ស្តែង ........................................ ១៦

២.២ ការវាយតម្លៃជាអត្តវិស័យនៃលក្ខណៈខុសច្បាប់ជាក់ស្តែង ........................................ ១៦

**ផ្នែកទី៤ ការបញ្ជា ឬការអនុញ្ញាតនៃច្បាប់** ........................................ ១៦

**១ ការបញ្ជានៃច្បាប់ ឬបទបញ្ជា** ........................................ ១៧

**២ ការអនុញ្ញាតដោយច្បាប់ ឬបទបញ្ជា** ........................................ ១៧

**ផ្នែកទី៥ អ្នកប្រកាសប្រាប់ពីភាពអាសន្ន** ........ ១៨

**ជំពូកទី២ បុព្វហេតុអត្តវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

**ផ្នែកទី១ កំហុសនៃការយល់ដឹងដែលកើតចេញអំពីសតិមិនល្អ** ........ ២២

**១ លក្ខខណ្ឌ** ........ ២២

១.១ លក្ខខណ្ឌសម្ភារៈ ........ ២២

១.១.១ ការលុបចោលនៃការយល់ដឹង ........ ២៣

១.១.២ ការធ្វើឲ្យចុះខ្សោយនៃការយល់ដឹង ........ ២៤

១.១.៣ ជនដែលមានវិប្លាសស្មារតីដោយសារការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន ........ ២៥

១.២ លក្ខខណ្ឌពេលវេលា ........ ២៧

**២ អានុភាព** ........ ២៧

២.១ ផលវិបាកទៅលើការទទួលខុសត្រូវព្រហ្មទណ្ឌ ........ ២៧

២.២ ការរក្សាទុក ឬការប្រកាន់ទុកនៃការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី ........ ២៨

**ផ្នែកទី២ ការបង្ខិតបង្ខំ** ........ ២៨

**១ ការបង្ខិតបង្ខំរូបកាយ** ........ ២៨

១.១ ការបង្ខិតបង្ខំដែលមានប្រភពដើមពីខាងក្រៅ ឬខាងក្នុង ........ ២៩

១.២ ការបង្ខិតបង្ខំដែលមិនអាចទប់ទល់បាន ........ ២៩

១.៣ ការបង្ខិតបង្ខំមិនដឹងមុន ........ ២៩

**២ ការបង្ខិតបង្ខំផ្លូវចិត្ត** ........ ៣០

២.១ ការទទួលយកការបង្ខិតបង្ខំផ្នែកខាងក្រៅ ........ ៣០

២.២ ការផាតចេញនៃបង្ខិតបង្ខំផ្នែកខាងក្នុង ........ ៣១

**៣ អានុភាពនៃការបង្ខិតបង្ខំ** ........ ៣១

**ផ្នែកទី៣ ការភាន់ច្រឡំលើអង្គច្បាប់** ........ ៣៣

**១ លក្ខខណ្ឌ** ........ ៣៣

១.១ លក្ខខណ្ឌខាងនីតិវិធី ........ ៣៣

១.១.១ ការភាន់ច្រឡំដែលមិនអាចជៀសវាងបាន ........ ៣៣

១.១.២ ជំនឿមួយស្របច្បាប់នៃកិច្ចមួយដែលត្រូវបានបំពេញ ........ ៣៤
**២ អានុភាព** ........ ៣៤
**ផ្នែកទី៤ អនីតិភាព** ........ ៣៥
**១ វិធានការអនុវត្តន៍ចំពោះអនីតិជន** ........ ៣៥
**២ ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន** ........ ៣៦

**ជំពូកទី៣ បុព្វហេតុនៃការមិនទទួលខុសត្រូវរបស់នីតិបុគ្គល**

**ផ្នែកទី១ ទាក់ទងនឹងនីតិបុគ្គល** ........ ៣៧
**១ ការមិនទទួលខុសត្រូវរបស់នីតិបុគ្គលឯកជន** ........ ៣៨
**២ ការមិនទទួលខុសត្រូវរបសនីតិបុគ្គលសាធារណៈ** ........ ៣៩
**សេចក្ដីសន្និដ្ឋាន** ........ ៤០
**អនុសាសន៍** ........ ៤២
**ឯកសារយោង**
**តារាងឧបសម្ព័ន្ធ**
**ឧបសម្ព័ន្ធ**

# សេចក្តីផ្តើម

# សេចក្តីផ្តើម

## ១. លំនាំបញ្ហានៃការស្រាវជ្រាវ

នៅក្នុងសង្គមមួយ ច្បាស់ណាស់អំពើអស្ថិរភាព អសន្តិសុខ ឬភាពវឹកវរ តែងតែកើតមានឡើងដែលបង្កឱ្យប៉ះពាល់ដល់សង្គមជាតិ។ ជាគោលការណ៍ទូទៅនៅក្នុងនីតិវិធីព្រហ្មទណ្ឌ នៅពេលមានបទល្មើសមួយបានកើតឡើង ត្រូវតែមានបុគ្គលណាម្នាក់ជាអ្នកទទួលខុសត្រូវចំពោះបទល្មើសនោះ តែនៅក្នុងករណីខ្លះ នៅពេលដែលមានបទល្មើសមួយកើតឡើង ក៏មានមូលហេតុដែលនាំឱ្យបុគ្គលដែលបានប្រព្រឹត្តបទល្មើសនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ ។ នេះជាមូលហេតុដែលញ៉ាំងឱ្យច្បាប់ត្រូវបានបង្កើតឡើង ដើម្បីគ្រប់គ្រងសកម្មភាពនានារបស់មនុស្ស ទោះបីជាពួកគេមានសិទ្ធិសេរីភាពពេញលេញក៏ដោយ ប៉ុន្តែការប្រើប្រាស់សិទ្ធិនេះត្រូវស្របតាមការចែងរបស់រដ្ឋធម្មនុញ្ញ និងច្បាប់ផ្សេងៗទៀតពោល គឺពលរដ្ឋពុំអាចធ្វើអ្វីតាមតែទំនើងចិត្ត និងហួសព្រំដែនកំណត់នៃច្បាប់ដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិអ្នកដទៃ និងសង្គមជាតិឡើយ។ បុគ្គលដែលប្រព្រឹត្តបទល្មើសអាចជារូបវន្តបុគ្គល ឬនីតិបុគ្គល ដែលរូបវន្តបុគ្គលសំដៅទៅលើនីតិជន និងអនីតិជន។

ជាការពិតណាស់ បុគ្គលដែលប្រព្រឹត្តបទល្មើសពុំអាចរួចផុតពីសំណាញ់ច្បាប់នោះឡើយ ប៉ុន្តែដោយឡែកបើយើងក្រឡេកទៅមើលករណីពិសេសខ្លះទៀត បុគ្គលដែលបានប្រព្រឹត្តបទល្មើសហើយ បែរជាអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ ឬការទទួលខុសត្រូវក្នុងកម្រិតណាមួយកំណត់ដោយច្បាប់ ដែលទទួលបានការការពារដោយច្បាប់ នោះត្រូវបានយកមកសំអាងក្នុងការកំណត់សិទ្ធិជាមូលដ្ឋាន ថាចំពោះអំពើល្មើសបែបណាខ្លះដែលមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌ ។

## ២. ចំណោទបញ្ហានៃការដោះស្រាយ

ដោយមានការសង្កេតឃើញថា ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ចំពោះករណីដែលបានប្រព្រឹត្តិបទល្មើសនៅមានកម្រិតនៅឡើយ ដូច្នេះទើបមានសំណួរចោទជាបញ្ហាឡើងថា តើមានមូលហេតុអ្វីខ្លះដែលនាំឱ្យអ្នកប្រព្រឹត្តិបទល្មើសព្រហ្មទណ្ឌមិនទទួលខុសត្រូវព្រហ្មទណ្ឌ?

## ៣. គោលបំណងនៃការស្រាវជ្រាវ

នៅក្នុងការស្រាវជ្រាវ តាក់តែង និងចងក្រងសារណានេះឡើងមក គឺធ្វើឡើងក្នុងគោលបំណងដើម្បីយល់កាន់តែច្បាស់ ក៏ដូចជាស្រាយបំភ្លឺនូវចម្ងល់ និងចំណោទជាបញ្ហាគតិយុត្តិ ដូចដែលបានលើកបង្ហាញខាងលើនេះដែលពាក់ព័ន្ធនឹងការមិនទទួលខុសត្រូវព្រហ្មទណ្ឌ។ លើសពីនេះ ក្នុងការចងក្រងសារណានេះឡើងក៏ដើម្បីបំពេញចន្លោះខ្វះខាតដែលពួកយើងមាន និងពង្រីកពង្រឹងនូវសមត្ថភាពរបស់ពួកយើងបន្ថែមទៀត។ ជាមួយគ្នានេះផងដែរ ការចងក្រងនូវសារណានេះ ក៏សម្រាប់ទុកជាស្នាដៃសម្រាប់ខ្លួនឯង ជាពិសេសនោះគឺសម្រាប់ទុកជូនសិស្សនិសិត្សជំនាន់ក្រោយ ព្រមទាំងសាធារណៈជនគ្រប់រូបដែលមានបំណងចង់ធ្វើការសិក្សាស្រាវជ្រាវ និងស្វែងយល់អំពីប្រធានបទនេះបន្ថែមទៀត។

## ៤. ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងប្រធានបទ ដែលបានលើកឡើងក្នុងចំណោទខាងលើនេះ សារណានេះត្រូវបានធ្វើការសិក្សាស្រាវជ្រាវលើឯកសារជាមូលដ្ឋានមានដូចជា ក្រមព្រហ្មទណ្ឌ ឆ្នាំ២០០៩ ក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ និងឯកសារបទដ្ឋានគតិយុត្តិទាំងឡាយដែលមានពាក់ព័ន្ធ ដែលបានលើកឡើងក្នុងឯកសារយោងស្រាប់ ដើម្បីសរសេរសារណានេះឡើង។

នៅក្នុងការសរសេរសារណានេះ គឺបានលើកឡើងតែអំពីការពាក់ព័ន្ធទាំងឡាយ ដែលទាក់ទងជាមួយនឹងការមិនទទួលខុសត្រូវព្រហ្មទណ្ឌតែប៉ុណ្ណោះ។

## ៥. សារៈប្រយោជន៍នៃការស្រាវជ្រាវ

សារណានេះមានសារៈប្រយោជន៍ជាច្រើនចំពោះអ្នកសិក្សា អ្នកអាន និងអ្នកសិក្សាស្រាវជ្រាវផ្ទាល់ដោយសារតែ សារណានេះបានវែកញែក បកស្រាយយ៉ាងស៊ីជម្រៅពីការកំណត់នូវវិធាន និងមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ នូវបទល្មើសបានប្រព្រឹត្ត និងអាចឱ្យបងប្អូននិស្សិតយល់ដឹងអំពីផ្នែកមួយនៃនីតិព្រហ្មទណ្ឌអំពីការមិនទទួលខុសត្រូវក្នុងរឿងក្តីព្រហ្មទណ្ឌផងដែរ។

## ៦. វិធីសាស្ត្រនៃការស្រាវជ្រាវ

សារណានេះ ត្រូវបានរៀបចងក្រងឡើងដោយប្រើប្រាស់នូវ វិធីសាស្ត្របែបពិពណ៌នា និងវិភាគ។ យើងខ្ញុំបានធ្វើការសិក្សាស្រាវជ្រាវដោយ ធ្វើការប្រមូលព័ត៌មានទាំងឡាយ ក៏ដូចជាឯកសារនានាដែលពាក់ព័ន្ធទៅនឹងប្រធានបទនៃសារណានេះដើម្បីឱ្យកាន់តែមានភាពត្រឹមត្រូវច្បាស់លាស់ និងមានប្រសិទ្ធិភាពខ្ពស់។ ព័ត៌មានទាំងឡាយ ដែលបានធ្វើការស្រាវជ្រាវឡើង ដែលជាមូលដ្ឋានគ្រឹះប្រកបដោយសុក្រឹត្យភាព រួមមានការពាក់ព័ន្ធនិងច្បាប់នានា និងពឹងផ្អែកទៅលើការសុំការណែនាំពីសាស្ត្រាចារ្យដឹកនាំសារណា សុំមតិយោបល់ពីលោកគ្រូអ្នកគ្រូ សាស្ត្រាចារ្យ សិស្សច្បង ឯកសារបទដ្ឋានគតិយុត្តនានា។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ជារួមមកប្រធានបទស្រាវជ្រាវអំពី **ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ** គឺត្រូវបានបែងចែកជា ០៣ ជំពូកធំៗរួមមាន៖

**ជំពូកទី១ ៖ បុព្វហេតុវត្ថុវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

**ជំពូកទី២ ៖ បុព្វហេតុអត្តវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ**

**ជំពូកទី៣ ៖ បុព្វហេតុនៃការមិនទទួលខុសត្រូវរបស់នីតិបុគ្គល**

# ជំពូកទី១

# បុព្វហេតុវត្ថុវិស័យនៃការ
# មិនទទួលខុសត្រូវ
# ព្រហ្មទណ្ឌ

## ជំពូកទី១ បុព្វហេតុវត្ថុវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

អំពើមួយដែលជាធម្មតាត្រូវផ្តន្ទាទោសដោយច្បាប់ តែបែរជាត្រូវចាត់ទុកថាត្រឹមត្រូវទៅវិញ នៅពេលអំពើនោះបានបង្ហាញពីការអនុវត្តសិទ្ធិ ឬជាការបំពេញកាតព្វកិច្ច បានសេចក្តីថាអំពើនោះបានកើតឡើងដោយសារតែផលប្រយោជន៍ស្របច្បាប់ហើយផលប្រយោជន៍នោះ មានសារៈសំខាន់ជាងការចាត់ទុកអំពើនោះជាបទល្មើស[1]។ បុព្វហេតុវត្ថុវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ គឺជាមូលហេតុដែលគេចាត់ទុកថាកើតចេញមកពីក្រៅបុគ្គលនៃចារីហើយដែលធ្វើឱ្យចារីបានរួចផុតពីការទទួលខុស នឹងនាំឱ្យអ្នកផ្តើមគំនិត ឬអ្នកសមគំនិតក៏រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌដូចគ្នាទៅនឹងចារីផងដែរ [2] ។ ផ្ទុយទៅនឹងបុព្វហេតុអត្តវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ដែលមានប្រភពក្នុងបុគ្គលភាពរបស់ជនជាប់ចោទ បុព្វហេតុវត្ថុវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ មានប្រភពនៅក្នុងកាលៈទេសៈជុំវិញនៃការប្រព្រឹត្តបទល្មើស បុព្វហេតុវត្ថុវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌមាន ០៥ ដែលចែងដោយក្រមព្រហ្មទណ្ឌ ទី១ កិច្ចការពារជាធម្មានុរូប ទី២ ស្ថានភាពចាំបាច់ ទី៣ ការបង្គាប់បញ្ជាដោយអាជ្ញាធរស្របច្បាប់ ទី៤ ការបង្គាប់បញ្ជា ឬការអនុញ្ញាតដោយច្បាប់ និងទី៥ ហេតុដែលបញ្ជាក់ផ្ទាល់ពីការប្រកាសភាពអាសន្ន[3] ។

តាមការអនុវត្តជាក់ស្តែង បុព្វហេតុវត្ថុវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ អាចលើកឡើងបាន តែកាលណាការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានធ្វើឡើងតែប៉ុណ្ណោះ ហើយកាលណាទោសដែលត្រូវដាក់ត្រូវបានលើកមកបង្ហាញ ត្រូវបញ្ជាក់ថា បុព្វហេតុវត្ថុវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ឬហេតុបញ្ជាក់មិនត្រូវធ្វើជាឧបសគ្គដល់ការបង្កើតបទល្មើសមួយនោះទេ ប៉ុន្តែផ្ទុយទៅវិញវាមកបញ្ជាក់អំពីការប្រព្រឹត្តនៃបទល្មើសព្រហ្មទណ្ឌមួយ ដែលត្រូវបានបង្កើតឡើងទាំងស្រុង ក្នុងភាពទាំងស្រុង នៃធាតុផ្សំរបស់វា ។

### ផ្នែកទី១ កិច្ចការពារធម្មានុរូប ឬការអនុញ្ញាតដោយច្បាប់

រាល់អំពើទាំងឡាយណាដែលកើតចេញពីការបំពេញកាតព្វកិច្ច ដែលតម្រូវដោយច្បាប់ ឬជាការអនុវត្តសិទ្ធិដែលច្បាប់បានបញ្ញត្តិ ឬអនុញ្ញាតឱ្យប្រព្រឹត្តអំពើនោះច្បាប់មិនបានបញ្ញត្តិឱ្យផ្តន្ទាទោសឡើយ ចុះពាក្យថាច្បាប់ ក្នុងមាត្រាខាងលើមានន័យយ៉ាងដូចម្តេច? ន័យទូលាយ ឬ ន័យចង្អៀត?

**ន័យទូលាយៈ** សំដៅលើរាល់លិខិតបទដ្ឋានគតិយុត្តដែលត្រូវបានបង្កើត និងគ្រប់គ្រងទំនាក់ទំនងទាំងអស់ក្នុងសង្គម។

---

[1] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៤៨។

[2] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ, (ភ្នំពេញៈអង្គរ, ២០១៣),២៤៣។

[3] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៣២ កថាខណ្ឌទី១។

**ន័យចង្អៀត:** សំដៅលើរាល់លិខិតបទដ្ឋានគតិយុត្តដែលត្រូវបានបង្កើត និងអនុម័តឡើងដោយអង្គការនីតិបញ្ញត្តិ និងឡាយព្រះហត្ថលេខាដាក់ឱ្យប្រើប្រាស់ដោយព្រះមហាក្សត្រ[4]។

តាមនិយមន័យទាំងពីរខាងលើ ក្រមព្រហ្មទណ្ឌមិនបានបញ្ញត្តិថាជាច្បាប់ក្នុងន័យមួយណាទេ តែបើគេពិនិត្យទៅលើករណីមួយ ដែលអាចចាត់ទុកជាករណីដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌលុះត្រាតែមានការអនុញ្ញាតពីច្បាប់ ឬមាននៅក្នុងច្បាប់(ន័យចង្អៀត) ទើបករណីនោះក្លាយជាមូលហេតុដែលរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ។

**ឧទាហរណ៍:**

១.ការចាប់ខ្លួនជនសង្ស័យដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ចំពោះបទល្មើសជាក់ស្តែង ។ ការចាប់ខ្លួនជនសង្ស័យស្ថានភាពជាក់ស្តែង [5] គឺត្រូវបានក្រមព្រហ្មទណ្ឌកំណត់ពីអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង។

២.មេធាវីម្នាក់ បានការពារសិទ្ធិឱ្យកូនក្តីរបស់ខ្លួន ដែលត្រូវបានចោទប្រកាន់ពីបទបើកបរដោយធ្វេសប្រហែសបណ្តាល ឱ្យរបួសធ្ងន់ដល់អ្នកដទៃ។ ក្នុងករណីនេះមេធាវីមិនត្រូវបានចាត់ទុកថាជាជនល្មើសឡើយ ព្រោះការការពារក្តីមួយនេះ ជាសិទ្ធិដែលច្បាប់បានផ្តល់ឱ្យមេធាវីក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដើម្បីបម្រើផលប្រយោជន៍សាធារណៈ និងឯកជន។

គេអាចទៅយកក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់មាត្រា៨៧ មកពិនិត្យជាសំអាងព្រោះច្បាប់បានអនុញ្ញាតឱ្យប្រជាពលរដ្ឋមានសិទ្ធិចាប់ខ្លួនជនល្មើស នៅក្នុងករណីប្រព្រឹត្តិបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ដើម្បីយកទៅប្រគល់ឱ្យនគរបាលយុត្តិធម៌ដែលនៅជិតបំផុត[6]។ ផ្ទុយទៅវិញនោះ ប្រសិនបើគ្មានច្បាប់ចែងយ៉ាងដូច្នេះ បែរជាប្រជាពលរដ្ឋ ឬនគរបាលយុត្តិធម៌ទៅចាប់ខ្លួនអ្នកដទៃដូចករណីខាងលើនេះ គឺជាការចាប់បង្ខាំងមនុស្សដោយខុសច្បាប់[7]។

ក្នុងមាត្រា៣២ វាក្យខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ បានចែងច្បាស់ថា បុគ្គលណាដែលប្រព្រឹត្តអំពើខុសច្បាប់ បានបញ្ញត្តិ ឬអនុញ្ញាតតាមច្បាប់បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។ ដូច្នេះវាក៏ប្រែក្លាយជាអំពើស្របច្បាប់ទៅវិញដែលជាហេតុនាំឱ្យ អ្នកប្រព្រឹត្តអំពើមួយមិនទទួលខុសត្រូវព្រហ្មទណ្ឌអ្វីសោះឡើយ[8]។

[4] សេចក្តីផ្តើមនីតិកម្ពុជា ក្រោមការដឹកនាំស្រាវជ្រាវរបស់ ស.ភ.ន.វ.ស។

[5] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៨៥។

[6] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៨៧។

[7] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ, (ភ្នំពេញ:អង្គរ, ២០១៣),២៤៣។

[8] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ, (ភ្នំពេញ:អង្គរ, ២០១៣),២៤៣។

**ឧទាហរណ៍:** នគរបាលយុត្តិធម៌ ឬប្រជាពលរដ្ឋប្រព្រឹត្តអំពើដែលត្រូវបានបញ្ញត្តិដោយច្បាប់ ដូចជាការទៅចាប់ខ្លួនជនល្មើស។ សកម្មភាពអាជ្ញាធរ ចុះរុះរើសំណង់អនាធិបតេយ្យដែលត្រូវបានសាងសង់ឡើងដោយខុសច្បាប់ជាដើម។

មាត្រា៣២ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ បានចែងថា បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្តិ ឬ អនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។ ប៉ុន្តែមាត្រា៣២ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ចំពោះបុគ្គលណាដែលប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនោះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់[9]។

តាមអត្ថន័យខាងលើនេះ ក្រមព្រហ្មទណ្ឌថ្មីបានបង្ហាញពីអំពើដែលត្រូវបានបញ្ញត្តិថាជាបទល្មើសតែបែរជាមិនមែនបទល្មើសទៅវិញ គឺដោយមូលហេតុថាអំពើនោះត្រូវបានអនុញ្ញាតដោយច្បាប់ និងមានការអនុញ្ញាតពីអាជ្ញាធរ។

ប៉ុន្តែក្នុងករណីលើកលែងចំពោះ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទល្មើសប្រល័យពូជសាសន៍ បទល្មើសឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬបទល្មើសឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ៖

១.ជនល្មើសដែលបានប្រព្រឹត្តអំពើដែលបញ្ញត្តិ ឬអនុញ្ញាត ឬមិនហាមឃាត់ ដោយច្បាប់អនុញ្ញាតជរមាន។

២. បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់[10]។

**ឧទាហរណ៍:** ទោះបីជាច្បាប់ជាធរមាននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យអនុញ្ញាតឱ្យមានការសម្លាប់មនុស្សក៏ដោយ ក៏អំពើនោះត្រូវបានចាត់ទុកជា បទឧក្រិដ្ឋប្រល័យពូជសាសន៍[11] បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ[12] បទឧក្រិដ្ឋសង្គ្រាម[13] ដូច្នេះ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិត មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយទោះបីជនល្មើសបានប្រព្រឹត្តអំពើដែលច្បាប់នាសម័យនោះបានអនុញ្ញាត ឬច្បាប់មិនបានហាមឃាត់ក៏ដោយ។

[9] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៣២ កថាខណ្ឌទី១។

[10] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៣២ កថាខណ្ឌទី២។

[11] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា១៨៣។

[12] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា១៨៤។

[13] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា១៩៣។

ចំពោះកិច្ចការពារជាធម្មានុរូប ឬការអនុញ្ញាតដោយច្បាប់នេះ ក៏បានបែងចែកជាបីចំណុចបន្ថែមមាន ដូចជា៖ កិច្ចការពារជាធម្មានុរូប ឬការអនុញ្ញាតដោយច្បាប់ (១) កិច្ចការពារជាធម្មានុរូបនៃទ្រព្យសម្បត្តិ (២) និង បន្ទុកនៃភស្តុតាងនៃកិច្ចការពារជាធម្មានុរូប (៣) ។

## ១ កិច្ចការពារជាធម្មានុរូបរបស់បុគ្គល

យោងតាមបញ្ញត្តិក្រមព្រហ្មទណ្ឌខាងលើ អ្នកនីតិបញ្ញត្តិមានបំណងបង្កើតជាយុត្តិកម្មនូវអំពើតាមធម្មតាជាបទល្មើស ប៉ុន្តែអំពើនោះបែរជាមិនត្រូវចាត់ទុកជាបទល្មើសទៅវិញដូចជា ការប៉ះពាល់ដល់បុគ្គល (១.១) ឬការប្រឆាំងបក (១.២)[14]។ ក្រមព្រហ្មទណ្ឌចាស់របស់កម្ពុជា កំណត់ដែរថា មិនចាត់ទុកជាអំពើល្មើសព្រហ្មទណ្ឌទេ កាលណាបើអំពើទាំងឡាយនោះធ្វើតាមបង្គាប់របស់ច្បាប់ ហើយអ្នកបញ្ជាឱ្យធ្វើក៏ជាអាជ្ញាធរធម្មានុរូបដែរ។

### ១.១ ការប៉ះពាល់ដល់បុគ្គល

ការការពារស្របច្បាប់ របស់បុគ្គលត្រូវអនុវត្តចំពោះស្ថានភាពទាំងឡាយណាដែលការប៉ះពាល់មួយត្រូវធ្វើឡើងប្រឆាំងនឹងបុគ្គលនោះ ឬប្រឆាំងនឹងអ្នកដទៃ ដូច្នេះ ការពារស្របច្បាប់ មានឧបនិស្ស័យ ការពារមិនត្រឹមតែបុគ្គលដែលត្រូវការពារប្រឆាំងនឹងការប៉ះពាល់មួយ ចំពោះការប្រឆាំងនឹងខ្លួនឯងប៉ុណ្ណោះទេ ក៏ប៉ុន្តែការពារផងដែរ ចំពោះបុគ្គលដែលត្រូវធ្វើអន្តរាគមន៍ ដើម្បីការពារតតិយជនណាម្នាក់។

ការប៉ះពាល់ចំពោះបុគ្គលណាម្នាក់ ត្រូវមានពិតប្រាកដ។ លក្ខខណ្ឌទិដ្ឋភាពនាំទៅដល់ការផាត់ចេញពីការការពារស្របច្បាប់ រាល់ការប៉ះពាល់ទាំងឡាយណាដែលមានលក្ខណៈទោសទណ្ឌសុទ្ធសាត ពោលគឺការប៉ះពាល់ដែលមានតែនៅក្នុងស្មារតីរបស់ចារីប៉ុណ្ណោះ។ ផ្ទុយទៅវិញលក្ខខណ្ឌនេះ ត្រូវបំពេញ ទោះជាមិនមានការប៉ះពាល់ក៏ដោយ តាំងពីពេលដែលមានហេតុកើតឡើង ចារីបានមានហេតុផលក្នុងការគិតថាខ្លួនត្រូវបានបំពាន។

**ឧទាហរណ៍:** ការការពារស្របច្បាប់ស្តីពី ឪពុកម្នាក់ចាញ់ទៅលើមិត្តរបស់កូនប្រុសរបស់ខ្លួន ដែលបានបានផ្ទុងអាវុធ ទៅលើកូនប្រុសរបស់ខ្លួន ក្នុងក្របខណ្ឌនៃល្បែងមួយ។

ការប៉ះពាល់ដែលមានលក្ខណៈមិនត្រឹមត្រូវ ពាក្យប៉ះពាល់មានន័យទូលំទូលាយយ៉ាងគ្រប់គ្រាន់ ដើម្បីក្តោបនៅទម្រង់ឈ្លានពានជាច្រើន និងទម្រង់បំពានជាច្រើនដែលទាញចេញពីនោះ៖

១ គ្រោះថ្នាក់រូបកាយ **ឧទាហរណ៍៖** អំពើហិង្សា ឬការបំពានផ្លូវភេទ ។

២ គ្រោះថ្នាក់ខាងផ្លូវចិត្ត **ឧទាហរណ៍៖** ហានិភ័យ នៃអំពើទុច្ចរិត។

លក្ខណៈមិនត្រឹមត្រូវនៃការប៉ះពាល់ផាតចេញ ការការពារប្រឆាំងនឹងអំពើដែលប្រព្រឹត្តឡើងស្របទៅនឹងច្បាប់ ។

[14] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៤៩។

**ឧទាហរណ៍:** បុគ្គលម្នាក់ មិនអាចលើកឡើងពីការការពារខ្លួនស្របច្បាប់ ដើម្បីពន្យល់ពីការឈ្លានពាន ប្រព្រឹត្តឡើងប្រឆាំងនឹងនគរបាលដែលដាក់ខ្នោះខ្លួន នៅពេលចាប់ខ្លួននោះទេ។

### ១.២ ការប្រឆាំងបក

ការការពារខ្លួន ត្រូវកើតឡើងជាដំណាលគ្នា វាមិនអាចធ្វើឡើងក្រោយការប៉ះពាល់បានទេ ។ ក្នុងករណី នេះ ប្រសិនបើវាមិនកើតឡើងដំណាលគ្នាទេ វាជាការសងសឹកវិញ។

ក្នុងករណីនេះផងដែរ ចំពោះការប្រឆាំងបក ឬហៅថាការតដៃនេះ ដើម្បីការពារខ្លួនឯងត្រូវមានលក្ខណៈ ចាំបាច់បំផុត ដើម្បីធ្វើជាឧបសគ្គ ឬរារាំងនៅពេលដែលមានការឈ្លានពានត្រូវបានកើតឡើង។

**ឧទាហរណ៍:**

១ មិនមានលក្ខណៈចាំបាច់ការដាល់មួយដៃទៅលើអ្នកឈ្លានពាន ដែលបានទប់ជាប់នៅនឹងដីដោយ តតិយជន។ ដូចគ្នានេះដែរ ត្រូវបានវិនិច្ឆ័យថាជាការតដៃដែលមានលក្ខណៈមិនចាំបាច់ ដូចជាការបាញ់កាំភ្លើង ទៅលើអ្នកឈ្លានពាន ដែលត្រូវបានគេចាប់ខ្លួនរួចហើយនឹងលើកដៃឡើងលើជាស្រេចទៅហើយនោះ ហើយ យើងបែរជាបាញ់ទៅលើអ្នកឈ្លានពានទៀត នោះការតដៃនេះវាមិនត្រូវនោះទេ។

ក្នុងនោះផងដែរចំពោះការប្រឆាំង ឬការតដៃត្រូវមានសមាមាត្រ បុគ្គលដែលប្រើមធ្យោបាយការពារខ្លួន មិនសមាមាត្រ ប្រឈមទៅនឹងការឈ្លានពាន ចេញក្រៅពីក្របខណ្ឌនៃការការពារខ្លួនស្របច្បាប់ហើយ លក្ខណៈ សមាមាត្រនៃការតដៃ ត្រូវបានវាយតម្លៃទៅតាមកាលៈទេសៈនៃហេតុ។ គួរបញ្ជាក់ថាផលវិបាកនៃអំពើតដៃ មិន អាចត្រូវបានយកមកពិចារណាតាមផ្លូវច្បាប់ ដើម្បីបញ្ជាក់លក្ខណៈ ឬមិនបញ្ជាក់លក្ខណៈពីហេតុដែលត្រូវយុត្តិ កម្មដល់ការការពារខ្លួននោះទេ។ សភាឧក្រិដ្ឋរបស់តុលាការបារាំង ទទួលយកថាភាពសមាមាត្រត្រូវតែមានរវាង អំពើឈ្លានពាន នឹងអំពើនៃការតដៃ ហើយមិនមែនរវាងផលវិបាកនៃឥរិយាបថការពារខ្លួននោះទេ។

**ឧទារហណ៍:** ត្រូវបានចាត់ទុកជាការតដៃ ដែលមានលក្ខណៈសមាមាត្រទៅនឹងការប៉ះពាល់មួយចំនួនៈ

១ ការបាញ់កាំភ្លើងទៅលើអាកាស បន្ទាប់មកទៀតបាញ់គ្រាប់ទីពីរចំ ជើងអ្នកឈ្លានពាន ដែលបានដើរ ទៅមុខ ដោយកាន់ប្រដាប់អាវុធដែលមានគ្រាប់។

២ ការប្រើប្រាស់គ្រាប់បែកបង្ហូរទឹកភ្នែក ប្រឆាំង និងអាជ្ញាសាលាម្នាក់ ដែលបានកំពុងប្រព្រឹត្តនៅការ រំលោភលំនៅដ្ឋាន ការចាប់បង្ខាំងមនុស្ស និងការរំលោភសិទ្ធិមួយចំនួន។

ផ្ទុយទៅវិញ ត្រូវបានចាត់ទុកជាមធ្យោបាយការពារខ្លួនមួយចំនួនផងដែរមានលក្ខណៈមិនសមាមាត្រ

៣ ស្ត្រីម្នាក់ដែលបានវាយនឹងស្បែកជើងកែងចោទ ដែលមានកែងស្រួចទៅលើក្បាលរបស់បុរសម្នាក់ ដែលស្រវឹង ដែលមកកៀកខ្លួន តែថាបុរសនោះមិនបានត្រូវនោះទេ ដោយសារតែមានអ្នកដំណើរជួយឃាត់ស្ត្រី ម្នាក់នោះជាប់។

៤ បុរសម្នាក់បានប្រើប្រាស់គ្រាប់បែកបង្ហូរទឹកភ្នែក គុបដាក់ទៅលើនារីម្នាក់ ឬហៅថាជាសកម្មភាពឆ្លើយតបទៅនឹងការឈ្លានពានដែលនារីម្នាក់នោះបានចាប់បោចសក់របស់គាត់។

ចំពោះករណីប្រឆាំងបក ឬហៅថាការតដៃដោយភ្ជាប់ជាធន្ទៈ អំពើនៃការការពារស្របច្បាប់ចាំបាច់ត្រូវមានលក្ខណៈជាធន្ទៈ ដូច្នេះ តាមយុត្តិសាស្ត្របារាំង ដែលមានលក្ខណៈ ថេរជាប្រចាំ គឺថាលក្ខណៈធន្ទៈនៃការការពារមានលក្ខណៈវិសមភាពជាមួយបទល្មើសអចេតនា។

## ២ កិច្ចការពារជាចម្មានុរូបនៃទ្រព្យសម្បត្តិ ឬការការពារស្របច្បាប់នៃទ្រព្យសម្បត្តិ

យោងតាមមាត្រា៣៣ ផ្នែកទី១ បានចែងថា: បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ។

ដើម្បីបញ្ចៀសពីការបាត់បង់នូវទ្រព្យសម្បត្តិទាំងឯកជន ឬសាធារណៈផង ដែលទ្រព្យសម្បត្តិទាំងនោះគឺប្រឈមមុខនឹងការឈ្លានពានណាមួយដែលមិនត្រឹមត្រូវ បណ្តាលឱ្យមានការបាត់បង់ ឬខូចខាតជាដើម។ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ក៏បានបញ្ញត្តិឡើងដើម្បីការពារទ្រព្យសម្បត្តិដែលប្រឈមនឹងការឈ្លានពានផងដែរ។ ករណីមានជនណាម្នាក់មកឈ្លានពានលើទ្រព្យសម្បត្តិណាមួយទាំងឯកជន និងសាធារណៈ នោះចារីអាចមានសិទ្ធិការពារបាន តែការការពារនោះគឺមិនត្រូវលើសពីព្រំដែនដែលច្បាប់បានបញ្ញត្តិឱ្យឡើយ។ ពោលគឺមិនត្រូវដល់ថ្នាក់សម្លាប់បានទេ ព្រោះវត្ថុ ឬទ្រព្យសម្បត្តិមិនមានតម្លៃស្មើនឹងអាយុជីវិតមនុស្សម្នាក់បានទេ ដូច្នេះ ប្រសិនបើនៅក្នុងករណីដែលមានការឈ្លានពានណាមួយ យើងអាចមានសិទ្ធិត្រឹមតែបណ្តេញចេញ ចាប់ ឃាត់ខ្លួន ឬប្តឹងទៅសមត្ថកិច្ច។ល។

**ឧទាហរណ៍:** លោក ក បានឃើញលោក ខ ដើរលបៗសំដៅមានបំណងទៅលួចស្បែកជើងថ្មីដែលលោក ក ទើបតែទិញ។ លោក ក ឃើញដូច្នោះ ក៏បានទាញឈើជ្រុងមួយវាយចំកញ្ចឹងកលោក ខ បណ្តាល ឱ្យរងរបួសធ្ងន់។ អំពើដែលលោក ក បានធ្វើទៅលើលោក ខ ដើម្បីទប់ទល់នឹងការលួចមួយនេះហួសដែនកំណត់នៃកម្លាំងនៃការឈ្លានពាន ហើយម្យ៉ាងវិញទៀតអំពើដែលលោក ក បានប្រព្រឹត្តនោះអាចបណ្តាលឱ្យលោក ខ ស្លាប់បាន។ ទ្រព្យសម្បត្តិមិនអាចប្រៀបនឹងអាយុជីវិតមនុស្សបានទេ ទ្រព្យសម្បត្តិអាចរកវិញបានតាមក្រោយ ប៉ុន្តែជីវិតមនុស្សគ្មានអ្វីយកមកជួសបានឡើយ។ ដូច្នេះសរុបមកវិញទង្វើរបស់លោក ក ដែលបានធ្វើដើម្បីការពារទ្រព្យសម្បត្តិរបស់ខ្លួនគឺគាត់ត្រូវប្រឈមមុខនឹងច្បាប់។

ការការពារទ្រព្យសម្បត្តិ គឺជាកាតព្វកិច្ចចាំបាច់គួរតែត្រូវធ្វើដើម្បីទប់ទល់នឹងការឈ្លានពានរក្សាការពារនូវទ្រព្យឱ្យបានគង់វង្ស តែប្រសិនបើការការពារនោះលើសកម្រិតនៃការឈ្លានពានទៅទៀតនោះ បុគ្គលនោះនឹងត្រូវប្រឈមមុខនឹងច្បាប់ជាក់ជាពុំខាន។ ប្រសិនបើនៅក្នុងករណីមិនអាចគេចបាន យើងត្រូវប្រព្រឹត្តតបតវិញ ហើយប្តឹងទៅសមត្ថកិច្ចជាដើម។

សូមបញ្ជាក់នូវពាក្យថា ការការពារទ្រព្យសម្បត្តិនេះ គឺអាចការពារទាំងទ្រព្យសម្បត្តិរបស់ខ្លួនឯង និង

អាចការពារទាំងទ្រព្យសម្បត្តិរបស់អ្នកដទៃទៀតផង។ មួយទៀតគឺពាក្យថា គ្មានសមាមាត្រ គឺស្មើនឹងមានតុល្យភាព ផ្ទុយទៅវិញ គ្មានតុល្យភាពគឺស្មើនឹងមានសមាមាត្រ នាំឱ្យពាក្យដែលថាគ្មានវិសមាមាត្រ ស្មើនឹងមានសមាមាត្រ ឬវិសមាមាត្រ ស្មើនឹងសមាមាត្រនេះឯង ពីព្រោះថា គ្មានសមាមាត្រ និងវិសមាមាត្រនេះ បើតាមក្បួនគណិតសាស្ត្រ គឺយើងសម្រួលឱ្យស្មើនឹងសូន្យបាត់ហើយ ដោយសារតែយើងស៊ីសង ឬក៏ទូទាត់គ្នារួចរាល់អស់ហើយ[15]។

យោងតាមក្រមព្រហ្មទណ្ឌបារាំង មាត្រា១២២ ត្រេ៥ វាក្យខណ្ឌ២ ការការពារស្របច្បាប់នៃទ្រព្យសម្បត្តិចែងយ៉ាងដូច្នេះថា មិនមានការទទួលខុសត្រូវខាងព្រហ្មទណ្ឌ បុគ្គលដែលបំពេញនៃកិច្ចមួយនៃការការពារដើម្បីការកាត់ផ្តាច់ការអនុវត្តនៃបទឧក្រិដ្ឋមួយ ឬបទមជ្ឈិមមួយ ប្រឆាំងនៅទ្រព្យសម្បត្តិមួយ ក្រៅតែពីមនុស្សឃាតដោយចេតនា កាលណាអំពើនេះចាំបាច់បំផុតសម្រាប់គោលបំណងដែលបានធ្វើ កាលណាមធ្យោបាយដែលប្រើសមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃបទល្មើស[16]។

ដូច្នេះ ត្រូវមានការប៉ះពាល់មួយដល់ទ្រព្យសម្បត្តិ(២.១) ហើយត្រូវមានការប្រឆាំងបក ឬការដៃតមកវិញ(២.២) ដែលគោរពលក្ខណៈដាក់លាស់មួយចំនួន[17]។

### ២.១ ការប៉ះពាល់ដល់ទ្រព្យសម្បត្តិ

ការប៉ះពាល់ដល់ទ្រព្យសម្បត្តិនេះ ខុសគ្នាទៅតាមការប៉ះពាល់ ដែលឆ្លើយតបទៅនឹងបទឧក្រិដ្ឋមួយ ឬបទមជ្ឈិមមួយ (២.១.១) ឬឆ្លើយតបទៅនឹងបទលហុ (២.១.២)។

#### ២.១.១ បទឧក្រិដ្ឋមួយ ឬបទមជ្ឈិមមួយ

រាល់ការប៉ះពាល់ដល់ទ្រព្យសម្បត្តិមួយ និងមិនអាចបញ្ជាក់បានពីការការពារស្របច្បាប់នោះទេ មានតែការប៉ះពាល់ដែលជាបទឧក្រិដ្ឋ ឬបទមជ្ឈិមមួយប៉ុណ្ណោះ ទើបវាចូលទៅក្នុងដែនអនុវត្តនៃអត្ថបទ មានន័យថាត្រូវបានការពារដោយច្បាប់។

#### ២.១.២ បទលហុ

ចំពោះអំពើដែលជាបទលហុមិនមានការការពារស្របច្បាប់នៃទ្រព្យសម្បត្តិនោះទេ។ ចំណែកការធ្វើឱ្យចុះថមថយស្រាលៗ (បានន័យថាការធ្វើអោយរីករិលតិច) មិនមែនជាមូលដ្ឋានគ្រឹះនៃការការពារស្របច្បាប់នោះទេ ដូច្នេះ ហើយចំពោះអ្នកដែលប្រព្រឹត្តបទលហុនោះ ច្បាប់ព្រហ្មទណ្ឌបារាំងមិនការពារនោះទេ។

**ឧទាហរណ៍:** ការទាត់រថយន្ត មួយជើងមិនអាចបញ្ជាក់អំពើហិង្សាដែលប្រព្រឹត្តឡើង ដោយឆ្លើយតបមកវិញនោះទេ។ ចំណុចបានន័យថាមិនមែនគ្រាន់តែគេទាត់រថយន្តយើងមួយជើង យើងស្ទុះទៅវាយគេនោះទេ ហើយគិតថាវាជាការការពារខ្លួន ឬការការពារទ្រព្យសម្បត្តិនោះទេ ដូច្នេះច្បាប់ការពារអំពើបែបនេះឡើយ។

---

[15] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ, (ភ្នំពេញ៖អង្គរ, ២០១៣),២៤៨។

[16] ព្រហ្មទណ្ឌបារាំង (២២ កក្កដា ២០១២),១២២ ត្រេ៥ វាក្យខណ្ឌទី២។

[17] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៤៩។

### ២.២ ការប្រឆាំងបក ឬការតដៃ

ការប្រឆាំងបក ឬការតដៃ ដូចគ្នាទៅនឹងការការពារស្របច្បាប់របស់បុគ្គលដែល ការប្រឆាំងបកត្រឡប់ទៅវិញ ត្រូវតែកើតឡើងដំណាលគ្នា វាត្រូវតែចាំបាច់បំផុត(២.២.១)ហើយត្រូវសមាមាត្រ (២.២.២)។

#### ២.២.១ ចាំបាច់បំផុត

លក្ខណៈចាំបាច់បំផុត នៃការប្រឆាំងត្រឡប់មកវិញដែលការប្រឆាំងត្រឡប់នេះ ត្រូវតែជាមធ្យោបាយតែមួយគត់ ក្នុងការបញ្ឈប់បទល្មើសដែលប្រព្រឹត្តឡើង ហើយរក្សាឱ្យបាននូវទ្រព្យសម្បត្តិ ។

#### ២.២.២ សមាមាត្រ

ការប្រឆាំងបកត្រូវតែសមាមាត្រផងដែរទៅនឹងភាពធ្ងន់ធ្ងរនៃការវាយណាមួយ។ គេអាចកត់សម្គាល់ថាអ្នកច្បាប់មិនបានបង្កើតទំនាក់ទំនងនៃសមាមាត្រភាពរវាងការវាយនឹងតម្លៃនៃទ្រព្យសម្បត្តិនោះទេ ប៉ុន្តែរវាងការវាយនឹងបទល្មើស។ អ្នកច្បាប់បាននាំមកនៅព្រំដែនមួយខាងការប្រឆាំងបកត្រឡប់ទៅវិញៈ ការការពារទ្រព្យសម្បត្តិមួយមិនអាចបញ្ជាក់បានទាល់តែសោះ នៃការប្រព្រឹត្តនៃបទមនុស្សឃាតដោយចេតនាមួយ។

**ឧទាហរណ៍:** អន្ទាក់ដែលសម្រាប់សម្លាប់សត្វដែលគេហាមឃាត់ ផ្ទុយទៅវិញអន្ទាក់សម្រាប់ធ្វើអោយរបួសចោរណាម្នាក់ជាយថាហេតុ ឬចោរលួចដែលត្រូវបានអនុញ្ញាតឱ្យធ្វើ[18]។

យោងតាមក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ក្របខណ្ឌនៃការការពារស្របច្បាប់ បានកំណត់ចេញជាលក្ខខណ្ឌមួយករណីទៀត ដែលពាក់ព័ន្ធនឹងការបង្ហាញភស្តុតាងពោល គឺជនជាប់ចោទមិនបាច់លើកសំអាងពីការពារស្របច្បាប់របស់ខ្លួនតាមលក្ខខណ្ឌនៃមាត្រា ៣៣ នៃក្រមព្រហ្មទណ្ឌឡើយ។ មានករណីមួយទៀតដែលនៅក្នុងក្របខណ្ឌ នៃការការពារស្របច្បាប់ បានសន្មតថាជាការការពារស្របច្បាប់តែម្តងដោយនៅក្នុងក្រមថ្មីនេះបានកំណត់ជាសច្ចធារណ៍នៃការការពារស្របច្បាប់ បានចែងថា ត្រូវសន្មតថាជាការការពារស្របច្បាប់នៅក្នុងករណីដូចតទៅៈ

- បទល្មើសត្រូវបានប្រព្រឹត្តដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការគាស់ទម្លុះទម្លាយដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ។
- បទល្មើសបានប្រព្រឹត្តដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា[19]។

គួរកត់សម្គាល់ លក្ខណៈនៃសច្ចាធារណ៍ៈ គឺគ្រាន់តែជាសច្ចាធារណ៍មួយធម្មតាប៉ុណ្ណោះ ដែលមិនមានចារីនៃការប្រឆាំងតបត្រឡប់មកវិញក្នុងការបង្ហាញឱ្យឃើញពីការការពារខ្លួន ដូច្នេះអយ្យការអាចបង្ហាញឱ្យឃើញភាពផ្ទុយរបស់វាវិញ។

---

[18] ព្រហ្មទណ្ឌបារាំង (២២ កក្កដា ២០១២),១២២ ។

[19] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៣៤។

សច្ចាធារណ៍ នៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ។ ហើយម្យ៉ាងវិញទៀតគ្រប់សកម្មភាព ដែលកើតមាន ដោយសច្ចាធារណ៍បែបនេះគឺអាចរំលាយទៅវិញបានដោយភស្តុតាងផ្ទុយ[20]។ បញ្ហានេះគឺទាក់ទង ហើយក្នុងករណីដែលច្បាប់សន្មតថាស្ថិតនៅក្នុងការការពារស្របច្បាប់ គឺបន្ទុកនៃភស្តុតាងត្រូវធ្លាក់ទៅលើស្ថាប័ន មានសមត្ថកិច្ចចោទប្រកាន់។ នៅក្នុងករណីទាំងពីរខាងលើនេះ បុគ្គលដែលជាចារីនៃបទល្មើស ត្រូវបានសន្មតថា ស្ថិតនៅក្នុងស្ថានភាពនៃការការពារស្របច្បាប់ ដូច្នេះបុគ្គលនោះពុំបាច់នាំយកនូវភស្តុតាងបញ្ជាក់ថា លក្ខខណ្ឌ នៃការការពារស្របច្បាប់នេះត្រូវបានបំពេញរួចរាល់ហើយនោះទេ ពីព្រោះថាការពារស្របច្បាប់នេះត្រូវបាន សន្មតថាត្រូវបានអនុវត្តត្រឹមត្រូវហើយ[21]។

## ផ្នែកទី២ ស្ថានភាពចាំបាច់

យោងតាមមាត្រា ៣៥ នៃក្រមព្រហ្មទណ្ឌកម្ពុជាបានចែងថា បុគ្គលដែលស្ថិតក្នុងការចាំបាច់ត្រូវតែប្រព្រឹត្ត បទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

ស្ថានភាពចាំបាច់ ជាករណីដែលមនុស្សម្នាក់ចង់គេចផុតពីគ្រោះអាសន្នជាក់ស្តែងមួយដែលកំពុងគំរាម កំហែងផលប្រយោជន៍របស់រដ្ឋ ផលប្រយោជន៍ស្របច្បាប់របស់ខ្លួន ឬរបស់អ្នកដទៃក្នុងកាលៈទេសៈដែលពុំមាន វិធីណាផ្សេង ក្រៅពីការធ្វើសកម្មភាព ដែលបង្កឱ្យមានការអន្តរាយមួយមានទំហំតូចជាងការអន្តរាយដែលត្រូវ ទប់ស្កាត់។ ការបង្កឱ្យមានការអន្តរាយ ក្នុងស្ថានភាពនេះពុំមែនជាបទល្មើសឡើយ[22]។ នៅចំពោះមុខស្ថានភាព មួយដែលទាមទារឱ្យមនុស្ស ត្រូវជំនះឱ្យបាននូវគ្រោះអាសន្ន ដែលកំពុងគំរាមកំហែងដល់បណ្តាផលប្រយោជន៍ ស្របច្បាប់ ហើយមានវិធីតែមួយគត់ គឺការបង្កឱ្យមានការអន្តរាយដល់ផលប្រយោជន៍ផ្សេងទៀតដែលក្រម ព្រហ្មទណ្ឌបានការពារ ហើយទំហំនៃការអន្តរាយត្រូវតែតូចជាងការអន្តរាយដែលគេបានទប់ស្កាត់[23]។ ជារួមស្ថាន ភាពចាំបាច់ គឺជាស្ថានភាពពិសេស ដែលមិនអាចខកខានបានដោយជៀសមិនផុតពីការប្រព្រឹត្តអ្វីមួយ[24]។ បុគ្គល ដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្ត មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌ ដូចខាងក្រោម៖

[20] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៣៤។

[21] សហប្រតិបត្តិការបារាំងគំពេងនីតិរដ្ឋ,មេរៀននីតិព្រហ្មទណ្ឌខ្មែរ ២០០៨,៣៧។

[22] សារណាបញ្ចប់ការសិក្សារបស់ លោក សុជា រស្មី និងលោក អៀង វណ្ណៈ (ឆ្នាំ២០១៦)

[23] ជួន ប៊ុនធី, នីតិព្រហ្មទណ្ឌទូទៅ។

[24] ទីស្តីការគណៈរដ្ឋមន្ត្រី, សន្ទានុក្រមច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០១១ ,៦៧។

- បទល្មើសត្រូវបានចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដ៏ទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង
- គ្មានសមាមាត្ររវាងមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់[25]។

បើគេប្រៀបធៀបកម្មវត្ថុ នៃការការពារនៅក្នុងស្ថានភាពចាំបាច់ គឺដូចគ្នាទៅនឹងករណីនៃការការពារស្របច្បាប់ បានន័យថាដូចទាំងការពារខ្លួន ដូចទាំងការពារអ្នកដ៏ទៃ និងដូចទាំងការពារទ្រព្យសម្បត្តិផងដែរ។

ប៉ុន្តែអ្វីដែលស្ថានភាពចាំបាច់ខុសគ្នាស្រលះពីការការពារស្របច្បាប់ គឺដោយសារចារីប្រឈមនឹងគ្រោះថ្នាក់មួយ ដែលមិនកើតចេញពីការឈ្លានពានមិនត្រឹមត្រូវនោះទេ។ ចំណែកឯនៅក្នុងការការពារស្របច្បាប់ គឺត្រូវតែមានការឈ្លានពានខុសច្បាប់ ឬកើតចេញពីការឈ្លានពានមួយដែលមិនត្រឹមត្រូវទេ។ រីឯនៅក្នុងស្ថានភាពចាំបាច់ គឺចារីស្ថិតនៅប្រឈមចំពោះគ្រោះថ្នាក់មួយ ដែលអាចកើតចេញដោយឯកឯង ក៏ប៉ុន្តែមិនមែនកើតចេញពីការឈ្លានពានមួយដែលមិនត្រឹមត្រូវឡើយ។ ចំណុចមួយទៀតនោះគឺថាស្ថានភាពចាំបាច់ខុសទៅនឹងអានុភាពនៃកម្លាំងបង្ខំ ឬការបង្ខំ ដោយសារតែនៅក្នុងស្ថានភាពចាំបាច់នេះ គឺចារីគាត់មានសេរីភាពនៅក្នុងជម្រើសរបស់ខ្លួនគាត់។ ចំណែកឯនៅក្នុងស្ថានភាពស្តីពីអានុភាពនៃកម្លាំង ឬការបង្ខំ គឺចារីគាត់មិនអាចទប់ទល់បានហើយ និងគ្មានជម្រើសនោះទេ។ ដូច្នេះហើយ នៅក្នុងស្ថានភាពចាំបាច់ គឺចារីគាត់មានសេរីភាពនៅក្នុងការប្រព្រឹត្ត ឬក៏មិនប្រព្រឹត្តទេ[26]។

ស្ថានភាពចាំបាច់ គឺជាស្ថានភាពរបស់បុគ្គលម្នាក់ដែលឈានទៅដល់ការប្រព្រឹត្តបទល្មើសណាមួយដោយសារតែមានបំណងចង់ស្តារនូវផលប្រយោជន៍មួយផ្សេងទៀត ដែលត្រូវបានគំរាមកំហែងដោយគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន។ ចំពោះស្ថានភាពចាំបាច់ ចារីមានជម្រើសពីរយ៉ាងគឺៈ

- ទទួលយកការខូចខាត ដែលនឹងត្រូវកើតមានឡើងដោយសុខចិត្តបដិសេធមិនព្រមប្រព្រឹត្តបទល្មើស។
- ត្រូវតែប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសការខូចខាត។

ស្ថានភាពចាំបាច់ធ្វើឱ្យកើតនូវវិវាទផលប្រយោជន៍ ដែលតម្រូវឱ្យបុគ្គលម្នាក់ជ្រើសរើសជាចាំបាច់ ដើម្បីការពារផលប្រយោជន៍ណាមួយដោយខានមិនបាន។ បើផ្អែកតាមសីលធម៌ចៅក្រម មានការលំបាកនឹងសម្រេចនូវការផ្តន្ទាទោសបុគ្គលណាម្នាក់ដែលសុខចិត្តជ្រើសរើសយកការប្រព្រឹត្តបទល្មើសដើម្បីបញ្ចៀសកុំឱ្យមានព្យសនកម្មធ្ងន់ធ្ងរកើតឡើង[27]។

[25] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៣៥។

[26] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ, (ភ្នំពេញៈអង្គរ, ២០១៣),២៥៤។

[27] សារណាបញ្ចប់ការសិក្សាឆ្នាំ២០២១ ស្តីមូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលទោសនូវការទទួលខុសត្រូវព្រហ្មទណ្ឌ ។

ដូច្នេះ ដើម្បីឱ្យមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនូវស្ថានភាពចាំបាច់នេះ អ្នកដែលបានប្រព្រឹត្តបទល្មើស (ចារី) ត្រូវតែបង្ហាញភស្តុតាងពីព្រឹត្តការណ៍នៃគ្រោះថ្នាក់នោះ ។

ស្ថានភាពចាំបាច់ស្ថិតនៅក្រោមលក្ខខណ្ឌមួយចំនួន លក្ខខណ្ឌនៃស្ថានភាពចាំបាច់ (១) ដើម្បីបង្កើតអានុភាពរបស់វា ។

## ១ លក្ខខណ្ឌនៃស្ថានភាពចាំបាច់

លក្ខខណ្ឌនៃស្ថានភាពចាំបាច់ ពីរត្រូវគ្នាដើម្បីបំពេញឱ្យស្ថានភាពចាំបាច់ ត្រូវបានបញ្ជាក់ៈ គ្រោះថ្នាក់ (១.១) ប្រតិកម្មចាំបាច់ សមាមាត្រការការពារបុគ្គល ឬទ្រព្យសម្បត្តិ (១.២)។

### ១.១ គ្រោះថ្នាក់

គ្រោះថ្នាក់ត្រូវតែមានលក្ខណៈ បច្ចុប្បន្ន ឬនឹងកើតឡើង(១.១.១) ភាពមិនស្របច្បាប់ (១.១.២)។

#### ១.១.១ បច្ចុប្បន្ន ឬនឹងកើតឡើង

ជាដំបូងជនប្រព្រឹត្តបទល្មើសដោយសារស្ថានភាពចាំបាច់ ត្រូវរកភស្តុតាងអំពីគ្រោះថ្នាក់ ដែលជំរុញឱ្យខ្លួនប្រព្រឹត្តបទល្មើស។ គ្រោះថ្នាក់នេះអាចជាគ្រោះថ្នាក់ដែលគំរាមកំហែងតតិយជន ឬមួយក៏គ្រាន់តែជាគំរាមកំហែងលើទ្រព្យសម្បត្តិណាមួយក៏បានដែរ[28]។

**ឧទាហរណ៍:** ដើម្បីកុំឱ្យសម្ភារះរបស់ខ្លួនត្រូវភ្លើងឆេះ បុរសម្នាក់បានចូលទៅផ្ទះអ្នកដទៃយកវត្ថុពន្លត់អគ្គិភ័យបាញ់ភ្លើងពន្លត់។ ក្នុងស្ថានភាពដែលកំពុងកើតឡើងចំពោះចារីផ្ទាល់បែបនេះ ចារីមិនត្រូវបានចាត់ទុកថាលួចទ្រព្យសម្បត្តិអ្នកដទៃឡើយ។ ដើម្បីជួយសង្គ្រោះជីវិតរបស់មនុស្សដែលកំពុងត្រូវភ្លើងឆេះដូចគ្នាបុរសម្នាក់បានចូលទៅក្នុងផ្ទះអ្នកដទៃ ដើម្បីលួចយកវត្ថុពន្លត់ភ្លើងបាញ់លើបុរសម្នាក់នោះ។ ករណីបែបនេះចារីបានចូលទៅក្នុងផ្ទះអ្នកដទៃដោយគ្មានការអនុញ្ញាត ប៉ុន្តែច្បាប់កំណត់ថាមិនខុសនោះឡើយ ព្រោះទង្វើរបស់ចារីស្តែងឱ្យឃើញពីការជួយអ្នកដទៃ។

គ្រោះថ្នាក់ត្រូវតែមានជាក់លាក់ មានន័យថា ជាគ្រោះថ្នាក់កំពុងមាន ឬដែលនឹងកើតមានយ៉ាងពិតប្រាកដមិនមែនគ្រោះថ្នាក់ជាយថាហេតុតាមការរើយវាយ ឬតាមការប៉ាន់ស្មានជាអត្តនោម័តរបស់ចារីឡើយ។

ហេតុដូច្នេះ ការវាយតម្លៃអំពីគ្រោះថ្នាក់ដែលនឹងកើតមានត្រូវធ្វើឡើងដោយលក្ខណៈសត្យានុម័ត មិនអាចទាញចេញពីការភ័យព្រួយបារម្ភរបស់ចារីតែម្នាក់ឯងបានឡើយ[29]។

---

[28] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២)២៧០។

[29] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២)២៧២។

**ឧទាហរណ៍:** បុរសម្នាក់បានលួចអាហារគេបរិភោគ ដោយអះអាងថាមកពីខ្លួនឃ្លាន។ ទង្វើនេះបានសម្តែងឱ្យឃើញពីចារីម្នាក់នោះ ដោយសារការលួចអាហាររបស់គេ។ បើសិនចារីពិតជាឃ្លានមែន គាត់អាចសុំគេដោយភាពសុចរិតទើបគ្មានកំហុស។

គ្រោះថ្នាក់ត្រូវតែមានលក្ខណៈបច្ចុប្បន្ន ឬនឹងកើតឡើង ឬជិតកើតឡើង ការជិតនឹងកើតមានឡើង មានន័យថាគ្រោះថ្នាក់អាច មិនទាន់កើតមាននៅឡើយ ប៉ុន្តែការលេចចេញរបស់វាអាចគេចមិនផុតនៅក្នុងរយៈពេលដល់ខ្លីបំផុត។

### ១.១.២ ភាពមិនស្របច្បាប់

លក្ខណៈមិនស្របច្បាប់នៃគ្រោះថ្នាក់ បញ្ចៀសមិនឱ្យស្វែងរកប្រភពដើមនៃគ្រោះថ្នាក់ មានយុត្តិសាស្ត្រជាប្រចាំដែលថាបុគ្គលម្នាក់ជាលក្ខណៈធន្ទះអាចនឹងស្ថិតនៅក្នុងស្ថានភាពមួយក្នុងការត្រូវតែប្រព្រឹត្តបទល្មើសមួយមិនអាចលើកឡើងបានពីស្ថានភាពចាំបាច់បានទេ ក្នុងនេះផងដែរ ចំពោះអំពើដែលខ្លួនបានប្រព្រឹត្តគឺមានលក្ខណៈខុសច្បាប់ ហើយមិនត្រូវបានការពារដោយច្បាប់នោះទេ ហេតុបុគ្គលដែលបានប្រព្រឹត្តបទល្មើសបែបនេះត្រូវទទួលខុសត្រូវនូវអំពើល្មើសរបស់ខ្លួន។

## ១.២ ប្រតិកម្មចាំបាច់ សមាមាត្រការការពារបុគ្គល ឬទ្រព្យសម្បត្តិ

ចារីត្រូវរកភស្តុតាងមកបញ្ជាក់ឱ្យឃើញថា បទល្មើសដែលខ្លួនបានប្រព្រឹត្តថាមានលក្ខណៈ សមាមាត្រទៅនឹងភាពធ្ងន់ធ្ងរនៃគ្រោះថ្នាក់។ ផលវិបាកនៃបទល្មើសត្រូវតែមានតម្លៃតិចជាង ឬស្មើនឹងតម្លៃដែលចារីមានបំណងចង់ស្រោចស្រង់សង្គ្រោះ។ ភាពសមាមាត្រនៃមធ្យោបាយការពារ និងទម្ងន់នៃគ្រោះថ្នាក់ត្រូវវាយតម្លៃទៅតាមស្ថានភាពនៃករណីនីមួយៗ[30] ។

**ឧទាហរណ៍:** បុរសម្នាក់បានសម្រេចចិត្តបើករថយន្តទៅបុកបង្គោលភ្លើង ដោយសារចង់គេចចេញពីក្មេងប្រុសម្នាក់ដែលរត់លើផ្លូវថ្នល់។ ករណីបែបនេះចារីមិនត្រូវបានចោទប្រកាន់ថា បំផ្លាញទ្រព្យសម្បត្តិសាធារណៈឡើយ។ គេសង្កេតឃើញថា បើបុរសម្នាក់នោះមិនបើកបុកបង្គោលភ្លើងទេ ជីវិតក្មេងអាចនឹងបាត់បង់ដោយសារឡានរបស់ខ្លួន។ ជាក់ស្តែងជីវិតមនុស្សថ្លៃជាងអ្វីៗទាំងអស់ ហេតុនេះគាត់ត្រូវតែរួចផុតពីការទទួលខុសត្រូវចំពោះទង្វើរបស់ខ្លួនយ៉ាងពិតប្រាកដ។

គួរកត់សម្គាល់ថាៈ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា បានចែងពីស្ថានភាពនេះផងដែរ។ យោងតាមមាត្រា៧៥៥ កថាខណ្ឌទី២ នៃក្រមរដ្ឋប្បវេណី បានកំណត់និយមន័យនៃស្ថានភាពចាំបាច់ថា អំពើដែល

[30] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២)២៧៤។

ស្ថានភាពចាំបាច់ សំដៅទៅលើអំពើរំលោភដែលពុំអាចចៀសវាងបាន ដើម្បីការពាររូបរាងកាយ ឬទ្រព្យសម្បត្តិរបស់ខ្លួន ឬអ្នកដទៃចំពោះគ្រោះថ្នាក់បច្ចុប្បន្ន ឬអច្ចាសន្ន[31] ហើយដែលស្ថិតក្នុងតុល្យភាពរវាងវិធីការពារ និងកម្រិតគ្រោះថ្នាក់នោះ[32]។ យោងតាមខ្លឹមសារនៃបញ្ញត្តិនេះ ស្ថានភាពចាំបាច់តាមក្រមរដ្ឋប្បវេណីកម្ពុជា មិនខុសពីស្ថានភាពចាំបាច់តាមក្រមព្រហ្មទណ្ឌឡើយ។ យោងតាមមាត្រា៧៥៦ ដោយស្ថានភាពចាំបាច់ កថាខណ្ឌទី២នៃក្រមរដ្ឋប្បវេណី ចំពោះការកើតមានឡើង ដោយស្ថានភាពចាំបាច់អ្នកដែលបានប្រព្រឹត្តបទល្មើសដោយសារស្ថានភាពចាំបាច់ពុំទទួលខុសត្រូវឡើយ។ ក្នុងករណីនេះ បុគ្គលដែលបានប្រព្រឹត្តអំពើផ្ទុយច្បាប់ដែលជាមូលហេតុនៃអំពើនោះត្រូវទទួលខុសត្រូវ។ ហេតុដូច្នេះតាមក្រមរដ្ឋប្បវេណីនៃព្រះរាជាណាក្រកម្ពុជា បុគ្គលដែលបានប្រព្រឹត្តបទល្មើសដោយសារស្ថានភាពចាំបាច់ មិនទទួលខុសត្រូវក្នុងការសងការខូចខាតឡើយ ក៏ប៉ុន្តែជនដែលបានបង្កឱ្យមានការប្រព្រឹត្តបទល្មើស គឺជាអ្នកទទួលខុសត្រូវទៅវិញ[33]។ ចាំបាច់ បទល្មើសដែលប្រព្រឹត្តត្រូវតែជាមធ្យោបាយដល់ប្រសើរបំផុត ក្នុងការបញ្ចៀសគ្រោះភ័យ។

គួរគត់សម្គាល់ (ភាពចាំបាច់នៃវិជ្ជាជីវៈ ញឹកញាប់ខ្លាំងណាស់ ភាពចាំបាច់នៃវិជ្ជាជីវៈមិនបញ្ជាក់បានពីការប្រព្រឹត្តនៃបទល្មើសមួយនោះទេ)។

**ឧទាហរណ៍:** ប្រធានសហគ្រាសមួយដែលប្រព្រឹត្តបទល្មើសទៅនឹងការតាំងបទបញ្ជាស្តីអំពីអនាម័យ ឬសន្តិសុខ របស់អ្នកធ្វើការ ដើម្បីបញ្ចៀសចំពោះសហគ្រាសរបស់ខ្លួននៅចំណាយធំដុំ មិនអាចលើកឡើងនៅស្ថានភាពចាំបាច់ប្រកបដោយសុពលភាពនោះទេ។

ប្រតិកម្មត្រូវសមាមាត្រ ដើម្បីកំណត់ថាមាន ឬមិនមានសមាមាត្រភាគ ត្រូវពិនិត្យឡើងវិញឲ្យឃើញថាគ្រោះថ្នាក់ ជាហេតុបណ្តាលឱ្យមានផលពិបាកមួយចំនួន គួរឱ្យសង្ស័យជាងផលវិបាក ដែលកើតចេញពីបទល្មើសដែលបានប្រព្រឹត្ត។ ពោល គឺផលប្រយោជន៍ដែលរក្សាបាន ត្រូវតែជាតម្លៃខ្ពស់ជាង ឬស្មើទៅនឹងផលប្រយោជន៍ដែលលះបង់។

កត់សម្គាល់: ស្ថានភាពចាំបាច់មិនអាចទទួលយកបានកាលណាគ្រោះភ័យដែលចំពោះនេះ ជនល្មើសចង់គេចដោយប្រព្រឹត្តនៅបទល្មើសដែលមានប្រភពដើមចេញពីកំហុសរបស់ខ្លួនឯងផ្ទាល់។

[31] អច្ចាសន្ន មានន័យថា គ្រោះថ្នាក់ដែលរៀបនិងកើតឡើងយ៉ាងពិតប្រាកដ។

[32] ក្រមរដ្ឋប្បវេណី,លេខ នស/រកម/១២០៧/០៣០,០៨ ធ្នូ ២០០៧, មាត្រា៧៥៥ កថាខណ្ឌទី២។

[33] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២)២៧៥។

អានុភាពនៃស្ថានភាពចាំបាច់ ប្រសិនបើគ្រប់លក្ខខណ្ឌទាំងអស់ត្រូវបានប្រមូលផ្តុំ ស្ថានភាពចាំបាច់បញ្ជាក់បានអំពើការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់បុគ្គលដែលទទួលផលពីនេះ ផ្ទុយទៅនឹងការការពារខ្លួនស្របច្បាប់ស្ថានភាពចាំបាច់មិនធ្វើឱ្យលេចបាត់នូវការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីទេ។

## ផ្នែកទី៣ បង្គាប់របស់អាជ្ញាធរស្របច្បាប់

មាត្រា៣២ កថាខណ្ឌ១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងថា បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្តិឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។ បុគ្គលណាដែលប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់[34]។

តាមអត្ថន័យខាងលើនេះ ក្រមព្រហ្មទណ្ឌថ្មីបានបង្ហាញពីអំពើដែលត្រូវបានបញ្ញត្តិថាជាបទល្មើស តែបែរជាមិនមែនបទល្មើសទៅវិញ គឺដោយមូលហេតុថាអំពើនោះត្រូវបានអនុញ្ញាតដោយច្បាប់ និងមានការអនុញ្ញាតពីអាជ្ញាធរ។

**ឧទាហរណ៍:** បុគ្គលដែលបំពេញកិច្ចមួយដែលបញ្ជាដោយអាជ្ញាធរស្របច្បាប់ មិនទទួលខុសត្រូវខាងព្រហ្មទណ្ឌនោះទេ លើកលែងតែកិច្ចនេះ បញ្ជាក់ឱ្យឃើញថាខុសច្បាប់យ៉ាងជាក់ក្រឡែកប៉ុណ្ណោះ។ ការបង្គាប់បញ្ជារបស់អាជ្ញាធរស្របច្បាប់ផ្អែកលើគំនិតនៃការស្ថិតនៅក្រោមបង្គាប់នឹងផ្អែកលើសញ្ញាណនៃការធ្វើជាអាជ្ញាកណ្តាលដោយសេរី។ ការបញ្ជាដែលត្រូវបានបញ្ជាដោយអាជ្ញាធរសាធារណៈ (១) ហើយមិនត្រូវខុសច្បាប់ជាក់ស្តែងនោះទេ ឬការផាតចេញនៃការបញ្ជាខុសច្បាប់ជាក់ស្តែង (២)។

### ១ ការបញ្ជាដោយអាជ្ញាធរសាធារណៈ

ការបញ្ជាដោយអាជ្ញាធរសាធារណៈ ឬអាជ្ញាធរស្របច្បាប់ គឺជាអ្នកទ្រទ្រង់នូវអាជ្ញា អ្នកកាន់អំណាចតាមសិទ្ធិដែលខ្លួនទទួលបានពេញលេញ។ ក្នុងន័យនេះ គេអាចឱ្យនិយមន័យអាជ្ញាធរសាធារណៈ គឺសំដៅលើអាជ្ញាធរសាធារណៈ ដែលអាចជាអាជ្ញាធររដ្ឋបាល អាជ្ញាធរតុលាការ ឬអាជ្ញាធរយោធា ដែលមានអំណាចតាមផ្លូវច្បាប់ក្នុងការបញ្ជាឱ្យអនុវត្តច្បាប់ និងលិខិតបទដ្ឋានផ្សេងៗទៀត។ ហេតុនេះមិនត្រូវចាត់ទុកជាបញ្ជាដោយអាជ្ញាធរសាធារណៈ ឬអាជ្ញាធរស្របច្បាប់ តាមន័យមាត្រា ៣២ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឡើយចំពោះ៖ និយោជកនៃក្រុមហ៊ុនមួយ(បញ្ជាឱ្យនិយោជិតធ្វើអ្វីមួយដែលខុសត្រូវច្បាប់) ឬឪពុកម្តាយ (បញ្ជាឱ្យកូនធ្វើអ្វីមួយដែលផ្ទុយនឹងច្បាប់)។

[34] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៣២ កថាខណ្ឌទី១។

**ឧទាហរណ៍:**

១.និយោជិកដែលបង្កើតនូវវិក័យបត្រក្លែងក្លាយតាមបញ្ជារបស់និយោជករបស់ខ្លួន មិនអាចទទួលបានពីការបង្គាប់បញ្ជារបស់អាជ្ញាធរស្របច្បាប់នោះទេ។

២.បេឡាកានី ដែលប្តឹងទំនាស់ទៅនឹងអតិថិជនម្នាក់ ពីបទលួចតាមបញ្ជារបស់ថ្នាក់លើរបស់ខ្លួន ហើយបន្ទាប់មកទៀតត្រូវបាន ចោទប្រកាន់ពីការប្រាប់ពីព័ត៌មានកុហក មិនអាចទទួលផលពីការបង្គាប់បញ្ជារបស់អាជ្ញាធរស្របច្បាប់នោះទេ។ ម្យ៉ាងទៀតអាជ្ញាធរនេះ ត្រូវតែមានសញ្ញាតិបារាំង ជាអ្វីដែលផាតចេញពីបង្គាប់បញ្ជាដែលធ្វើអាជ្ញាធរបរទេស[35]។

## ២ ការផាតចេញនៃការបញ្ជាខុសច្បាប់ជាក់ស្តែង

តាមមាត្រា៣២ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌកម្ពុជា មិនអនុញ្ញាតឱ្យជនដែលប្រព្រឹត្តបទល្មើសតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ រួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប្រសិនបើអំពើនោះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់។ ចំពោះពាក្យថាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ទាមទារឱ្យមានការវាយតម្លៃទៅតាមករណីនីមួយៗ។ ដោយត្រូវពិនិត្យទៅលើស្ថានភាពជាក់ស្តែងរបស់អ្នកទទួលបញ្ជាដូចជា សមត្ថភាព បទពិសោធន៍ និងឋានៈជាដើម។ ដូច្នេះ មន្ត្រីរាជការថ្នាក់ខ្ពស់មានសមត្ថភាពអាចវាយតម្លៃកំណត់ពីភាពស្របច្បាប់ ឬមិនស្របច្បាប់នៃបញ្ជាណាមួយរបស់ថ្នាក់លើខ្លួនជាងមន្ត្រីធម្មតា ឬជនសាមញ្ញដែលអាជ្ញាធរបញ្ជាឱ្យធ្វើអ្វីមួយ[36]។

ការប្រើពាក្យថា អំពើខុសច្បាប់យ៉ាងជាក់ច្បាស់ នាំឱ្យសន្និដ្ឋានបានថាប្រសិនបើអំពើដែលប្រព្រឹត្តគ្រាន់តែជាអំពើខុសច្បាប់ ប៉ុន្តែមិនមែនជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ទេ អ្នកទទួលបញ្ជាអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានដោយផ្អែកលើមាត្រា៣២ នៃព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០០៩[37]។

លក្ខណៈជាក់ស្តែងខុសច្បាប់នៃបញ្ជា អាចឱ្យចាត់ទុកជាការបញ្ជានេះខុសច្បាប់ប៉ុណ្ណោះ ប៉ុន្តែមិនមែនខុសច្បាប់ជាក់ស្តែងនោះទេ អាចចូលទៅក្នុងដែនអនុវត្តនៃការបង្គាប់បញ្ជារបស់អាជ្ញាធរស្របច្បាប់។

**ឧទាហរណ៍:** ខណៈពេលកំពុងធ្វើដំណើរលើដងវិថីមួយកន្លែង បុរសម្នាក់ត្រូវបាននគរបាលចរាចរណ៍បញ្ជាឱ្យបើកម៉ូតូទៅមុខត្រង់ស្របពេលភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម។ គេដឹងហើយថាភ្លើងសញ្ញាចរាចរណ៍ពណ៌ក្រហម គឺជាសញ្ញាឱ្យអ្នកបើកបរត្រូវតែឈប់សិនទម្រាំភ្លើងបៃតងមកដល់ទើបអាចធ្វើដំណើរទៅមុខបាន។ ប៉ុន្តែដោយសារតែបុរសម្នាក់នេះទទួលបានការអនុញ្ញាតពីនគរបាលចរាចរណ៍ ដែលជាអាជ្ញាធរស្របច្បាប់នោះ គាត់នឹងមិនត្រូវបានចោទថាល្មើសនឹងច្បាប់ចរាចរណ៍ឡើយ បើទោះបីជាគាត់បើកបរក្នុងពេលភ្លើងសញ្ញាចរាចរណ៍ ពណ៌ក្រហមក៏ដោយ។

---

[35] ព្រហ្មទណ្ឌបារាំង (២២ កក្កដា ២០១២),១២២ ។

[36] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),។

[37] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៣២។

លក្ខណៈខុសច្បាប់ជាក់ស្តែងនេះ ការវាយតម្លៃជាវត្ថុវិស័យនៃលក្ខណៈខុសច្បាប់ជាក់ស្តែង (២.១) ការវាយតម្លៃជាអត្តវិស័យនៃលក្ខណៈខុសច្បាប់ជាក់ស្តែង (២.២)។

## ២.១ ការវាយតម្លៃជាវត្ថុវិស័យនៃលក្ខណៈខុសច្បាប់ជាក់ស្តែង

ការវាយតម្លៃវត្ថុវិស័យតម្រូវឱ្យពិនិត្យនៃបទល្មើស ដែលបញ្ជាមកអាចទាញចេញពីនេះ គឺថាការប៉ះពាល់ទៅនឹងជីវិត ឬទៅនឹងបូរណភាពរូបកាយរបស់អ្នកដទៃ គឺជាការបញ្ជាមួយខុសច្បាប់យ៉ាងជាក់ស្តែង ការបញ្ជាខុសច្បាប់យ៉ាងជាក់ស្តែង កាលណាវាជាបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាមមិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ផ្ទុយទៅវិញការវាយតម្លៃមានលក្ខណៈស្មុកស្មាញជាងខាង ការប៉ះពាល់ដល់សិទ្ធិកម្មសិទ្ធ ឬសិទ្ធិបុគ្គលភាព ពីព្រោះកាលប៉ះពាល់ទាំងនេះជូនកាលអាចមានសភាពខាងក្រៅនៃភាពស្របច្បាប់។ ការវាយតម្លៃអត្តវិស័យវិញមានលក្ខណៈសមស្របជាង។

## ២.២ ការវាយតម្លៃជាអត្តវិស័យនៃលក្ខណៈខុសច្បាប់ជាក់ស្តែង

ការវាយតម្លៃអត្តវិស័យ នាំទៅដល់ការធ្វើឲ្យខ្លួនឯង មានការឃើតយ៉ាវទៅលើឋានៈរបស់ភ្នាក់ងារ។ ចៅក្រមនឹងធ្វើការញែកឲ្យដាច់គ្នាទៅតាមអ្វីដែលជាប្រជាពលរដ្ឋធម្មតាម្នាក់ ឬជាមន្ត្រីម្នាក់ ចៅក្រមក៏នឹងពិចារណាផងដែរ ពីទីកន្លែងក្នុង ឋាណានុក្រម នឹងចំណេះដឹងផ្នែកច្បាប់របស់ជនល្មើស។

**ឧទាហរណ៍:** រដ្ឋលេខាជាន់ខ្ពស់ម្នាក់ អាចនឹងពិបាកថាខ្លួនប៉ុនប៉ង មិនដឹងអំពីលក្ខណៈខុសច្បាប់យ៉ាងជាក់ស្តែងនៃបញ្ជានោះទេ ដូច្នេះមិនអាចទទួលបានការបង្គាប់បញ្ជារបស់អាជ្ញាធរស្របច្បាប់ មន្ត្រីរដ្ឋលេខាជាន់ខ្ពស់ដែលធ្វើឲ្យគេចាប់យកលិខិតឆ្លងឆ្លើយឯកជនទៅតាមបញ្ជារបស់អភិបាលខេត្ត។

## ផ្នែកទី៤ ការបញ្ជា ឬការអនុញ្ញាតនៃច្បាប់

មាត្រា៣២ កថាខណ្ឌ១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងថា បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្តិ ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។ បុគ្គលណាដែលប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់[38]។

ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឬ បទឧក្រិដ្ឋសង្គ្រាមមិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ៖

១.ជនល្មើសដែលបានប្រព្រឹត្តអំពើដែលបញ្ញត្តិ ឬមិនហាមឃាត់ជនល្មើសនោះដោយច្បាប់អនុញ្ញាតធរមាន។

[38] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៣២ កថាខណ្ឌទី១។

២. បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់[39]។

**ឧទាហរណ៍:** ទោះបីជាច្បាប់ជាធរមាននៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យអនុញ្ញាតឱ្យមានការសម្លាប់មនុស្សក៏ដោយ ក៏អំពើនោះត្រូវបានចាត់ទុកជា បទឧក្រិដ្ឋប្រល័យពូជសាសន៍[40] បទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ[41] បទឧក្រិដ្ឋសង្គ្រាម[42] ដូច្នេះ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតមិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយទោះបីជនល្មើសបានប្រព្រឹត្តអំពើដែលច្បាប់នាសម័យនោះបានអនុញ្ញាត ឬច្បាប់មិនបានហាមឃាត់ក៏ដោយ។ ត្រូវញែកឲ្យដាច់គ្នាទៅតាមអំពើដែលបញ្ជានៃច្បាប់ ឬបទបញ្ជា(១) ឬដែលអនុញ្ញាតដោយច្បាប់ ឬដោយបទបញ្ជា (២)។

## ១ ការបញ្ជានៃច្បាប់ ឬបទបញ្ជា

ក្នុងមាត្រា៣២ វាក្យខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ចែងថា បុគ្គលណាដែលប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់លាក់។ អាចនិយាយបានថាជារឿងកើតឡើងពីច្បាប់ព្រហ្មទណ្ឌមួយចែងផ្ទុយទៅនឹងច្បាប់ព្រហ្មទណ្ឌមួយទៀត ហើយអនុញ្ញាតឲ្យប្រព្រឹត្តនូវអំពើល្មើស ដែលអាចជាបទល្មើសមួយក្នុងកាលៈទេសៈផ្សេងទៀត។

**ឧទាហរណ៍:** គ្រូពេទ្យត្រូវតែប្រកាន់ឲ្យបាននូវការសម្ងាត់នៃវិជ្ជាជីវៈ។ ក៏ប៉ុន្តែ គ្រូពេទ្យមិនប្រព្រឹត្តនូវបទល្មើសនោះទេ កាលណាគ្រូពេទ្យនោះប្រាប់ឲ្យដឹងពីការព្យាបាលមិនបានល្អដែលអ្នកជំងឺក្រោមអាយុ១៥ឆ្នាំអាចជាកម្មវត្ថុនោះ ពីព្រោះមាត្រា៤៣៤ ត្រេទី៣ នៃក្រមព្រហ្មទណ្ឌបារាំង ដាក់បន្ទុកជាកាតព្វកិច្ចដល់គ្រូពេទ្យប្រាប់ឲ្យដឹងពីការព្យាបាលបែបនេះដល់អ្នកជំងឺ។ ផងដែរ អ្នកប្រកបវិជ្ជាជីវៈម្នាក់ ឋិតនូវក្រោមបទ នៃការប្រយុទ្ធប្រឆាំងទៅនឹងការសម្អាតប្រាក់ នៃការផ្តល់ហិរញ្ញទាននៃភេរវកម្ម ដែលនឹងប្រាប់ឲ្យដឹងដល់អតិថិជនរបស់ខ្លួន នឹងទទួលផលពីបទបញ្ជា ដោយពុំមានការស្តីបន្ទោសថាជាការរំលោភនៃការសម្ងាត់នៃវិជ្ជាជីវៈនោះទេ។

## ២ ការអនុញ្ញាតដោយច្បាប់ ឬបទបញ្ជា

អនុញ្ញាត៖ មានន័យថាការយល់ព្រម ការបើកឱកាសឱ្យ ការផ្តល់ឱ្យនូវសិទ្ធិអ្វីមួយ។

[39] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៣២ កថាខណ្ឌទី២។

[40] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា១៨៣។

[41] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា១៨៤។

[42] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា១៩៣។

យោងតាមមាត្រា៣២ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌកម្ពុជា រាល់អំពើទាំងឡាយណាដែលកើតចេញពីការបំពេញកាតព្វកិច្ច ដែលតម្រូវដោយច្បាប់ ឬជាការអនុវត្តសិទ្ធិដែលច្បាប់បានបញ្ញត្តិ ឬអនុញ្ញាតឱ្យប្រព្រឹត្តអំពើនោះច្បាប់មិនបានបញ្ញត្តិឱ្យផ្តន្ទាទោសឡើយ។

**ឧទាហរណ៍:**

១.ការចាប់ខ្លួនជនសង្ស័យដែលធ្វើឡើងដោយមន្ត្រីនគរបាលយុត្តិធម៌ ចំពោះបទល្មើសជាក់ស្តែង។ ការចាប់ខ្លួនជនសង្ស័យស្ថានភាពជាក់ស្តែង[43] គឺត្រូវបានក្រមព្រហ្មទណ្ឌ កំណត់ពីអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមក្របខណ្ឌ នៃការស៊ើបអង្កេតករណីជាក់ស្តែង។

២.មេធាវីម្នាក់បានការពារក្តីឱ្យកូនក្តីរបស់ខ្លួន ដែលត្រូវបានចោទប្រកាន់ពីបទល្មើសបើកបរដោយធ្វេសប្រហេសបណ្តាលឱ្យរបួសធ្ងន់ដល់អ្នកដទៃ។ ក្នុងករណីនេះមេធាវីមិនត្រូវបានចាត់ទុកថាជាជនល្មើសឡើយ ព្រោះការការពារក្តីមួយនេះ ជាសិទ្ធិដែលច្បាប់បានផ្តល់ឱ្យមេធាវីក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួន ដើម្បីបម្រើផលប្រយោជន៍សាធារណៈ និងឯកជន។

គេអាចទៅយកក្រមនីតិវិធីព្រហ្មទណ្ឌ ត្រង់មាត្រា៨៧ មកពិនិត្យជាសំអាងព្រោះច្បាប់បានអនុញ្ញាតឱ្យប្រជាពលរដ្ឋមានសិទ្ធិចាប់ខ្លួនជនល្មើស នៅក្នុងករណីប្រព្រឹត្តិបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង ដើម្បីយកទៅប្រគល់ឱ្យនគរបាលយុត្តិធម៌ដែលនៅជិតបំផុត[44]។ ផ្ទុយទៅវិញនោះ ប្រសិនបើគ្មានច្បាប់ចែងយ៉ាងដូច្នេះ បែរជាប្រជាពលរដ្ឋ ឬនគរបាលយុត្តិធម៌ទៅចាប់ខ្លួនអ្នកដទៃដូចករណីខាងលើនេះ គឺជាការចាប់បង្ខាំងមនុស្សដោយខុសច្បាប់[45]។

ក្នុងមាត្រា៣២ វាក្យខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ បានចែងច្បាស់ថា បុគ្គលណាដែលប្រព្រឹត្តអំពើខុសច្បាប់ បានបញ្ញត្តិ ឬអនុញ្ញាតតាមច្បាប់បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ។ ដូច្នេះវាក៏ប្រែក្លាយជាអំពើស្របច្បាប់ទៅវិញដែលជាហេតុនាំឱ្យ អ្នកប្រព្រឹត្តអំពើមួយមិនទទួលខុសត្រូវព្រហ្មទណ្ឌអ្វីសោះឡើយ[46]។

**ឧទាហរណ៍:** នគរបាលយុត្តិធម៌ ឬប្រជាពលរដ្ឋប្រព្រឹត្តអំពើដែលត្រូវបានបញ្ញត្តិដោយច្បាប់ ដូចជាការទៅចាប់ខ្លួនជនល្មើស។ សកម្មភាពអាជ្ញាធរ ចុះរុះរើសំណង់អនាធិបតេយ្យដែលត្រូវបានសាងសង់ឡើងដោយខុសច្បាប់ជាដើម។

---

[43] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៨៥។

[44] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៨៧។

[45] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ, (ភ្នំពេញ៖អង្គរ, ២០១៣),២៤៣។

[46] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ, (ភ្នំពេញ៖អង្គរ, ២០១៣),២៤៣។

### ផ្នែកទី៥ អ្នកប្រកាសប្រាប់ពីភាពអាសន្ន

យោងតាមមាត្រា១២២ ត្រេ៩ នៃក្រមព្រហ្មទណ្ឌបារាំង អនុញ្ញាតចំពោះអ្វីដែលធ្វើឲ្យប៉ះពាល់ដល់ការសម្ងាត់មួយដែលត្រូវការពារដោយច្បាប់ កាលណាលក្ខខណ្ឌតទៅនេះត្រូវបានបំពេញៈ

- ការលាតត្រដាងចាំបាច់ និងសមាមាត្រទៅនឹងការការពារផលប្រយោជន៍មួយចំនួន ដែលចោទជាបញ្ហា
- ការលាតត្រដាងធ្វើឡើងក្នុងការគោរពនីតិវិធីនៃការប្រាប់ឲ្យដឹងមុននឹងកំណត់ដោយច្បាប់
- បុគ្គលដែលឆ្លើយទៅនឹងលក្ខណៈវិនិច្ឆ័យនៃនិយមន័យនៃអ្នកប្រាប់ឲ្យដឹងមុន[47]។

ទាក់ទងទៅនឹងលក្ខខណ្ឌចុងក្រោយនេះ មាត្រា៦ វាក្យខណ្ឌ១ នៃច្បាប់លេខ២០១៦-១៦៩១ នៃថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០១៦ ស្តីអំពីតម្លាភាពចំពោះការប្រយុទ្ធប្រឆាំងទៅនឹងអំពើពុករលួយ នឹងការធ្វើទំនើបកម្មនៃជីវភាពសេដ្ឋកិច្ចកំណត់អំពីការប្រាប់ឲ្យដឹងមុនថាជារូបវន្តបុគ្គលដែលលាតត្រដាង ឬប្រាប់ជាសញ្ញា ដោយមិនគិតអំពីផលប្រយោជន៍ និងដោយសុច្ចរិត នូវបទឧក្រិដ្ឋមួយ ឬបទមជ្ឈិមមួយ ការរំលោភមួយធ្ងន់ធ្ងរហើយបង្ហាញឲ្យឃើញពីការសន្យាជាអន្តរជាតិមួយ ដែលត្រូវបានផ្តល់សច្ចាប័ន ឬបានយល់ព្រមយ៉ាងត្រឹមត្រូវដោយប្រទេសបារាំង នៃកិច្ចឯកតោភាគីមួយ ឬអង្គការអន្តរជាតិមួយដែលបានធ្វើឡើង ដោយផ្អែកលើមូលដ្ឋាននៃការសន្យាបែបណាមួយនោះ នៃច្បាប់ ឬបទបញ្ញា ឬការគំរាមកំហែងមួយ ឬវិព្យណាសកម្មធ្ងន់ធ្ងរចំពោះផលប្រយោជន៍ទូទៅ ដែលខ្លួនបានដឹងជាលក្ខណៈបុគ្គល ។ វាក្យខណ្ឌទី២ នៃបញ្ញត្តិដដែលបានបញ្ជាក់ថាហេតុបញ្ជាក់ជាយុត្តិកម្មនៃមាត្រា១២២ ត្រេ៩ នៃក្រមព្រហ្មទណ្ឌបារាំង អាចត្រូវអនុវត្តចំពោះការរំលោភចំពោះការសម្ងាត់នៃការការពារជាតិ ការសម្ងាត់ពេទ្យ ឬការសម្ងាត់រវាងមេធាវីនឹងអតិថិជនរបស់ខ្លួន។ មាត្រា៨ និងមាត្រា៩ នៃច្បាប់ដែលបានកំណត់អំពីនីតិវិធីដែលបានប្រាប់ឲ្យដឹងមុន ដែលបញ្ជាក់ជាអាទិ៍ថាការប្រាប់ឲ្យដឹងមុន ជាបឋមត្រូវប្រាប់ឲ្យដឹងដល់ប្រធានឋានុក្រមខាងលើរបស់និយោជក ឬរបស់អ្នកដឹកនិយោជិកនេះ។

[47] ព្រហ្មទណ្ឌបារាំង (២២ កក្កដា ២០១២),១២២-៩ ។

# ជំពូកទី២

# បុព្វហេតុអត្តវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

## ជំពូកទី២ បុព្វហេតុអត្តវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុព្វហេតុអត្តវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ មានលក្ខណៈជាបុគ្គលរបស់ចារីតែម្តង។ បុព្វហេតុមានចំនួន០៤ ផ្នែកធំៗគឺ កំហុសនៃការយល់ដឹងដែលកើតចេញពីសតិមិនល្អ (១) ការបង្ខិតបង្ខំ (២) ការភាន់ច្រឡំនៃអង្គច្បាប់(៣)និងនីតិភាព (៤) ។

បុព្វហេតុអត្តវិស័យនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ធ្វើជាឧបសគ្គទៅការបង្កើតបទល្មើសព្រហ្មទណ្ឌ ពីព្រោះវារាំងពីការបញ្ជាក់លក្ខណៈជាតុចិត្តសាស្ត្រនៃបទល្មើស ហើយច្បាស់ជាងនេះទៅទៀតការដាក់បន្ទុក (ការមានសតិមិនល្អ បង្ខិតបង្ខំ ឬអនីតិភាព) ឬភាព (ភាន់ច្រឡំខាងអង្គច្បាប់)។ ដូចន្នេះ វាអាចសមហេតុសមផលក្នុងការសំដៅទៅលើបុព្វហេតុអត្តវិស័យមួយនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ នូវកម្រិតនៃការបញ្ជាក់លក្ខណៈ នៃជាតុចិត្តសាស្ត្រ។

### ផ្នែកទី១ កំហុសនៃការយល់ដឹងដែលកើតចេញអំពីសតិមិនល្អ

មាត្រា ៣១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ២០០៩ កថាខណ្ឌទី១ ចែងថា កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។[48] មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ចំពោះបុគ្គលដែលប៉ះពាល់កាយសម្បទាមិនល្អ ឬសតិមិនគ្រប់ ដែលបានលុបចោលនៅការយល់ដឹងរបស់ខ្លួន ឬការត្រួតពិនិត្យនៃអំពើល្មើសរបស់ខ្លួន។

មាត្រានេះចែងផងដែរពីស្ថានភាពនៅក្នុងនេះ ការរំខានទាំងនេះមិនបានលុបត្រឹមតែសតិមិនគ្រប់ ការយល់ដឹងរបស់ជនជាប់នៅពេលកើតហេតុនេះទេ។ លក្ខខណ្ឌមួយចំនួន កំណត់ក្របខណ្ឌពីការទទួលខុសត្រូវព្រហ្មទណ្ឌដោយហេតុនៃកំហុសនៃការយល់ដឹង (១) ពីព្រោះវាបង្កើតនៅអានុភាពរបស់វា (២)។

### ១ លក្ខខណ្ឌ

កំហុសនៃការយល់ដឹង ដែលកើតចេញពីអំពីសតិមិនល្អ មានលក្ខខណ្ឌពីរត្រួតគ្នា កំណត់ក្របខណ្ឌនៃការទទួលខុសត្រូវព្រហ្មទណ្ឌ នូវកំហុសក្នុងការយល់ដឹងៈ លក្ខខណ្ឌសម្ភារៈ (១.១) លក្ខខណ្ឌពេលវេលា (១.២)។

#### ១.១ លក្ខខណ្ឌសម្ភារៈ

កាយសម្បទាមិនគ្រប់គ្រាន់ ឬសតិមិនល្អ (ឡប់សតិ) អាចៈ

១ គ្រប់ទម្រង់ទាំងអស់ មានន័យថាទាំងកាយសប្បទាំមិនគ្រប់គ្រាន់ហើយ សតិមិនល្អ គ្មានការយល់ដឹង ប្រសិនបើប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

២ គ្រប់ប្រភេទទាំងអស់ តែកើតឡើងដោយសារតែជំម្ងឺ ឬគ្មានជម្ងឺ។

[48] ក្រមព្រហ្មទណ្ឌកម្ពុជា,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩,មាត្រា៣១, កថាខណ្ឌទី១។

៣ គ្រប់ប្រភពទាំងអស់ មានតាំងពីកំណើត ឬដោយសារគ្រោះថ្នាក់អ្វីមួយ។

ការមិនគ្រប់ទឹកអាចជាលទ្ធផលនៃមានក្នុងឈាម (សារជាតុញៀន ឬជាតិស្រវឹង) ការមានគ្រឿងញៀននៅក្នុងខ្លួនមិនមានជាហេតុរបស់ជនជាប់ចោទខ្លួនឯងផ្ទាល់នោះទេ ។

ក្នុងករណីបែបនេះ ប្រសិនបើមានផ្ទុកនៅសារជាតុញៀន ឬជាតិស្រា អាចជាអចិន្ត្រៃយ៍ ឬម្តងម្កាល់ ប្រសិនបើប្រព្រឹត្តបទល្មើសនោះ គេត្រូវពិនិត្យមើលទៅលើស្ថានភាពជាក់ស្តែង បើកើតឡើងដោយសារបែបនេះ មិនធ្វើឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌទេ។

**ឧទាហរណ៍:**

១.បុរសម្នាក់មានជំងឺឆ្កួតជ្រូក ដូច្នេះបុរសម្នាក់នោះ គឺជាការមិនគ្រប់ទឹកម្តងម្កាល់ មានន័យអាចយល់ដឹងផង និងមិនយល់ដឹង អំពើសកម្មភាពរបស់បានប្រព្រឹត្តដែលជាបទល្មើសថាខុសខ្លួនបានធ្វើ ឬក៏ត្រូវនោះទេ ។

២.ចំពោះបុគ្គលខ្លះអាចថាគាត់ជំងឺប្រចាំកាយឬមិនមាន ដូច្នេះហើយនៅពេលដែលគាត់ប្រព្រឹត្តបទល្មើសនោះ ក្នុងករណីបែបនេះត្រូវតែពិនិត្យរកឱ្យឃើញថានៅពេលដែលបទល្មើសបានកើតឡើងសួរថា គាត់មានការយល់ដឹង ឬក៏គ្មានការយល់ដឹងដោយសារជំងឺនោះ។

អ្វីដែលសំខាន់ត្រូវដឹងថាការមិនគ្រប់ទឹកនេះគឺជា ការលុបចោលនៃការយល់ដឹង (១.១.១) ឬការធ្វើឲ្យចុះខ្សោយនូវយល់ដឹងរបស់ជនជាប់ចោទ(១.១.២) និងជនដែលមានវិល្លសស្មារតីដោយសារការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន(១.១.៣)។

**១.១.១ ការលុបចោលនៃការយល់ដឹង**

តាមមាត្រា៣១ កថាខណ្ឌទី១ កំណត់ថា កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ផ្អែកតាមស្មារតីមាត្រានេះ ជនកើតវិបល្លាសស្មារតី ត្រូវរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌទាំងស្រុង។

ដើម្បីឱ្យរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ គេត្រូវតែរកភស្តុតាងមកបញ្ជាក់អំពីអត្ថិភាពនៃវិបល្លាសស្មារតីដែលចារីមាននៅពេលប្រព្រឹត្តបទល្មើស។ ភស្តុតាងនេះត្រូវតែរកឱ្យបាន ពោលគឺ មានការសន្មត់ថាជនស្ថិតនៅក្រោមអាណាព្យាបាលទូទៅក៏ដោយ ។ ប៉ុន្តែយោបល់ទាំងនេះពុំមានអានុភាពចងជាកាតព្វកិច្ចឱ្យចៅក្រមត្រូវតែជឿតាមនោះទេ មានន័យថាចៅក្រមអាចជឿក៏បាន ចៅក្រមអាចមិនជឿក៏បានដែរ តាមឆន្ទានុសិទ្ធិរបស់គាត់[49]។

នៅក្នុងច្បាប់ពាក្យថាវិបល្លាសស្មារតី គឺសំដៅទៅលើអ្នកដែលមានសតិបញ្ញាស្មារតីមិនប្រក្រតី ហើយគេអាចហៅថាជាជនវិកលចរិត ឬហៅថាមនុស្សឆ្កួតស៊ប់[50]។ ដូច្នេះស្ថានភាពស្មារតីនេះ បើសិនគាត់ស្ថិតនៅក្រោម

[49] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៣៩។

[50] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ អង្គារ,២០១៣០,២៣៧។

របបអាណាព្យាបាលទូទៅបានន័យថា ជាមនុស្សវិកលចរិត ឬជាមនុស្សឆ្កួតស៊ប់ ដែលបាត់បង់នូវការដឹងខុសត្រូវទាំងស្រុង ឬក៏ជានិរន្តរ៍នោះបានទៅប្រព្រឹត្តបទល្មើស មនុស្សប្រភេទនេះនឹងរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ[51]។

**ឧទាហរណ៍ ៖** មានបុរស ក ម្នាក់ត្រូវបានជនវិកលចរិតយកដំបងវាយទៅលើក្បាលរបស់លោក ខ យ៉ាងពេញទំហឹងបណ្តាល ឱ្យមានរបួសយ៉ាងធ្ងន់ធ្ងរ។ ករណីនេះ ជនវិកលចរិតនោះ នឹងមិនត្រូវបានផ្តន្ទាទោសព្រហ្មទណ្ឌឡើយ។ បើសិនជាមានភស្តុតាងបញ្ជាក់ ថាគាត់ពិតជាគ្មានសមត្ថភាព ក្នុងការយល់ដឹងខុសត្រូវ និងវិនិច្ឆ័យអំពីអំពើរបស់ខ្លួនដែលបានប្រព្រឹត្តនោះ ។

**១.១.២ ការធ្វើឲ្យចុះខ្សោយនៃការយល់ដឹង**

វិបល្លាសស្មារតី ដែលជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវតែជាវិបល្លាសដែលបានបាត់បង់ទាំងស្រុងនូវសមត្ថភាពក្នុងការយល់ដឹងរបស់ចារី (លទ្ធភាពក្នុងការយល់ដឹងខុសត្រូវនៃអំពើដែលខ្លួនបានប្រព្រឹត្ត) ឬបាត់បង់ទាំងស្រុងនូវសមត្ថភាពក្នុងការត្រួតពិនិត្យសកម្មភាពរបស់ខ្លួន។ ប្រសិនបើចារីមានវិបល្លាសស្មារតី ដែលត្រឹមតែបន្ថយនូវការដឹងខុសត្រូវរបស់គាត់តែប៉ុណ្ណោះ គាត់នៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ក៏ប៉ុន្តែស្ថានភាពនេះ អាចក្លាយជាស្ថានភាពសម្រាលទោសសម្រាប់ចារីបាន[52]។

លើសពីនេះទៅទៀត បើគេយោងតាមសៀវភៅនីតិព្រហ្មទណ្ឌទូទៅ របស់លោក **កៅ សីហា** ផ្តល់គំនិតបន្ថែមថាប្រសិនបើក្នុងករណីដែលជនវិបល្លាសស្មារតីណាម្នាក់បានប្រព្រឹត្តបទល្មើស ដោយបាត់បង់នូវការទទួលខុសត្រូវត្រឹមតែមួយផ្នែក គឺគាត់នៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ ប៉ុន្តែនៅពេលដែលតុលាការសម្រេចផ្តន្ទាទោស គេនឹងពិនិត្យអំពីស្ថានភាព ដែលគាត់បានប្រព្រឹត្តបទល្មើសនោះ ដោយសារតែគាត់មិនបានបាត់បង់នូវការយល់ដឹងទាំងស្រុងនោះទេ គឺគ្រាន់តែបន្ថយនូវការយល់ដឹងតែប៉ុណ្ណោះ ដូច្នេះគាត់នៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល[53]។

ជាក់ស្តែង នៅក្នុងមាត្រា ៣១ នៃក្រមព្រហ្មទណ្ឌកម្ពុជា កថាខណ្ឌទី២ ចែងថា កាលណាបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការយល់ដឹងរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល។ ប៉ុន្តែតុលាការត្រូវគិតគូរបញ្ហានេះ កាលណាតុលាការកំណត់ទោស [54] ។ ផ្អែកតាមស្មារតីមាត្រានេះ បុគ្គលបានប្រព្រឹត្តបទល្មើសស្របពេលដែលបុគ្គលនោះស្ថិតនៅក្នុងស្ថានភាពដូចខាងលើ គេមិនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ តែអាចទទួលបានស្ថានសម្រាលពីច្បាប់។

---

[51] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ អង្គរ,២០១៣០,២៣៧។

[52] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៣៩។

[53] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញ៖ អង្គរ,២០១៣០,២៣៨។

[54] ក្រមព្រហ្មទណ្ឌកម្ពុជា,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩,មាត្រា៣១, កថាខណ្ឌទី២។

បើយោងតាមសៀវភៅមេរៀននីតិព្រហ្មទណ្ឌខ្មែរ ដែលត្រូវបានរៀបចំឡើងដោយសហប្រតិបត្តិការបារាំងគម្រោងទ្រទ្រង់នីតិរដ្ឋ បញ្ជាក់ថាមាត្រា៣១ កថាខណ្ឌ២ នៃក្រមព្រហ្មទណ្ឌកម្ពុជា សំដៅលើជនម្នាក់កើតវិបល្លាសស្មារតី នៅពេលប្រព្រឹត្តបទល្មើស ប៉ុន្តែកម្លាំងនៃវិបល្លាសនេះ ពុំមានលក្ខណៈលុបបំបាត់ទាំងស្រុងនូវសមត្ថភាពក្នុងការយល់ដឹងខុសត្រូវទេពោលកម្លាំងនៃវិបល្លាសនេះ គ្រាន់តែត្រូវបានកាត់បន្ថយតែប៉ុណ្ណោះ[55]។ ដូច្នេះករណីនេះ មិនមែនជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ប៉ុន្តែជាមូលហេតុនៃការបន្ថយការទទួលខុសត្រូវព្រហ្មទណ្ឌ ពីព្រោះថាបុគ្គលនោះត្រូវបានជំនុំជម្រះដោយតុលាការ ត្រូវតែលើកយកមកពិចារណានូវស្ថានភាពនេះដើម្បីកំណត់ទោស។

នៅក្នុងការអនុវត្តជាក់ស្តែង ការបន្ថយនូវការយល់ដឹងខុសត្រូវ អនុញ្ញាតឱ្យបន្ថយទោសបាន។ ទស្សនៈនៃបទបញ្ញត្តិនេះ គឺច្បាស់លាស់ណាស់ បទល្មើសតម្រូវឱ្យមានចេតនាធ្វើសកម្មភាព ហើយថែមទាំងភាពដែលអាចទម្លាក់កំហុសបាន មានន័យថាលទ្ធភាពដែលអាចត្រូវបានគេស្តីបន្ទោស។ ប៉ុន្តែជនណាដែលមានវិកលចរិតអាចមានបំណងប្រព្រឹត្តបទល្មើស ដោយពុំមានលទ្ធភាពក្នុងការយល់ដឹងពិតប្រាកដនូវផលវិបាក នៃសកម្មភាពដែលខ្លួននឹងប្រព្រឹត្ត ជននោះពុំមានស្មារតីពិតប្រាកដមែន។ ប្រសិនបើពុំមានភាពដែលពុំអាចទម្លាក់កំហុសបាននោះ ជាធម្មតាការទទួលខុសត្រូវខាងព្រហ្មទណ្ឌ ត្រូវបានច្រានចេញ[56]។

**១.១.៣ ជនដែលមានវិល្លាសស្មារតីដោយសារការប្រើប្រាស់គ្រឿងស្រវឹង ឬគ្រឿងញៀន**

ផ្អែកតាមស្មារតីនៃក្រមព្រហ្មទណ្ឌ បុគ្គលម្នាក់ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ស្របពេលដែលខ្លួនស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬគ្រឿងញៀន គេមិនអាចចាត់ទុកថាបុគ្គលនោះមានវិបល្លាសស្មារតីឡើយពោល គឺជននោះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌដោយមិនអាចលើកលែងបានឡើយ[57]។

បើយោងទៅតាមមាត្រា ៣១ កថាខណ្ឌ៣ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងថាកាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ។

វិបល្លាសស្មារតីដែលកើតចេញពីការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន និងថ្នាំដែលច្បាប់ហាមឃាត់ច្រើនតែកើតចេញពីឆន្ទៈផ្ទាល់របស់ចារីតែម្តង ហើយក៏មិនអាចចាត់ទុកថាជាមូលហេតុដែលនាំឱ្យជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌផងដែរ។

**ឧទាហរណ៍:**

១ មានបុរសម្នាក់បានបើកបររថយន្ត ក្នុងស្ថានភាពស្រវឹងជោគជាំ និងបាត់បង់ស្មារតីក្នុងការយល់ដឹង

[55] សហប្រតិបត្តិការបារាំងគំរោងទ្រទ្រង់នីតិរដ្ឋ, មេរៀននីតិព្រហ្មទណ្ឌខ្មែរ (២០០៨), ៤០។

[56] សហប្រតិបត្តិការបារាំងគំរោងទ្រទ្រង់នីតិរដ្ឋ, មេរៀននីតិព្រហ្មទណ្ឌខ្មែរ (២០០៨), ៤០។

[57] ក្រមព្រហ្មទណ្ឌកម្ពុជា,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩,មាត្រា៣១, កថាខណ្ឌទី៣។

ហើយបង្កឱ្យគ្រោះថ្នាក់ចរាចរណ៍មួយកើតឡើង គឺបុរសម្នាក់នោះ បានបើករយន្តទៅបុកជាមួយក្មេងស្រីម្នាក់ ដែលកំពុងធ្វើដំណើរតាមដងផ្លូវ បណ្តាលឱ្យស្លាប់ភ្លាមៗ។ ក្នុងករណីនេះ បុរសដែលបានបង្កនេះ ទោះបីជាគាត់គ្មានចេតនាក្នុងការប្រព្រឹត្តបទល្មើសក៏ដោយ ក៏គាត់នៅតែទទួលខុសត្រូវនូវអំពើរបស់ខ្លួនបានប្រព្រឹត្តដដែរ ព្រោះថាគាត់បានបាត់បង់ស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹងដែលច្បាប់បានកំណត់ថាត្រូវតែទទួលខុសត្រូវចំពោះអំពើដែលគាត់បានប្រព្រឹត្តនោះ ។

២ បុរសម្នាក់បានប្រើប្រាស់ថ្នាំញៀន ឬផឹកគ្រឿងស្រវឹង បណ្តាលឱ្យបាត់បង់ការគ្រប់គ្រងលើខ្លួនឯង ហើយក៏បានទៅវាយបុរសម្នាក់ទៀត ដែលនៅក្បែរនោះបណ្តាលអោយរងរបួសធ្ងន់។ ជនល្មើសនោះមិនអាចប្រើប្រាស់ ឬលើកយកនូវមូលហេតុដែលខ្លួនស្រវឹង យកមកធ្វើជាហេតុផលមួយដែលអាចធ្វើឱ្យខ្លួនមានការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះទេ។ ដោយឡែកបុរសដែលប្រព្រឹត្តនោះ នឹងត្រូវតែប្រឈមមុខនូវរាល់កំហុសទាំងអស់ដែលខ្លួនបានប្រព្រឹត្ត ពីព្រោះថាមូលហេតុដែលខ្លួនប្រុងនឹងលើកយកមកអះអាងនៅទីនោះមិនមានច្បាប់ណាមួយបញ្ជាក់ថាអាចយកមកធ្វើជាភស្តុតាងផ្ទុយបាននោះទេ[58]។

លើសពីនេះទៅទៀត សៀវភៅរបស់លោកសាស្ត្រាចារ្យ **រុន ពណ្ណារិទ្ធ** បង្ហាញដែរថាបញ្ហាចោទឡើងចំពោះការប្រើប្រាស់ថ្នាំផ្សេងៗ ដែលមានឥទ្ធិពលប៉ះពាល់ដល់ប្រព័ន្ធប្រសាទដូចជា គ្រឿងញៀន សុរា ឬថ្នាំផ្សេងៗទៀតជាដើម ។ ការប្រើប្រាស់ថ្នាំទាំងអស់នោះច្រើនពេកអាចធ្វើឱ្យខូចខាតដល់ប្រព័ន្ធសរសៃប្រសាទគ្រប់គ្រងខ្លួនមនុស្សមួយរយៈពេលបាន។ ប៉ុន្តែការកំណត់ថាការប្រើប្រាស់គ្រឿងបំពុលនេះជាមូលហេតុនៃការមិនទទួលខុសត្រូវបានបង្កជាចំណោទមួយដ៏លំបាកស្មុគស្មាញ ពីព្រោះថាការប្រើប្រាស់គ្រឿងបំពុលច្រើនតែកើតចេញពីឆន្ទៈរបស់អ្នកប្រើប្រាស់តែម្តង។ ហេតុដូច្នេះហើយ ទើបក្រមព្រហ្មទណ្ឌត្រង់មាត្រា ៣១ កថាខណ្ឌទី៣ មិនចាត់ទុកថាវិបល្លាសស្មារតីដែលបានកើតចេញពីការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារជាតិដែលច្បាប់ហាមឃាត់ជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌបានឡើយ[59]។

សៀវភៅរបស់លោក **កៅ សីហា** អះអាងផងដែរថា ច្បាប់បានកំណត់ដើម្បីឱ្យទទួលខុសត្រូវផងដែរចំពោះអ្នកប្រើប្រាស់សារជាតិដែលច្បាប់ហាមឃាត់ គ្រឿងញៀន ឬមួយផឹកស្រាស្រវឹងក៏ទៅប្រព្រឹត្តបទល្មើស ដោយយកលេសថាមានវិបល្លាសស្មារតី ដើម្បីរួចផុតពីការទទួលខុសត្រូវនោះច្បាប់មិនទទួលស្គាល់ទង្វើបែបនេះឡើយ។[60]

**ឧទាហរណ៍:** បុរសម្នាក់ដែលជាអ្នកចូលចិត្តដើរលេងយប់ បានប្រើប្រាស់ថ្នាំញៀន ដើម្បីភាពសប្បាយរីករាយ។ ភ្លាមៗនោះ ដោយសារតែឥទ្ធិពលនៃថ្នាំញៀន បានធ្វើឱ្យបុរសម្នាក់នោះទៅចាប់រំលោភសេពសន្ថវៈលើ

[58] សារណាបញ្ចប់ការសិក្សារបស់ លោក សុជា រស្មី និងលោក អៀង វណ្ណៈ (២០១៦)។

[59] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៤០។

[60] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ (ភ្នំពេញៈ អង្គារ,២០១៣០,២៣៨។

ស្ត្រីម្នាក់។ ជាលទ្ធផលបុរសម្នាក់នោះ មិនអាចលើកហេតុផលថា មូលហេតុនៃការប្រព្រឹត្តបទល្មើសរបស់ខ្លួន បណ្ដាលមកពីឥទ្ធិពលគ្រឿងញៀនឡើយ ពោលបុរសម្នាក់នោះ ត្រូវតែទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌដដែល។

### ១.២ លក្ខខណ្ឌពេលវេលា

អតិភាពនៃការឡប់សតិនៅពេលប្រព្រឹត្តបទល្មើស ដូចបញ្ជាក់ប្រាប់នៃរឿងនេះផងដែរ ពាក្យពេជនៃមាត្រា១២២ គ្រ១ នៃក្រមព្រហ្មទណ្ឌបារាំងចែងថាអតិភាពនៃភាពមិនគ្រប់ទឹកផ្នែកចិត្តសាស្ត្រ ត្រូវវាយកាយតម្លៃនៅកាលប្រព្រឹត្ត ហេតុដូច្នេះវាជារឿងត្រឹមត្រូវដែរថាការមិនគ្រប់ដប ឬការឡប់សតិ មនុស្សមិនគ្រប់ទឹកនេះត្រូវមាននៅពេលមានបទល្មើស ដើម្បីបង្កើតជាបុព្វហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ[61]។

## ២ អានុភាព

ប្រសិនបើចារីមានវិបល្លាសស្មារតី ដែលត្រឹមតែបន្ថយនូវការដឹងខុសត្រូវរបស់គាត់តែប៉ុណ្ណោះ គាត់នៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ក៏ប៉ុន្តែស្ថានភាពនេះ អាចក្លាយជាស្ថានភាពសម្រាលទោសសម្រាប់ចារីបាន។ កំហុកនៃការធ្វើឲ្យចុះខ្សោយ បញ្ជាក់បានពីការរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌ (២.១) ក៏ប៉ុន្តែមិនមានឧបទ្ទវហេតុណាមួយទៅលើការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីនោះទេ(២.២)។

### ២.១ ផលវិបាកនៅលើការទទួលខុសត្រូវព្រហ្មទណ្ឌ

មាត្រា៣១ កថាខណ្ឌទី១ កំណត់ថា កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតីដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ផ្អែកតាមស្មារតីមាត្រានេះ ជនកើតវិបល្លាសស្មារតី ត្រូវរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌទាំងស្រុង។

ចារីមានវិបល្លាសស្មារតី ដែលត្រឹមតែបន្ថយនូវការដឹងខុសត្រូវរបស់គាត់តែប៉ុណ្ណោះ គាត់នៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ក៏ប៉ុន្តែស្ថានភាពនេះ អាចក្លាយជាស្ថានភាពសម្រាលទោសសម្រាប់ចារីបាន[62]។

ផ្អែកតាមស្មារតីនៃក្រមព្រហ្មទណ្ឌ បុគ្គលម្នាក់ដែលបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ស្របពេលដែលខ្លួនស្ថិតក្រោមឥទ្ធិពលនៃគ្រឿងស្រវឹង ឬគ្រឿងញៀន គេមិនអាចចាត់ទុកថាបុគ្គលនោះមានវិបល្លាសស្មារតីឡើយ ពោល គឺជននោះត្រូវតែទទួលខុសត្រូវព្រហ្មទណ្ឌដោយមិនអាចលើកលែងបានឡើយ[63]។ ដូច្នេះ ត្រូវញែកឱ្យដាច់ស្ថានភាព ០២ គឺ៖

១ ការមិនគ្រប់ទឹក ដែលត្រូវបានលុបចោលនៅការយល់ដឹង: បុគ្គលនឹងមិនអាចត្រូវបានប្រកាសឲ្យទទួលខុសត្រូវខាងព្រហ្មទណ្ឌនោះទេ។

---

[61] ព្រហ្មទណ្ឌបារាំង (២២ កក្កដា ២០១២),១២២-១។

[62] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៣៩។

[63] ក្រមព្រហ្មទណ្ឌកម្ពុជា,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩,មាត្រា៣១, កថាខណ្ឌទី៣។

២ ការមិនគ្រប់ទឹក បានធ្វើឱ្យចុះខ្សោយការយល់ដឹងៈ បុគ្គលនូវតែទទួលខុសត្រូវដដែល ប៉ុន្តែចៅក្រម និង ពិចារណាទៅលើកាលៈទេសៈនេះ ដើម្បីសម្របទោស។

**២.២ ការរក្សាទុក ឬការប្រកាន់ទុកនៃការទទួលខុសត្រូវផ្នែករដ្ឋប្បវេណី**

ការធ្វើឲ្យចុះខ្សោយ ឬការធ្វើឲ្យលុបចោលការយល់ដឹង មិនមានឧបទ្ទហេតុណាមួយទៅលើការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីរបស់ជនជាប់ចោទនោះទេ។

**ផ្នែកទី២ ការបង្ខិតបង្ខំ**

តាមមាត្រា៣៦ កថាខណ្ឌទី១ នៃក្រមព្រហ្មទណ្ឌកម្ពុជា ការបង្ខិតបង្ខំ គឺជាព្រឹត្តិការណ៍ដែលស្តែងចេញពីរបស់ធម្មជាតិ សត្វ ឬតតិយជនទៅកាន់ចារីក្នុងរូបភាពដែលមិនអាចទប់ទល់បាន បណ្តាលឱ្យចារីបង្ខំចិត្តត្រូវតែប្រព្រឹត្តបទល្មើសនោះតែម្តង។

ការបង្ខិតបង្ខំ ខុសពីសតិមិនគ្រប់ ដែលលុបចោលនៅការយល់ដឹងការបង្ខិតបង្ខំលុបចោលឆន្ទៈរបស់ចារី។ ការមិនទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គលដែលបានធ្វើសកម្មភាពក្រោមកម្លាំងមួយ ឬការបង្ខិតបង្ខំមួយដែលខ្លួនមិនអាចទ្រាំបាន។ ការបង្ខិតបង្ខំអាចមានលក្ខណៈរូបកាយ (១) ឬផ្លូវចិត្ត(២)ហើយមានអានុភាពមួយចំនួនទៅការទទួលខុសត្រូវរបស់ចារី(៣)។

**១ ការបង្ខិតបង្ខំរូបកាយ**

ការបង្ខំលើរូបកាយ សំដៅទៅលើវត្តមាននៃកម្លាំងណាមួយលើរូបកាយរបស់ចារី ដែលជាមូលហេតុធ្វើឱ្យចារីត្រូវតែប្រព្រឹត្តអំពើ ដោយខ្លួនពុំអាចឃាត់ឃាំងអំពើនោះបាន[64]។

**ឧទាហរណ៍ៈ**

១ ខ្យល់ព្យុះ ឬរន្ទះបាញ់ បានបណ្តាលឱ្យអ្នកបើកបររថយន្ត មិនអាចទប់ទល់ចង្កូតរថយន្តបាន ហើយក៏ជ្រុលចង្កូតទៅកិនអ្នកថ្មើរជើងតាមដងផ្លូវបណ្តាលឱ្យស្លាប់បាត់បង់ជីវិត និងរបួសជាច្រើននាក់។

២ បុរសម្នាក់បានបើកបរត្រឹមត្រូវតាមល្បឿនកំណត់នៅលើដងផ្លូវ ពេលកំពុងបើកបរស្រាប់ តែមានក្មេងពីរនាក់បានរត់លេងប្រទ្បេងគ្នា ក៏រត់ជ្រុលចូលចំពីផ្លូវមុខរថយន្តរបស់បុរសកំពុងបើកបរនោះបណ្តាលឱ្យស្លាប់បាត់បង់ជីវិត។

ប្រសិនបើប្រភពដើមនៃការបង្ខិតបង្ខំ ដែលមានប្រភពដើមពីខាងក្រៅ ឬខាងក្នុង (១.១) ប៉ុន្តែវាត្រូវតែមិនអាចទប់ទាល់បាន(១.២) ហើយមិនអាចដឹងមុនបាន(១.៣)។

**១.១ ការបង្ខិតបង្ខំដែលមានប្រភពដើមពីខាងក្រៅ ឬខាងក្នុង**

ការបង្ខំលើរូបកាយអាចនៅខាងក្នុង ឬនៅខាងក្រៅ។ កម្លាំងបង្ខំនេះអាចជាកម្លាំងបង្ខំមកពីខាងក្រៅ ដូចជា

[64] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៤៣។

កម្លាំងបង្ខំមកពីព្រឹត្តិការណ៍ធម្មជាតិ មកពីសត្វ ឬមកពីតតិយជនណាមួយ។

**ឧទាហរណ៍**: កំពុងតែធ្វើដំណើរលើផ្លូវ ស្រាប់តែមានខ្យល់ព្យុះ បណ្ដាលឱ្យបុរសម្នាក់មិនអាចគ្រប់គ្រងចង្កូតរថយន្តបាន ក៏ឈានដល់បុកអ្នកដំណើរម្នាក់ស្លាប់ភ្លាមៗ។ ជនបង្កមិនត្រូវដាក់ទោសបានឡើយដោយសារមូលហេតុនៃអំពើគ្រោះថ្នាក់ មិនបានកើតពីឆន្ទៈខ្លួនពោលការដែលបណ្ដាលឱ្យរថយន្តជ្រុលចង្កូតទៅបុកអ្នកដទៃវាកើតឡើងពីកម្លាំងធម្មជាតិ។

ក្រៅពីនេះ កម្លាំងបង្ខំអាចជាកម្លាំងបង្ខំមកពីស្ថានភាពខាងក្នុងផ្ទាល់របស់ចារី។

**ឧទាហរណ៍**: នៅពេលកំពុងបើកបរធម្មតាលើដងផ្លូវ អ្នកបើកបរម្នាក់ស្រាប់តែរកវិលមុខ ធ្វើឱ្យស្មារតីមិនអាចគ្រប់គ្រងរថយន្តរបស់ខ្លួនបានបណ្ដាលឱ្យបុកអ្នកដំណើរម្នាក់រងរបួស។ ករណីនេះហៅថា កម្លាំងបង្ខំមកពីស្ថានភាពខាងក្នុងផ្ទាល់របស់ចារី ដែលចារីនោះមិនត្រូវផ្ដន្ទាទោសព្រហ្មទណ្ឌឡើយ។

គួរបញ្ជាក់ថា មាត្រា៣៦ កថាខណ្ឌទី២ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងថា: កម្លាំង និងការបង្ខំអាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សប៉ុណ្ណោះ។ ចំណែកឯការបង្ខំលើរូបកាយដែលកើតចេញពីស្ថានភាពខាងក្នុងផ្ទាល់របស់ចារី គឺជាព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្ស តែជាស្ថានភាពដែលកើតចេញពីខ្លួនចារីផ្ទាល់។ ហេតុដូចនេះ គេមិនអាចឱ្យសន្និដ្ឋានបានថា ជំងឺរបស់ចារី គឺជាព្រឹត្តិការណ៍កើតចេញពីឆន្ទៈរបស់ចារីនោះទេ[65]។

## ១.២ ការបង្ខិតបង្ខំដែលមិនអាចទប់ទល់បាន

មាត្រា៣៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងថាបុគ្គលដែលប្រព្រឹត្តបទល្មើស ក្រោមអានុភាព នៃកម្លាំង ឬនៃការបង្ខំ ដែលបុគ្គលនេះ មិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ។ កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ កម្លាំងនេះ ត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចចៀសបាន[66]។ ក្នុងករណីដែលបទល្មើសមួយបានកើតឡើងហើយ បុគ្គលនោះពុំបានអាចដឹងមុន ឬពុំអាចត្រៀមខ្លួនក្នុងការទប់ទល់នឹងបទល្មើសមួយនោះបានក៏បង្ខំចិត្តប្រព្រឹត្តបទល្មើសនោះទៅ ដូច្នេះបុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

## ១.៣ ការបង្ខិតបង្ខំមិនដឹងមុន

កម្លាំង និងការបង្ខំ ត្រូវតែជាស្ថានភាពដែលមិនអាចមើលឃើញជាមុនបានពោល គឺជនដែលប្រព្រឹត្តបទល្មើសមិនអាចប៉ាន់ស្មានដឹងជាមុនបានឡើយ ហើយក៏ពុំមែនកើតចេញពីកំហុសណាមួយផ្ទាល់របស់គាត់ផ្ទាល់ដែរ។ ក្នុងន័យនេះជនដែលខ្វះការប្រុងប្រយ័ត្នក្នុងការទប់ស្កាត់អំពើដែលអាចបង្ខំអោយខ្លួនប្រព្រឹត្តបទល្មើសមិនលើកសំអាងពីកម្លាំង ឬការបង្ខំ ដើម្បីឱ្យខ្លួនរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌនោះឡើយ[67]។

---

[65] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៤៤។

[66] ក្រមព្រហ្មទណ្ឌកម្ពុជា,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩,មាត្រា៣៦។

[67] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៤៧។

**ឧទាហរណ៍:**

១.ក្នុងករណីជនដែលខ្វះការប្រុងប្រយ័ត្នក្នុងការទប់ស្កាត់អំពើដែលបានកើតមកលើខ្លួន មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។

២.អ្នកបើកបរមិនអាចលើកសំអាងថា ខ្លួនមិនអាចដឹងជាមុនថាម៉ាស៊ីនឡានរបស់ខ្លួនខូចបណ្តាលឱ្យគាត់បើកបរបង្ករបួសដល់ជនរងគ្រោះឡើយ ពីព្រោះថាគាត់បានធ្វេសប្រហែសមិនបានមើលថែទាំរថយន្តរបស់គាត់ឱ្យបានល្អ។ ជាមួយគ្នានេះ អ្នកបើកបរមិនអាចលើកសំអាងថា ដោយសារការបើកបររថយន្តរយៈពេលវែងនិងមិនបានបរិភោគអាហារគ្រប់គ្រាន់ ធ្វើឱ្យសុខភាពផ្លូវកាយរបស់គាត់ទ្រុឌទ្រោម ទើបបានជាបង្កឱ្យមានគ្រោះថ្នាក់ចរាចរណ៍ ពីព្រោះថាជាទូទៅគេអាចដឹងជាមុនបានថា នៅពេលបើកបររយៈពេលវែង និងបរិភោគអាហារមិនគ្រប់គ្រាន់ រមែងធ្វើអោយរូបកាយចុះខ្សោយ[68]។

## ២ ការបង្ខិតបង្ខំផ្លូវចិត្ត

ការបង្ខំលើផ្លូវចិត្ត មានលក្ខណៈខុសគ្នារវាងការបង្ខំលើរូបរាងកាយត្រង់ថា ការបង្ខំលើរូបរាងកាយ ចារីប្រព្រឹត្តបទល្មើស ក្រោមការបង្ខំពីឆន្ទៈខាងក្រៅ។ ចំណែកឯការបង្ខំលើផ្លូវចិត្តវិញ គឺចារីប្រព្រឹត្តបទល្មើស ក្រោមការបង្ខំពីឆន្ទៈខាងក្នុង ការបង្ខំលើផ្លូវចិត្ត គឺជាឥទ្ធិពលមួយដែលចារីទទួលរងសម្ពាធយ៉ាងធ្ងន់ធ្ងរបំផុតពីតតិយជនក្នុងការបង្ខំឱ្យចារីនោះចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស ជាហេតុនាំឱ្យចារីចាំបាច់ត្រូវតែបង្ខំចិត្តប្រព្រឹត្តបទល្មើសដោយ កើតចេញពីការគំរាមកំហែងនោះតែម្តង។ វាអាចជាហេតុខាងក្រៅ ឬការទទួលយកការបង្ខិតបង្ខំផ្នែកខាងក្រៅ (២.១) ប៉ុន្តែមិនអាចជាហេតុខាងក្នុង ឬការផ៉ាតនៃការបង្ខិតបង្ខំផ្នែកខាងក្នុង (២.២)។

### ២.១ ការទទួលយកការបង្ខិតបង្ខំផ្នែកខាងក្រៅ

ការបង្ខំផ្លូវចិត្តក៏អាចជាមូលហេតុនៃការមិនទទួលត្រូវព្រហ្មទណ្ឌបានដែរ តែក្នុងករណីដែលការបង្ខំនោះមានប្រភពមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់ចារីប៉ុណ្ណោះ ពោលគឺជាការរងសម្ពាធយ៉ាងធ្ងន់ធ្ងរបំផុតខាងក្រៅដែលជំរុញឱ្យចារីមិនអាចបញ្ចៀសបានពីការប្រព្រឹត្តិបទល្មើស[69]។ ដូចគ្នាទៅនឹងការបង្ខិតបង្ខំរូបកាយដែល ការបង្ខិតបង្ខំផ្លូវចិត្តផ្នែកខាងក្រៅ តម្រូវឲ្យមាននៅក្នុងហេតុមួយចំនួន នឹងកាលៈទេសៈមួយចំនួន ដែលរៀបចំឡើងឥតខ្ចោះដែលទាញចេញពីនោះមក គឺថាមិនអាចគេចផុតពីគ្រោះភ័យ ដោយពុំប្រព្រឹត្តនៅបទល្មើសនោះ នៅទីនេះអាចជាសម្ពាធទៅលើឆន្ទៈរបស់ចារី ដែលដកហូតពីចារីនៅឆន្ទៈរបស់ខ្លួន ក្នុងការប្រព្រឹត្តកាយវិកា។

ការបង្ខំខាងផ្លូវចិត្តនេះអាចលើកលែងចារីនៅពេល ដែលការបង្ខំនេះមានប្រភពមកពីខាងក្រៅ។ ដូច្នេះនៅក្នុងករណីដែលចារីបានប្រព្រឹត្តដោយមានការគំរាមកំហែងដ៏ច្បាស់លាស់ ប្រឆាំងនឹងខ្លួនរបស់ចារី ឬប្រឆាំងនឹងតតិយជន ជននោះអាចមិនទទួលខុសត្រូវព្រហ្មទណ្ឌ[70]។ ការគំរាមកំហែងដែលជាមូលហេតុនាំឱ្យចារីរួចផុតពី

[68] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៤៧។

[69] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៤៥។

[70] សហប្រតិបត្តិការបារាំងគំពេងទ្រទ្រង់នីតិរដ្ឋ,មេរៀននីតិព្រហ្មទណ្ឌខ្មែរ(២០០៨),ទំព័រ៤២។

ការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវតែមានភស្តុតាងបញ្ជាក់ថា ការគំរាមកំហែងពិតជាមានលក្ខណៈខុសច្បាប់ពិតប្រាកដមែន[71]។

**ឧទាហរណ៍:** ចោរមួយក្រុមដឹងថា បុរសម្នាក់បានដឹកជញ្ជូនប្រាក់យ៉ាងច្រើនពីធនាគារជាតិទៅប្រើប្រាស់តាមការចាត់ចែងរបស់មន្ត្រីធនាគារជាតិ។ លុះធ្វើដំណើរដល់ពាក់កណ្ដាលផ្លូវ បុរសនោះត្រូវបានគំរាមកំហែងប្លន់យកប្រាក់ ដោយក្រុមចោរឱ្យបើករថយន្ត ទៅកាន់ទីកន្លែងចោរ។ ករណីនេះ អ្នកដឹកជញ្ជូនពុំទទួលខុសត្រូវពីបទល្មើសព្រហ្មទណ្ឌទេ ចំពោះអំពើនៃការប្លន់ប្រាក់នេះឡើយ ពីព្រោះថាខ្លួនបានប្រគល់ប្រាក់ទាំងនោះ ក្រោមការគំរាមកំហែងរបស់ តតិយជនដែលជាក្រុមចោរ។

## ២.២ ការផាតចេញនៃបង្ខិតបង្ខំផ្នែកខាងក្នុង

ផ្ទុយទៅវិញ ចំពោះការបង្ខំខាងផ្លូវចិត្តខាងក្នុងការមិនទទួលខុសត្រូវព្រហ្មទណ្ឌអាចពុំត្រូវបានគេទទួលស្គាល់ទេ [72] ។ ជាញឹកញាប់បំផុត ការបង្ខំខាងផ្លូវចិត្តនេះទាក់ទងនឹងសភាពជំងឺផ្នែកតណ្ហា ដែលកំណត់ការប្រព្រឹត្តរបស់ចារី ដូចគ្នាដែរ ចំពោះតណ្ហា កំហឹង ភាពស្អប់ខ្ពើម។ ការបង្ខំខាងផ្លូវចិត្តខាងក្នុងនេះ ពុំមែនជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ លើកលែងករណីជ្រុល ឬសភាពជំងឺ ដែលឈានទៅរកការបាត់បង់នូវការដឹងខុសត្រូវ ដោយសារតែស្មារតីវិបល្លាស។ ជាក់ស្តែងការបង្ខំលើផ្លូវចិត្តដែលមានប្រភពមកពីចារីផ្ទាល់មិនអាចជាមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌបានទេ[73]។

**ឧទាហរណ៍:** ដោយសារការខឹង ការស្អប់ខ្ពើម ជំនឿផ្នែកមនោគមវិជ្ជា ឬសាសនាណាមួយបានបង្ខំឱ្យចារីត្រូវតែប្រព្រឹត្តបទល្មើស។ ក្នុងករណីបែបនេះ ចារីនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែលពីព្រោះថាការបង្ខំផ្លូវចិត្តនេះមានប្រភពមកពីព្រឹត្តិការណ៍ក្នុងឆន្ទៈរបស់ចារីផ្ទាល់តែម្តង[74]។

# ៣ អានុភាពនៃការបង្ខិតបង្ខំ

អានុភាព៖ ជាថាមពលនៃកម្លាំងអ្វីមួយ។

មាត្រា៣៦ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងថាបុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំងឬនៃការបង្ខំ ដែលបុគ្គលនេះ មិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវខាងព្រហ្មទណ្ឌទេ។ កម្លាំង និងការបង្ខំ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ។ កម្លាំងនេះ ត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចចៀសបាន[75]។ ក្នុងករណីដែលបទល្មើសមួយបានកើតឡើងហើយ បុគ្គលនោះពុំបានអាច

[71] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៤៥។

[72] សហប្រតិបត្តិការបារាំងគាំពារទ្រទ្រង់នីតិរដ្ឋ,មេរៀននីតិព្រហ្មទណ្ឌខ្មែរ(២០០៨),ទំព័រ៤២។

[73] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៤៥។

[74] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៤៥។

[75] ក្រមព្រហ្មទណ្ឌកម្ពុជា,លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា ២០០៩,មាត្រា៣៦។

ដឹងមុន ឬពុំអាចត្រៀមខ្លួនក្នុងការទប់ទល់នឹងបទល្មើសមួយនោះបានក៏បង្ខំចិត្តប្រព្រឹត្តបទល្មើសនោះទៅ ដូច្នេះ បុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ។

ក្រមព្រហ្មទណ្ឌថ្មី មិនបានឱ្យនិយមន័យលើពាក្យ អានុភាពនៃកម្លាំង និងការបង្ខំឡើយ។ ចំណែកឯក្រមព្រហ្មទណ្ឌចាស់កម្ពុជា១៩៦៧វិញ ក៏មិនបានប្រើពាក្យ អានុភាពនៃកម្លាំង ឬការបង្ខំទេ ប៉ុន្តែបានអោយនិយមន័យ នៃពាក្យនេះនៅមាត្រា៩៦ យ៉ាងដូច្នេះថា កាលបើមានភស្តុតាងថាមានកម្លាំងអ្វីមួយបានបង្ខំជនណាម្នាក់ឱ្យប្រព្រឹត្តបទល្មើសអ្វីមួយ ហើយជននោះកាលមិនអាចទប់ទល់នឹងកម្លាំងនោះបានទេ ក៏ប្រព្រឹត្តិបទល្មើសនោះទៅ។ ជនប្រព្រឹត្តបទល្មើសនេះមិនត្រូវឱ្យទទួលខុសត្រូវ ចំពោះអំពើដែលខ្លួនបានប្រព្រឹត្តឡើយ[76]។

មាត្រា៩៧ នៃក្រមព្រហ្មទណ្ឌចាស់កម្ពុជាឆ្នាំ១៩៦៧ដដែល ឱ្យនិយមន័យនៃពាក្យកម្លាំងបង្ខំ ថាជាគ្រោះថ្នាក់ណាមួយដែលបណ្តាលឱ្យមានអាសន្នយ៉ាងធំបំផុត[77]។ ពាក្យថាអាសន្នយ៉ាងធំបំផុត មានន័យថាគ្រោះថ្នាក់មួយយ៉ាងធំបំផុត ដែលនឹងត្រូវធ្លាក់មកលើខ្លួន ក្នុងពេលជាបន្ទាន់ក្រៃពេកមិនអាចឱ្យខ្លួនចៀសផុតពីគ្រោះនេះបាន ដោយមិនបានប្រព្រឹត្តបទល្មើសមួយនោះទេ ម្យ៉ាងទៀតគ្រោះថ្នាក់នោះ កាលបើកើតឡើងក៏ មិនមែនកើតឡើងពីឆន្ទៈផ្ទាល់របស់ចារីនៃបទល្មើសនោះដែរ នឹងមិនមែនចារីនោះជាអ្នកបង្កើត ឬជាអ្នកបណ្តាលឱ្យមានគ្រោះថ្នាក់នោះដែរ[78]។

មាត្រា៩៩ នៃក្រមព្រហ្មទណ្ឌចាស់ ជានិយមន័យដ៏សំខាន់ក្នុងការឈានទៅដល់ការស្វែងយល់ពីនិយមន័យពីមាត្រា៣៦ នៃក្រមព្រហ្មទណ្ឌ និងមាត្រា ៩៦ នៃក្រមព្រហ្មទណ្ឌចាស់នៃព្រះរាជាណាចក្រកម្ពុជា ពីព្រោះមាត្រាទាំងពីរនេះមានខ្លឹមសារប្រហាក់ប្រហែលគ្នា។ ដូចនេះតាមរយៈខ្លឹមសារនៃមាត្រា ៩៧ នៃក្រមព្រហ្មទណ្ឌចាស់(១៩៦៧) យើងអាចសន្និដ្ឋានបាននូវនិយមន័យនៃពាក្យថា អានុភាពនៃកម្លាំងបង្ខំ ឬការបង្ខំ គឺសំដៅដល់គ្រោះថ្នាក់យ៉ាងធំបំផុតនឹងត្រូវធ្លាក់មកលើជនណាម្នាក់ក្នុងពេលជាបន្ទាន់ដោយមិនអាចនឹងជៀសវាងបាន លុះត្រាតែចារីបានប្រព្រឹត្តបទល្មើសហើយបទល្មើសនោះទៀតសោតក៏មិនបានចេញពីឆន្ទៈរបស់ចារីដែរ[79]។

**ឧទាហរណ៍៖** បុរសម្នាក់ជាអ្នករត់តាក់ស៊ី បានបើកបរគោរពតាមច្បាប់ចរាចរណ៍ដែលបានកំណត់នៅពេលកំពុងបើកបរ ស្រាប់តែមានខ្យល់ព្យុះយ៉ាងធំមួយបានគួចបោកឡានបុរសនោះ បណ្តាលឱ្យធ្លាក់ផ្លូវ និងក្រឡាប់បណ្តាលឱ្យអ្នកធ្វើដំណើរក្នុងឡាននោះរងរបួសជាច្រើននាក់។ ក្នុងករណីនេះ បុរសអ្នកបើកតាក់ស៊ីនោះ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ដោយសារតែអំពើរបស់គាត់ស្តែងចេញពីឆន្ទៈខាងក្រៅរបស់គាត់តែប៉ុណ្ណេះ។

---

[76] ក្រមព្រហ្មទណ្ឌចាស់កម្ពុជាឆ្នាំ១៩៦៧,មាត្រា៩៦។

[77] ក្រមព្រហ្មទណ្ឌចាស់កម្ពុជាឆ្នាំ១៩៦៧,មាត្រា៩៧។

[78] នុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២),២៤២។

[79] សារណាបញ្ចប់ការសិក្សារបស់ លោក សុជា រស្មី និងលោក អៀង វណ្ណៈ (២០១៦)។

## ផ្នែកទី៣ ការភាន់ច្រឡំលើអង្គច្បាប់

ការភាន់ច្រឡំលើអង្គច្បាប់ ផ្តល់ផលទៅឲ្យបុគ្គលដែលបានប្រព្រឹត្តហេតុមួយចំនួនដែលអាចស្ដីបន្ទោសបានដោយមិនដឹងពីអត្ថិភាពនៃការចោទប្រកាន់ ឬដោយបកស្រាយដោយអត្ថបទដោយរបៀបភាន់ច្រឡំ ។

**ឧទាហរណ៍:** មាត្រា១២២ គ្រេ៣ នៃក្រមព្រហ្មទណ្ឌបារាំងចែងថា មិនទទួលខុសត្រូវព្រហ្មទណ្ឌបុគ្គលដែលផ្តលនូវយុត្តិកម្មថាបានជឿតាមការភាន់ច្រឡំមួយលើអង្គច្បាប់ថាខ្លួនមិនបាន បញ្ចៀស ឬមិនបានបំពេញអំពើដោយស្របច្បាប់។

ប៉ុន្តែគោលការណ៍ គឺថាគ្មានជនណាម្នាក់មិនដឹងថាច្បាប់មាននោះទេ នូវតែជាពាក្យស្លោកដែលត្រូវដឹងដដែលការភាន់ច្រឡំខាងអង្គច្បាប់ចែងនៅមាត្រា១២២ គ្រេ៣ នៃក្រមព្រហ្មទណ្ឌបារាំង ហើយកំណត់ក្របខណ្ឌដោយលក្ខខណ្ឌមួយចំនួន (១) ពីព្រោះវាបង្កើតអានុភាពរបស់វា (២)។

### ១ លក្ខខណ្ឌ

### ១.១ លក្ខខណ្ឌខាងនីតិវិធី

អ្នកច្បាប់បញ្ជាក់ដោយស្តែងចេញច្បាស់លាស់ថា បុគ្គលដែលគិតថាលើកយកមកសំអាងជាច្បាប់ ការភាន់ច្រឡំខាងអង្គច្បាប់មួយត្រូវតែបញ្ជាក់ជាយុត្តិកម្មថាបានប្រព្រឹត្តនូវការភាន់ច្រឡំបែបណាមួយនោះ។ តុលាការកំពូលបារាំងបានទាញចេញពីនេះថា:

១ បុគ្គលដែលចោទប្រកាន់ត្រូវធ្វើជាមូលដ្ឋានតែមួយគាត់ក្នុងការលើកពីការភាន់ច្រឡំខាងអង្គច្បាប់ (ចៅក្រមមិនអាចស្រង់ការភាន់ច្រឡំខាងអង្គច្បាប់ជាបន្ទាន់បានទេ) ហើយដូច្នេះ គឺផ្អែកលើការភាន់ច្រឡំនេះហើយដែលបន្ទុកនៃភស្តុតាងត្រូវផ្អែកលើ។

២ ការភាន់ច្រឡំខាងអង្គច្បាប់ មិនអាចត្រូវបានលើកឡើងសម្រាប់លើកដំបូងនៅចំពោះមុខតុលាការកំពូលបានទេ។ ការភាន់ច្រឡំខាងអង្គច្បាប់ត្រូវតែលើកឡើង បើពុំនោះទេ នឹងមិនទទួលយកពាក្យបណ្តឹងនៅចំពោះមុខចៅក្រមខាងអង្គសេចក្តី។

#### ១.១.១ ការភាន់ច្រឡំដែលមិនអាចជៀសវាងបាន

ការភាន់ច្រឡំលើអង្គច្បាប់ អាចទទួលយកបានតែប្រសិនបើវាមិនជៀសវាងបានប៉ុណ្ណោះ ទៅតាមយុត្តិសាស្ត្រតុលាការកំពូលបារាំង។ ការវាយតម្លៃលក្ខណៈមិនអាចជៀសវាងបាននេះ ត្រូវធ្វើឡើងទៅតាមៈ

១ ស្ថានភាពរបស់ជនជាប់ចោទ

២ ភាពស្មុកស្មាញនៃវិធានច្បាប់ ដែលចែងផ្ទុយ

ការភាន់ច្រឡំខាងអង្គច្បាប់ អាចចេញមកពីការភាន់ច្រឡំ នៃការចុះផ្សាយជាសាធារណៈតាមផ្លូវនៃបិទផ្សព្វផ្សាយនៃសេចក្តីសម្រេចខាងនគរបាល ឬតាមការផ្តល់ព័ត៌មានភាន់ច្រឡំបញ្ជូនទៅឲ្យបុគ្គល។ ក៏ប៉ុន្តែយុត្តិ

សាស្ត្របង្ហាញយ៉ាងម៉ឺងម៉ាត់ ខាងសម្មតិកម្មនៃផ្តល់ព័ត៌មានភាន់ច្រឡំៈ មានតែការផ្តលព័ត៌មានខុសប៉ុណ្ណោះ ដែលកើតចេញពីអាជ្ញាធរសាធារណៈមួយ(ជារឿយៗគឺអាជ្ញាធររដ្ឋបាល)អាចត្រូវទទួលយកបាន។ ដូច្នេះ ព័ត៌មានភាន់ច្រឡំ កើតចេញពីអាជ្ញាធរឯកជន មិនអាចបង្កើតនៃការភាន់ច្រឡំខាងអង្គច្បាប់ ដែលមិនអាចជៀសវាងបាននោះទេ។

**ឧទាហរណ៍ៈ**

១ វិជ្ជាជីវៈខាងច្បាប់ដូចជា មេធាវី ក្រុមប្រឹក្សា មិនអាចផ្តល់នៅព័ត៌មានភាន់ច្រឡំដែលបានបញ្ជាក់ការភាន់ច្រឡំខាងអង្គច្បាប់ដែលមិនអាចជៀសវាងបាននោះទេ។

២ ចម្លើយរបស់រដ្ឋបាលពន្ធ ទាក់ទងទៅនឹងកម្មវត្ថុនៃពាក្យស្នើសុំ ធ្វើឡើងដោយជំនាញការគណនេយ្យដែលជាអ្នកដែលត្រូវបានអនុវត្តដោយអ្នកគ្រប់គ្រងពីនាក់មិនអនុញ្ញាតឲ្យប្រកាន់យកកាភាន់ច្រឡំខាងអង្គច្បាប់ជាប្រយោជន៍របស់ខ្លួនបានទេ តែថាការភាន់ច្រឡំនោះចាត់តាំងពីដើមទីនៃសកម្មភាពរបស់ក្រុមហ៊ុន ត្រូវជាប់ពន្ធលើកាតព្វកិច្ចពន្ធរបស់ខ្លួន។

ត្រូវចងចាំថាចៅក្រមចាត់ទុកថារាល់លើកឱ្យតែមានការភាន់ច្រឡំអាចត្រូវបានលើកឡើង តាមការពិនិត្យពិច័យឡើងវិញបន្ទាប់ពីនៅនឹងអាជ្ញាធរសាធារណៈមួយ វាមិនអាចចាត់ទុកជាថាការភាន់ច្រឡំមិនអាចជៀសវាងបាននោះទេ។

### ១.១.២ ជំនឿមួយស្របច្បាប់នៃកិច្ចមួយដែលត្រូវបានបំពេញ

ចារីត្រូវមានជំនឿដាច់ខាតថា កិច្ចដែលត្រូវបានបំពេញមានលក្ខណៈស្របច្បាប់។ ចារីមិនត្រូវមានមុន្ទិលណាមួយនៅក្នុងអារម្មណ៍នៅពេលដែលហេតុមួយចំនួន ស្តីអំពីនីត្យានុកូលភាព នៃអំពើដែលត្រូវបានបំពេញ។ សភាឧក្រិដ្ឋ នៃតុលាការកំពូលបារាំងបានបញ្ជាក់ថា ពាក្យខ្វែងគំនិតគ្នាមួយ នៃយុទ្ធសាស្ត្ររវាងសភាពីររបស់តុលាការកំពូលបារាំង (ក្នុងរឿងនេះរវាងសភាឧក្រិដ្ឋ និងសភាសង្គម ទាក់ទងទៅនឹងចោរកម្មនៃឯកសារដោយនិយោជិក) គឺជាភាពមិនច្បាស់លាស់មួយហើយ ផាតចេញថាភ្នាក់ងារបានមានជំនឿដាច់ខាតក្នុងកិច្ចស្របច្បាប់នៃកិច្ចដែលបានបំពេញ។

## ២ អានុភាព

បុគ្គលដែលទទួលផលពីការភាន់ច្រឡំ លើអង្គច្បាប់ត្រូវបានប្រកាសមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌនោះទេ។ បើនិយាយអំពើបុព្វហេតុនៃការមិនទទួលខុសត្រូវអត្តវិស័យវិញ សហចារី សមគំនិត អ្នកផ្សំគំនិត មិនអាចលើកសំអាងធ្វើជាច្បាប់បានទេ ប្រសិនបើពួកគេមិនបង្ហាញឲ្យឃើញថាវាត្រូវពួកក៏ជាជនរងគ្រោះនៃការភាន់ច្រឡំផងដែរនោះ ។

## ផ្នែកទី៤ អនីតិភាព

ជាគោលការណ៍ គេមិនអាចឱ្យជនដែលមិនដឹងខុសត្រូវពីភាពធ្ងន់ធ្ងរ នៃអំពើរបស់ខ្លួនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ។ ការយល់ដឹងខុសត្រូវជាកត្តាមួយដែលនាំឱ្យបុគ្គលម្នាក់ៗ ត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ។ ប្រសិនបើក្មេងអាយុ៥ឆ្នាំម្នាក់ បានចាក់សម្លាប់ក្មេងម្នាក់ទៀត ក្មេងដែលបានប្រព្រឹត្តអំពើល្មើសមិនអាចទទួលខុសត្រូវព្រហ្មទណ្ឌបានទេ ដោយសារតែក្មេងអាយុ៥ឆ្នាំនោះ មិនមានសមត្ថភាពដឹងខុសត្រូវពីអំពើរបស់ខ្លួនឡើយ។ ដោយឡែកចំពោះអនីតិជនដែលមានអាយុ៩ឆ្នាំវិញ ការអះអាងថាអនីតិជននោះមិនដឹងខុសត្រូវទាល់តែសោះនោះ គឺជាអំណះអំណាងមួយដែលនឹងពិបាកទទួលយកបាន[80]។ យ៉ាងណាមិញ មាត្រា៣៨ នៃក្រមព្រហ្មទណ្ឌ កំណត់នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌគឺនៅត្រឹមអាយុ១៨ឆ្នាំឡើងទៅ[81]។

ក្នុងន័យបញ្ញត្តិនៃមាត្រា៣៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០១៩ អនីតិជនដែលមានអាយុតិចជាង១៨ឆ្នាំមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ[82] ។ ថ្វីត្បិតតែអនីតិជនមិនត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ ក៏ប៉ុន្តែក្រមព្រហ្មទណ្ឌតម្រូវឱ្យមានវិធានការតាមដាន វិធានការការពារ និងវិធានការឧបត្ថម្ភសម្រាប់អនីតិជនដែលប្រព្រឹត្តបទល្មើស។ ដូច្នេះប្រសិនបើអនីតិជនបានប្រព្រឹត្តបទល្មើស ជាគោលការណ៍គេប្រើវិធានការតាមដាន អប់រំ ការពារ និងឧបត្ថម្ភចំពោះ អនីតិជននោះ (១) មិនតែប៉ុណ្ណោះប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ ក្រមព្រហ្មទណ្ឌអនុញ្ញាតឱ្យតុលាការប្រកាសទណ្ឌកម្មព្រហ្មទណ្ឌ ទៅលើអនីតិជនចាប់ពីអាយុ១៤ឆ្នាំឡើងទៅបានដោយអនីតិជនត្រូវតែទទួលការផ្តន្ទាទោសដោយឡែក (២)[83]។

### ១ វិធានការអនុវត្តន៍ចំពោះអនីតិជន

អនីតិជន ជាជនដែលច្បាប់មិនទាន់ឱ្យទទួលខុសត្រូវលើអំពើដែលខ្លួនបានប្រព្រឹត្ត និងជាជនដែលច្បាប់កំណត់ឱ្យទទួលខុសត្រូវលើអំពើរបស់ខ្លួនដោយមានកម្រិត[84] ។ អនីតិជន គឺជាជនដែលមានអាយុដែលច្បាប់កំណត់ថា ជាជនមិនទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ ព្រោះជាជនដែលមិនអាចយល់ដឹងពីសកម្មភាព ឬអំពើដែលខ្លួនបានប្រព្រឹត្តថា ជាបទល្មើសព្រហ្មទណ្ឌឡើយ។ ទោះបីជាច្បាប់បានកំណត់ថាអនីតិជនដែលមានអាយុក្រោម១៤ឆ្នាំ មិនត្រូវទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌក៏ដោយ តែក៏នៅមានវិធានការមួយចំនួនសម្រាប់អនុវត្តចំពោះនីតិជននោះផងដែរ។ យោងតាមមាត្រា៣៩ ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ កំណត់ថាអនីតិជនប្រព្រឹត្តបទល្មើសជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ[85]។

[80] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២)២៣១។

[81] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៣៨។

[82] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២)២៣១។

[83] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២)២៣២។

[84] ទីស្តីការគណៈរដ្ឋមន្ត្រី, សទ្ទានុក្រមច្បាប់ខ្មែរ អង់គ្លេស បារាំង ផ្នែកព្រហ្មទណ្ឌកម្ពុជាឆ្នាំ២០១១ ,៦៩។

[85] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៣៩ កថាខណ្ឌទី១។

មាត្រា៤០ ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ដដែល កំណត់ពីវិធានការតាមដាន វិធាននការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ ដូចតទៅៈ

១.ការប្រគល់អនីតិជនឱ្យទៅឪពុកម្ដាយ អាណាព្យាបាល បុគ្គលដែលថែរក្សាអនីតិជននោះ ឬបុគ្គលណាផ្សេងទៀត ប្រសិនបើបុគ្គលនោះសក្តិសមនឹងទំនុកចិត្ត។

២. ការប្រគល់អនីតិជនឱ្យទៅសេវាសាធារណដែលសម្រាប់ទទួលបន្ទុកឱ្យអនីតិជន។

៣. ការប្រគល់អនីតិជនឱ្យទៅអង្គការឯកជនដែលមាននីតិសម្បទា ក្នុងការទទួល អនីតិជន។

៤. ការប្រគល់អនីតជនឱ្យទៅមន្ទីរពេទ្យ ឬស្ថាប័នឯកទេស។

៥. ការដាក់អនីតិជនឱ្យស្ថិតនៅក្រោមការការពាររបស់តុលាការ។

ក្នុងករណីដែលអនីតិជនដាក់ឱ្យស្ថិតក្រោមការការពាររបស់តុលាការនោះ តុលាការចាត់តាំងបុគ្គលមួយរូបដែលទទួលភារៈធ្វើការតាមដានអនីតិជន។ បុគ្គលនេះធ្វើរបាយការណ៍ ស្តីពីកិរិយាមាយាទរបស់អនីតិជន ឱ្យបានទៀតទាត់ដល់ព្រះរាជអាជ្ញា អំពីព្រឹត្តិការណ៍ទាំងអស់ដែលអាចនាំឱ្យមានការកែប្រែនូវវិធានការនេះ។

មាត្រាទាំងពីរគឺបានបង្ហាញនូវវិធានការ សម្រាប់អនុវត្តទៅលើអនីតិជនដើម្បីអប់រំ កែប្រែចំពោះ អនីតិជនដែលបានប្រព្រឹត្តបទល្មើស និងដើម្បីធ្វើអោយអនីតិជននោះក្លាយជា អនីតិជនដ៏ល្អនៅក្នុងសង្គម ហើយមិនអាចផ្តន្ទាទោសណាមួយឡើយ បើទោះបីជាអនីតិជននោះបានប្រព្រឹត្តបទល្មើសប្រភេទណាក៏ដោយ។ តាមខ្លឹមសារនៃមាត្រា៣៩ និងមាត្រា៤០ នៃក្រមព្រហ្មទណ្ឌខាងលើនេះ តុលាការជាស្ថានប័នមានសមត្ថកិច្ចក្នុងការចាត់វិធានការដែលបានរៀបរាប់នៅក្នុងមាត្រា៤០ នៃក្រមព្រហ្មទណ្ឌ ក៏ប៉ុន្តែក្រមព្រហ្មទណ្ឌក៏ដូចជាក្រមនីតិវិធីព្រហ្មទណ្ឌពុំបានចែងលម្អិតអំពីនីតិវិធីពិសេស សម្រាប់ចាត់វិធានការទាំងអស់នេះឱ្យមានប្រសិទ្ធភាពនោះទេ[86]។ នីតិវិធីនៃការឃាត់ខ្លួនរបស់អនីតិជនមានលក្ខណៈពិសេសមិនដូចជាការឃាត់ខ្លួននីតិជនឡើយ ពោលគឺពុំមានការពន្យាពេលនៃការឃាត់ខ្លួនឡើយបើសិនបុគ្គលដែលឃាត់ខ្លួននោះជាអនីតិជន[87] ។

## ២ ទណ្ឌកម្មព្រហ្មទណ្ឌលើអនីតិជន

សម្រាប់អនីតិជនចាប់ពីអាយុចាប់ពី១៤ឆ្នាំឡើងទៅ តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌបាន។ ទណ្ឌកម្មព្រហ្មទណ្ឌដែលក្រមព្រហ្មទណ្ឌសំដៅដល់គឺទោសនេះតែម្តង [88] ។ ការកំណត់អាយុ១៤ឆ្នាំ សម្រាប់លទ្ធភាពនៃការប្រកាសទណ្ឌកម្ម ស្របទៅនឹងបទបញ្ញត្តិនៃក្រមនីតិវិធីព្រហ្មទណ្ឌដែលអនុញ្ញាតឱ្យមានការឃុំខ្លួនជនត្រូវចោទ ឬជនជាប់ចោទជាបណ្តោះអាសន្ន ចំពោះអនីតិជនចាប់ពី១៤ឆ្នាំដល់ក្រោម១៨ឆ្នាំ ក្នុងលក្ខណ្ឌ

[86] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២)២៣៣។

[87] ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/៨០០៧/០២៤,១០ សីហា ២០០៧ មាត្រា៩៦ ។

[88] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២)២៣៣។

កំណត់ដោយច្បាប់ និងក្នុងចិរវេលាមួយតិចជាងការឃុំខ្លួនបណ្តោះអាសន្នលើនីតិជន[89]។ ចំណែកឯអនីតិជនអាយុក្រោម១៤ឆ្នាំវិញ មិនអាចត្រូវទទួលរងនូវការផ្តន្ទាទោសណាមួយឡើយ ទោះបីជាអនីតិជននោះបានប្រព្រឹត្តិបទល្មើសប្រភេទណាក៏ដោយ ក៏ប៉ុន្តែតុលាការអាចចាត់វិធានការណាមួយដូចមានចែងនៅក្នុងមាត្រា៤០ នៃក្រមព្រហ្មទណ្ឌបាន[90]។

យោងតាមមាត្រា៣៩ ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០១៩ កំណត់ថា កំណត់ថាអនីតិជនប្រព្រឹត្តបទល្មើសជាកម្មវត្ថុនៃវិធានការតាមដាន វិធានការអប់រំ វិធានការការពារ និងវិធានការឧបត្ថម្ភ។ ប៉ុន្តែតុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជន ចាប់ពីអាយុ១៤ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនតម្រូវ[91]។

បន្ថែមពីនេះទៅទៀត នៃក្រមព្រហ្មទណ្ឌស្តីពីការមិនរាងចាល មិនអាចយកមកអនុវត្តបានឡើយចំពោះអនីតិជន បើទោះបីជាអនីតិជននោះបានប្រព្រឹត្តក្នុងស្ថានភាពមិនរាងចាលក៏ដោយ[92]។

ក្រមព្រហ្មទណ្ឌពុំបានកំណត់និយមន័យ ឬបុគ្គលិកលក្ខណៈរបស់អនីតិជន ដែលជាលក្ខខណ្ឌនៃការប្រកាសទោសទៅលើអនីតិជនឡើយ។ ក្នុងន័យនេះ តុលាការវិនិច្ឆ័យទៅតាមរឿងក្តីនីមួយៗថា តើមានលក្ខខណ្ឌតម្រូវឱ្យប្រកាសទោសទៅលើអនីតិជនដែរ ឬទេ[93]។

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី១៨ឆ្នាំឡើងទៅ។ ដូច្នេះ ក្រោមអាយុ១៨ឆ្នាំ ជាគោលការណ៍ គឺមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ប៉ុន្តែអញ្ញត្រកម្ម ឬករណីលើកលែង ឬករណីពិសេសមួយចំនួន តុលាការអាចប្រកាសទណ្ឌកម្មព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី១៤ឆ្នាំឡើងទៅ ប្រសិនបើកាលៈទេសៈនៃបទល្មើស ឬបុគ្គលិកលក្ខណៈរបស់អនីតិជនដែលជាជនល្មើសតម្រូវ ដូចជាស្ថិតនៅក្នុងស្ថានភាពឃោរឃៅ ឬមួយប្រព្រឹត្តជាប្រចាំ ឬក៏អនីតិជននោះមានអាយុ១៤ឆ្នាំក៏ពិតមែន ប៉ុន្តែមានការរីកធំធាត់ដូចមនុស្សពេញវ័យ។ ដូច្នេះតុលាការអាចប្រកាសទោស ក៏ប៉ុន្តែទោសដែលប្រកាសចំពោះអនីតិជនអាយុចាប់ពី១៤ឆ្នាំនោះ មានលក្ខណៈស្រាលជាងទោសដែលប្រកាសសម្រាប់នីតិជន។ តែបើអនីតិជនមានអាយុក្រោម១៤ឆ្នាំ ឬ១៣ឆ្នាំ ១១ខែ ២៩ថ្ងៃ គឺអត់មានទទួលខុសត្រូវព្រហ្មទណ្ឌ ឬទទួលនូវទណ្ឌកម្មព្រហ្មទណ្ឌណាមួយឡើយ[94]។

---

[89] ក្រមនីតិវិធីព្រហ្មទណ្ឌ លេខ នស/រកម/៨០០៧/០២៤,១០ សីហា ២០០៧ មាត្រា២១៣ និងមាត្រា២១៤ ។

[90] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២)២៣៤។

[91] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៣៩។

[92] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា១៦៣។

[93] រុន ពណ្ណារិទ្ធ,នីតិព្រហ្មទណ្ឌទូទៅ,កែសម្រួលដោយ ចាំង ស៊ីណាត (ភ្នំពេញ ២០១២)២៣៤។

[94] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ, (ភ្នំពេញ៖អង្គរ, ២០១៣),២៤២។

នៅក្នុងក្រមព្រហ្មទណ្ឌ បានបញ្ញត្តិយ៉ាងជាក់លាក់ចំពោះទោសដែលត្រូវអនុវត្តទៅលើអនីតិជន កាលណាតុលាការសម្រេចផ្តន្ទាទោសទៅលើអនីតិជនដែលមានអាយុចាប់ពី ១៤ ឆ្នាំឡើងទៅ គឺមូលហេតុលើការចោទប្រកាន់ត្រូវបានបន្ថយក្នុងលក្ខខណ្ឌដូចតទៅ៖

១.អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល។

២.ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ២០ឆ្នាំ។

៣.អប្បរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើអប្បរមានោះលើសពី១ថ្ងៃ។

៤.អប្បរមា និងអតិបរមានៃទោសពិន័យជាប្រាក់ត្រូវបន្ថយពាក់កណ្តាល[95]។

ដូច្នេះ ការកំណត់ទោសដែលយកមកអនុវត្តលើអនីតិជន ត្រូវបន្ថយពាក់កណ្តាលដូចមានចែងក្នុងមាត្រាខាងលើ។

[95] ក្រមព្រហ្មទណ្ឌកម្ពុជា លេខ នស/រកម/៣០០៩/០២២,៣០ វិច្ឆិកា មាត្រា៦០។

# ជំពូកទី៣

# បុព្វហេតុការមិនទទួលខុសត្រូវរបស់នីតិបុគ្គល

## ជំពូកទី៣ បុព្វហេតុនៃការមិនទទួលខុសត្រូវរបស់នីតិបុគ្គល

## ផ្នែកទី១ ទាក់ទងនឹងនីតិបុគ្គល

ទោះបីជាច្បាប់បានកំណត់អំពីគោលការណ៍ នៃការទទួលខុសត្រូវព្រហ្មទណ្ឌក៏ដោយ ក៏ច្បាប់បានកំណត់អំពីគោលការណ៍អញ្ញត្រកម្មមួយចំនួន ដែលអនុញ្ញាតឱ្យនីតិបុគ្គលអាចមិនទទួលខុសត្រូវព្រហ្មទណ្ឌបានដែរ។ នីតិបុគ្គលគឺជាក្រុមមនុស្ស ឬមូលនិធិដែលមានបុគ្គលភាពគតិយុត្ត ហើយជាប្រធាននៃសិទ្ធិ និងកាតព្វកិច្ច[96]។

មូលហេតុទាក់ទងនឹងនីតិបុគ្គលរួមមាន ការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល ដែលប្រព្រឹត្តដោយរូបវន្តបុគ្គល ឬហៅថានីតិបុគ្គលឯកជន (១) និងការមិនទទួលខុសត្រូវព្រហ្មទណ្ឌរបស់រដ្ឋ ឬហៅថានីតិបុគ្គលសាធារណៈ (២)។

### ១ ការមិនទទួលខុសត្រូវរបស់នីតិបុគ្គលឯកជន

នីតិបុគ្គលឯកជន ជាបណ្តុំនៃរូបវន្តបុគ្គលដែលបង្កើតឡើងដោយច្បាប់ ក្នុងគោលដៅស្វែងរកផលចំណេញ និងបម្រើផលប្រយោជន៍រូបវន្តបុគ្គលដែលជាសមាជិករបស់ខ្លួន។

**ឧទាហរណ៍:** ក្រុមហ៊ុន សមាគម សហជីប ឬអង្គការក្រៅរដ្ឋាភិបាល ឬអង្គការអន្តរជាតិផ្សេងៗ។ល។ក្នុងករណីដែលអំពើមួយប្រព្រឹត្តឡើងដោយតំណាងនៃនីតិបុគ្គលនោះ ប៉ុន្តែដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន ឬជាផលប្រយោជន៍សម្រាប់អ្នកដទៃ គឺច្បាប់មិនដាក់ទណ្ឌកម្មទៅលើនីតិបុគ្គលនោះឡើយ ឬក៏ក្នុងករណីដែលបុគ្គលដែលជាតំណាងឱ្យនីតិបុគ្គលនោះ បានប្រព្រឹត្តបទល្មើសស្ថិតនៅក្នុងមូលហេតុ នៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌដែលមានចែងក្នុងមាត្រា៣១ ដល់មាត្រា៣៧ នៃក្រមព្រហ្មទណ្ឌកម្ពុជា ដូចជាការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ ការការពារស្របច្បាប់ សច្ចធារណ៍នៃការការពារស្របច្បាប់ ស្ថានភាពចាំបាច់ និងអនុភាពនៃកម្លាំង ឬការបង្ខំ ទង្វើទាំងអស់នេះក៏ត្រូវគេសន្មតថានីតិបុគ្គលនោះនឹងមិនទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌដែរ។ និយាយដោយរួមការដាក់ឱ្យនីតិបុគ្គលណាម្នាក់ទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌ លុះត្រាតែមានអំពើជាចេតនារបស់រូបវន្តបុគ្គលមួយ ដែលជាតំណាងឱ្យនីតិបុគ្គលនោះបានប្រព្រឹត្តបទល្មើស ដើម្បីជាផលប្រយោជន៍សម្រាប់នីតិបុគ្គល ហើយត្រូវតុលាការផ្តន្ទាទោសចំពោះរូបវន្តបុគ្គលនោះ ទើបតុលាការប្រកាសអំពីទោសចំពោះនីតិបុគ្គលនោះបាន ក្នុងករណីដែលមានច្បាប់បានចង្អុលបង្ហាញជាក់លាក់អំពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល។

ដើម្បីឱ្យនីតិបុគ្គលឯកជនអាចទទួលខុសត្រូវព្រហ្មទណ្ឌ គឺទាល់តែចូលលក្ខខណ្ឌដែលថានីតិបុគ្គលនេះបានប្រព្រឹត្តបទល្មើសណាមួយ ដោយធ្វើតាមរយៈតំណាងរបស់គាត់ដើម្បីជាប្រយោជន៍របស់នីតិបុគ្គលនោះ។ ការ

[96] ក្រមរដ្ឋប្បវេណីកម្ពុជា លេខ នស/រកម/១២០៧/០៣០, ០៨ ធ្នូ ២០០៩ មាត្រា៤៦ កថាខណ្ឌទី១។

ទទួលខុសត្រូវព្រហ្មទណ្ឌរបស់នីតិបុគ្គល គឺមិនលើកលែង នូវការទទួលខុសត្រូវព្រហ្មទណ្ឌរបស់រូបវន្តបុគ្គលក្នុងអំពើដដែលនោះទេ (វាអាចពាក់ព័ន្ធទៅនឹងមាត្រា១៨ នៃក្រមព្រហ្មទណ្ឌ)[97]។ មាត្រា១៨ នៃក្រមព្រហ្មទណ្ឌកម្ពុជា ចែងថា ការដាក់ឈ្មោះបទល្មើសដែលប្រព្រឹត្តដោយនីតិបុគ្គលថាជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ ត្រូវកំណត់ដោយទណ្ឌកម្មដែលទទួលរងដោយរូបវន្តបុគ្គល។

ក្រុមហ៊ុនមួយបង្កើតឡើងដែលមានភ្នាក់ងាររបស់គាត់ ឬមួយក៏តំណាងរបស់គាត់បានទៅធ្វើសកម្មភាពដើម្បីជាប្រយោជន៍ដូចជា ទៅប្រើប្រាស់នូវគ្រប់មធ្យោបាយនានា រៀបចំដើម្បីទៅធ្វើឱ្យសាធារណៈជនយល់ច្រឡំរួចក៏បង់នូវប្រាក់កាស ឬទ្រព្យសម្បត្តិផ្សេងៗ ដែលគាត់យកមកធ្វើជាប្រយោជន៍សម្រាប់នីតិបុគ្គល។ ដូច្នេះគឺយើងកំណត់ថា គាត់បានធ្វើអំពើឆបោកសាធារណៈជន ដែលធ្វើឡើងបែបនេះ គឺថានីតិបុគ្គលប្រព្រឹត្តបទល្មើស។ ប៉ុន្តែដើម្បីឱ្យនីតិបុគ្គលនេះអាចទទួលខុសត្រូវព្រហ្មទណ្ឌបាន ទាល់តែមានច្បាប់ ឬបទដ្ឋានគតិយុត្តចែងជាក់លាក់ថា នីតិបុគ្គលត្រូវទទួលខុសត្រូវព្រហ្មទណ្ឌ តែបើសិនជាមិនមានចែងទេ យើងមិនអាចឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ហើយមិនមែនអំពើទាំងអស់ដែលធ្វើឡើងមកនោះ គឺសុទ្ធតែឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌទេ។ នៅក្នុងក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ២០០៩ ចែងចំណុចពាក់ព័ន្ធទៅនឹងបទល្មើសមួយៗនោះ ដោយកំណត់ថា តើបទល្មើសណាខ្លះដែលនីតិបុគ្គលត្រូវទទួលខុសត្រូវ។ ផ្ទុយទៅវិញ បើសិនជាបទល្មើសណាមួយមិនមានចែងឱ្យនីតិបុគ្គលទទួលខុសត្រូវព្រហ្មទណ្ឌទេ គឺអត់ត្រូវដាក់ទណ្ឌកម្មព្រហ្មទណ្ឌទៅលើនីតិបុគ្គលនោះទេ។ នេះហើយ គឺជាលក្ខណ្ឌចាំបាច់មួយ ដែលត្រូវតែមានចែងនៅក្នុងច្បាប់យ៉ាងជាក់លាក់តែម្តង[98]។

**២ ការមិនទទួលខុសត្រូវរបស់នីតិបុគ្គលសាធារណៈ**

នីតិបុគ្គលសាធារណៈ គឺជាបុគ្គលអរូបដែលច្បាប់បង្កើតមកសម្រាប់បម្រើផលប្រយោជន៍សាធារណៈ និងសេវាកម្មសាធារណៈដោយមិនស្វែងរកប្រាក់ចំណេញ។ ប្រសិនបើនីតិបុគ្គលសាធារណៈ បានប្រព្រឹត្តនូវអំពើដែលផ្ទុយពីច្បាប់ ឬអាចនិយាយថាអំពើដែលច្បាប់មានចែងជាអំពើខុសច្បាប់ នីតិបុគ្គលនោះមិនត្រូវបានទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ ទោះបីជាមានការប្រព្រឹត្តបទល្មើសដោយតំណាងរបស់នីតិបុគ្គល ហើយវាជាផលប្រយោជន៍សម្រាប់នីតិបុគ្គលនោះក៏ដោយ ក៏មានលក្ខខណ្ឌពិសេសមួយទៀត ដែលអនុញ្ញាតឱ្យនីតិបុគ្គលសាធារណៈពិសេសនេះ មិនទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌដែរគឺរដ្ឋ។ រដ្ឋជានីតិបុគ្គលសាធារណៈ ដែលមិនទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌឡើយ។ ដូចនេះរដ្ឋជានីតិបុគ្គលពិសេសតែមួយគត់ ដែលមិនទទួលខុសត្រូវក្នុងរឿងព្រហ្មទណ្ឌ ដោយសាររដ្ឋជាអ្នកបង្កើតច្បាប់សម្រាប់ដាក់ទណ្ឌដល់បុគ្គលណា ដែលមិនប្រតិបត្តិតាមពោលរដ្ឋមិនបង្កើតច្បាប់ដាក់ទណ្ឌកម្មខ្លួនឯងឡើយ ហើយវាជាការងារសំខាន់មួយទៀត គឺរដ្ឋមានតួនាទីដឹកនាំ

[97] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ, (ភ្នំពេញ៖អង្គរ, ២០១៣),២០៤។

[98] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ, (ភ្នំពេញ៖អង្គរ, ២០១៣),២០៥។

កិច្ចការទាំងអស់នៅក្នុងប្រទេស ដែលរដ្ឋជាអ្នកទទួលខុសត្រូវលើបញ្ហាទាំងអស់ ដើម្បីរៀបចំសង្គម និងអភិវឌ្ឍន៍ប្រទេសជាតិឱ្យរីកចម្រើនជានិរន្តរ៍។ ប៉ុន្តែចំពោះសំណងរដ្ឋប្បវេណីវិញ រដ្ឋនៅតែមានកាតព្វកិច្ចសងសំណងទៅលើរាល់ការខូចខាតទាំងឡាយណា ដែលបណ្តាលមកពីអំពើតាមរយៈតំណាងរបស់ខ្លួន ក្នុងការបំពេញការងារក្នុងនាមរដ្ឋជាដាច់ខាត។ រដ្ឋ គឺជានីតិបុគ្គលពិសេសមួយដែលច្បាប់មិនឱ្យទទួលខុសត្រូវព្រហ្មទណ្ឌទេ ពីព្រោះថាច្បាប់ព្រហ្មទណ្ឌនៅក្នុងទោសបន្ថែម គឺអាចរំលាយនីតិបុគ្គលមួយចោលបាន។ ដូចនេះបើសិនជាឱ្យរំលាយនីតិបុគ្គលដែលជារដ្ឋ ឬប្រទេសមួយចោល ពេលនោះនឹងធ្វើឱ្យប៉ះពាល់អធិបតេយ្យជាតិ ដែលត្រូវបានការពារដោយរដ្ឋធម្មនុញ្ញជាក់ជាមិនខាន[99]។

[99] កៅ សីហា,នីតិព្រហ្មទណ្ឌទូទៅ, (ភ្នំពេញ៖អង្គរ, ២០១៣),២០៤។

# សេចក្តីសន្និដ្ឋាន

# សេចក្ដីសន្និដ្ឋាន

ជាការពិតណាស់ មនុស្សយើងគ្រប់ៗរូបកើតមករមែងតែងតែមានសិទ្ធិ និងកាតព្វកិច្ចមកជាមួយរៀងៗខ្លួន មិនថាក្នុងសង្គមនៅប្រទេសកម្ពុជាទេ គឺប្រជាជនទាំងអស់ទូទាំងពិភពលោកសុទ្ធតែមានសិទ្ធិស្មើៗភាពគ្នា។ តួយ៉ាងដូចដែលនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បានចែងថា "ប្រជាពលរដ្ឋខ្មែរមានភាពស្មើគ្នាចំពោះមុខច្បាប់ មានសិទ្ធិសេរីភាព និងករណីយកិច្ចដូចគ្នាទាំងអស់ ដោយឥតប្រកាន់ពូជសាសន៍ ពណ៌សម្បុរ ភេទ ភាសា ជំនឿសាសនា និន្នាការនយោបាយ ដើមកំណើតជាតិ ឋានៈសង្គម ធនធាន ឬ ស្ថានភាពឯទៀត ឡើយ។ ការប្រើសិទ្ធិសេរីភាពផ្ទាល់ខ្លួនរបស់បុគ្គលម្នាក់ៗ មិនត្រូវឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពអ្នកដទៃឡើយ។ ការប្រើសិទ្ធិសេរីភាពនេះ ត្រូវប្រព្រឹត្តតាមលក្ខខណ្ឌកំណត់ក្នុងច្បាប់"។ ប៉ុន្តែមានមនុស្សមួយចំនួនតូចមានភាព លោភលន់ក្នុងការប្រើប្រាស់សិទ្ធិដែលខ្លួនមាន ហើយថែមទាំងឈានទៅដល់ការប្រើប្រាស់សិទ្ធិរបស់ខ្លួនទៅ បំពានលើអ្នកដទៃ ដែលបង្កអសន្តិសុខដល់សង្គម គ្មានសណ្ដាប់ធ្នាប់ និងគ្មានរបៀបរៀបរយជាដើម។ ហេតុ ដូច្នេះហើយទើបបានជាគេបង្កើតឡើងនូវក្រមព្រហ្មទណ្ឌ ដើម្បីរក្សានូវសិទ្ធិសេរីភាពរបស់បុគ្គលដែលត្រូវបានគេ បំពានមកលើខ្លួន ក៏ដូចជាការពារ ឬទប់ស្កាត់នូវអំពើណាដែលមានលក្ខណៈឈ្លានពានអំពើដែលមិនគប្បីនៅ ក្នុងសង្គម ដូចជាការគំរាមកំហែងដល់អ្នកទន់ខ្សោយជាង ការគៀបសង្កត់នូវសិទ្ធិសេរីភាពរបស់អ្នកទន់ខ្សោយ មិន ថាអំពើនោះជាអំពើចេតនា ឬអចេតនានោះឡើយ។

ដូចនេះការស្រាវជ្រាវលើប្រធានបទនេះបានផ្ដល់នូវផលប្រយោជន៍ ការយល់ដឹង និងការបកស្រាយបានទូលាយស្ដីអំពី "**ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ**"។ នៅក្នុងនេះផងដែរមានមូលហេតុនៃការមិនទទួលខុសត្រូវព្រហ្មទណ្ឌ មានលក្ខណៈដូចជា ភាពដែលមិនអាចទម្លាក់កំហុស បាន គឺមានន័យថា ចារីដែលប្រព្រឹត្តបទល្មើសនោះគឺមាន វិបត្តិវិបល្លាសស្មារតីនៅពេលប្រព្រឹត្តបទល្មើស នៅក្នុងក្រមព្រហ្មទណ្ឌថ្មីពុំបានកម្រិតដាក់ទណ្ឌកម្មទៅលើបុគ្គលណាដែលប្រព្រឹត្តបទល្មើស នៅពេលដែលខ្លួនមានវិបត្តិ វិបល្លាសស្មារតីឡើយ នេះគឺមានន័យថាបុគ្គលនោះមិនទទួលខុសត្រូវព្រហ្មទណ្ឌឡើយ។ មូលហេតុដែលជាការ បញ្ជាដោយច្បាប់ ដោយអាជ្ញាធរទៅលើស្ថានភាពចាំបាច់ និងការការពារដោយស្របច្បាប់ (យុត្តិកម្មនៃ បទល្មើស) អំពើទាំងនេះក៏អាចរួចផុតពីការទទួលខុសត្រូវបាន ក៏ព្រោះតែវាសុទ្ធសឹងតែជាករណីដែលឱ្យគោរព តាមលក្ខខណ្ឌនៃច្បាប់បានកំណត់មក។ លើសពីនេះទៅទៀតការការពារស្របច្បាប់ក៏អាចរួចផុតពីការទទួល ខុសត្រូវព្រហ្មទណ្ឌបានដែរ ដូចជាការការពារខ្លួន ការពារអ្នកដទៃ ឬការការពារទ្រព្យ សម្បត្តិប្រឈមមុខនឹងការ ឈ្លានពានមួយដែលមិនត្រឹមត្រូវក្នុងករណីនេះគឺចង់រក្សាការពារនៃការឈ្លានពានណាមួយដែលមិនត្រឹមត្រូវមួយ ដូច្នេះបុគ្គលដែលតបតទៅនឹងតតិយជនដែលកំពុងរងនូវការឈ្លានពាននោះ គឺមិនត្រូវបានទទួលខុសត្រូវ ព្រហ្មទណ្ឌឡើយ ។

សរុបមកវិញនៅក្នុងសារណានេះគឺផ្តោតសំខាន់ទៅលើការមិនទទួលខុសត្រូវព្រហ្មទណ្ឌ យើងអាចបញ្ជាក់ឱ្យឃើញថាអំពើ ឬបទល្មើសទាំងអស់គឺមិនមែនសុទ្ធសឹងតែត្រូវការទទួលខុសត្រូវទាំងអស់ឡើយ អំពើខ្លះបុគ្គលបានប្រព្រឹត្តដោយមិនបានយល់ដឹងច្បាស់ថាជាអំពើល្មើសនឹងច្បាប់ អំពើខ្លះទៀតបានប្រព្រឹត្តឡើង ក្នុងគោលបំណងក្នុងការការពារ បង្ការ ឬទប់ស្កាត់ នូវគ្រោះថ្នាក់ទាំងឡាយណាដែលរៀបនឹងកើតមានឡើងដែលនឹងអាចគ្រោះថ្នាក់ដល់រូបរាងកាយ ឬអាចឈានទៅដល់ការបាត់បង់ជីវិតជាដើម។

# អនុសាសន៍

# អនុសាសន៍

គ្រប់បញ្ហា និងដំណោះស្រាយទៅលើបញ្ហាគ្រប់ផ្នែកទាំងអស់ដែលបានរៀបរាប់ខាងលើនេះ ទោះបីជាច្បាប់បានចែងយ៉ាងជាក់ច្បាស់ ទៅលើបញ្ហាគតិយុត្តនីមួយៗ ក្នុងការទាញយកហេតុផលសមស្របក្នុងការឱ្យចារីរួចផុតពីការមិនទទួលខុសត្រូវព្រហ្មទណ្ឌហើយ ច្បាប់ពិតជាអនុញ្ញាត ឱ្យបុគ្គលណាដែលបានប្រព្រឹត្តបទល្មើសណាមួយដែលមានហេតុផលសមស្រប គឺមិនទទួលខុសត្រូវព្រហ្មទណ្ឌក៏ពិតមែន ប៉ុន្តែនៅជុំវិញបញ្ហា គតិយុត្តទាំងអស់នេះរាជរដ្ឋាភិបាល ក៏ដូចជាអ្នកនីតិប្បញ្ញត្តិ គួរតែមានវិធានការបន្ថែម ទៅបញ្ហាគតិយុត្តខាងលើនេះបន្ថែមទៀតដើម្បីទប់ស្កាត់ភាគរយនៃការកើនឡើងនៃចំនួនបទល្មើសដដែលជារៀងរាលថ្ងៃ។ បញ្ហា គតិយុត្តខាងលើបទល្មើសមួយចំនួនសមស្រប ក្នុងការដែលឱ្យចារីមិនទទួលខុសត្រូវព្រហ្មទណ្ឌដោយ មានករណីដូចជាៈ បទល្មើសដែលកើតចេញពីជនវិបល្លាសស្មារតី អានុភាពនៃកម្លាំង ឬការបង្ខំណាមួយដែល មិនអាចមើលឃើញ និងប៉ាន់ស្មានដឹងបានជាមុនទាល់តែសោះ ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរស្រប ច្បាប់ ការការពារស្របច្បាប់ក្នុងស្ថានភាពចាំបាច់ណាមួយ។ ប៉ុន្តែបើយើងសង្កេតទៅបទល្មើសដែលកើត ចេញពីអនីតិជនវិញ វាហាក់ដូចជាមិនសូវសមស្របទាល់តែសោះ ក្នុងការលើកលែងឱ្យចារីដែលជាអនីតិជនមិនទទួលខុសត្រូវរាល់អំពើល្មើសរបស់ខ្លួនទៅវិញ។ វាពិតជាអយុត្តិធម៌ខ្លាំងបំផុតសម្រាប់ជនរងគ្រោះ បើ ទោះបីជាតុលាការ មានវិធានការមួយចំនួនសម្រាប់អនុវត្តទៅលើអនីតិជនក៏ដោយ ក៏នៅតែគ្មានភាពវិសមាមាត្រ រវាងជនរងគ្រោះដែរ។ ជាក់ស្តែងបទល្មើសឃាតកម្មដោយអចេតនា បានបណ្តាលឱ្យជនរងគ្រោះស្លាប់បាត់ជីវិត ជារៀងរហូត ចំណែកចារីដែលជាអនីតិជនបែរជាមិនទទួលខុសត្រូវព្រហ្មទណ្ឌទៅវិញ ដោយសារតែចារី ពុំទាន់ដល់ នីតិភាពក្នុងការទទួលទណ្ឌកម្មទៅវិញ ដោយគ្រាន់តែឪពុកម្តាយ ឬអាណាព្យាបាលរបស់ចារីដែលជា អនីតិជន នោះសងជាសំណងរដ្ឋប្បវេណីទៅគ្រួសារជនរងគ្រោះតែប៉ុណ្ណោះ។ ដំណោះស្រាយក្នុងបញ្ហាគតិយុត្ត នេះ គួរតែបង្កើតឱ្យមានតុលាការអនីតិជនផ្សព្វផ្សាយច្បាប់ដែលពាក់ព័ន្ធអនីតិជនឱ្យបានទូលំទូលាយ ពង្រឹង នីតិវិធីក្នុងការអនុវត្តទណ្ឌកម្មទៅលើអនីតិជនឱ្យបានគ្រប់ដំណាក់កាល យ៉ាងសុក្រឹតបំផុតទៅតាមប្រភេទបទ ល្មើស និងជាពិសេសគួរតែបង្កើតឱ្យមានពន្ធនាគារសម្រាប់ចារី ដែលជាអនីតិជនឱ្យនៅដាច់ដោយឡែកពីចារីដែលជានីតិជន។

# ឯកសារយោង

## ឯកសារយោង

### ១. សៀវភៅទ្រឹស្តី

- មេធាវី កៅ សីហា ទោសព្រហ្មទណ្ឌ ឆ្នាំ២០១៣
- សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ,ចៅក្រម ចាំង ស៊ីណាត នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០១២
- សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ,ចៅក្រម ចាំង ស៊ីណាត នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០០៤
- មេធាវី ជ្រ សុភារ៉ា ឯកសារជំនួយស្មារតីនីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០២០
- សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ,ចៅក្រម ចាំង ស៊ីណាត នីតិព្រហ្មទណ្ឌទូទៅ ឆ្នាំ២០១១
- សហប្រតិបត្តិការបារាំងលើគម្រោងទ្រទ្រង់នីតិរដ្ឋ និងរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ មេរៀនក្រមព្រហ្មទណ្ឌឆ្នាំ២០០៧
- សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ,ចៅក្រម ចាំង ស៊ីណាត នីតិព្រហ្មទណ្ឌទូទៅ នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ ឆ្នាំ២០១២។

### ២. ច្បាប់ និងលិខិតបទដ្ឋានជាតិ និងអន្តរជាតិ

- ព្រះរាជក្រមលេខ នស/ រកម/ ០២០៨/ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញ
- ព្រះរាជក្រមលេខ នស/ រ១១០៩ /០២២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩ ប្រកាសឱ្យប្រើក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រមលេខ នស/រកម/ ០៨០៧/ ០២៤/ ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០០៧ ប្រកាសឱ្យប្រើក្រមនីតិវិធីព្រហ្មទណ្ឌសនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រមលេខ នស/រកម/១២០៧/០៣០ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ប្រកាសឱ្យប្រើ ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា
- ព្រះរាជក្រមលេខ នស/ រកម/ ០៧១៦/ ០០៩ ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២០១៦ ប្រកាសឱ្យប្រើច្បាប់ស្តីពីយុត្តិធម៌អនីតិជន
- ក្រមព្រហ្មទណ្ឌបារាំង ប្រកាសឱ្យប្រើនៅថ្ងៃទី២២ ខែកក្កដា ឆ្នាំ១៩៩១។

### ៣. ឯកសារផ្សេងៗ

- សារណាបញ្ចប់ការសិក្សា ឆ្នាំ២០២៣ និស្សិតឈ្មោះ ឡុង សុវណ្ណមុន្នីរ័ត្ន ណែនាំដោយសាស្ត្រាចារ្យ ជួន ប៊ុនធី
- សារណាបញ្ចប់ការសិក្សា ឆ្នាំ២០១៩ និស្សិតឈ្មោះ កែវ ពិសិដ្ឋ និងឈ្មោះ ទូច ចរិយា ណែនាំដោយសាស្ត្រាចារ្យ ហោ សុភ័ណ្ឌ

- សារណាបញ្ចប់ការសិក្សា ឆ្នាំ២០២១ និស្សិតឈ្មោះ កែវ សែហ្មុង និងឈ្មោះ ស្លេះ ម៉ារ៉ាអ៊ី ណែនាំដោយសាស្ត្រាចារ្យ ជ្រ សុភារ៉ា
- សារណាបញ្ចប់ការសិក្សា ឆ្នាំ២០២៣ និស្សិតឈ្មោះ អាន កុលធីតា និងឈ្មោះ ព្រាប កលសម្បត្តិមេធានី ណែនាំដោយសាស្ត្រាចារ្យ ជួន ប៊ុនធី
- សារណាបញ្ចប់ការសិក្សា ឆ្នាំ២០១៦ និស្សិតឈ្មោះ សុជា រស្មី និងឈ្មោះ អៀង វណ្ណៈ។

**៤.វចនានុក្រម និងសន្ទានុក្រម**

- វចនានុក្រមខ្មែរសម្តេចសង្ឃរាជ ជួន ណាត ចេញផ្សាយដោយវិទ្យាស្ថានពុទ្ធសាសនាបណ្ឌិតឆ្នាំ១៩៦៧
- សន្ទានុក្រមពាក្យច្បាប់ ផ្នែកព្រហ្មទណ្ឌ ទីស្តីការគណរដ្ឋមន្ត្រីបោះពុម្ព ឆ្នាំ២០១១។

# តារាងឧបសម្ព័ន្ធ

| លេខរៀង | កម្មវត្ថុ | ផ្សេងៗ |
|---|---|---|
| ១ | ក្រមព្រហ្មទណ្ឌ | |
| ២ | ក្រមនីតិវិធីព្រហ្មទណ្ឌ | |
| ៣ | ក្រមរដ្ឋប្បវេណី | |
| ៤ | ក្រមព្រហ្មទណ្ឌបារាំង | |

# ឧបសម្ព័ន្ធ

# ក្រមព្រហ្មទណ្ឌ

## ព្រះរាជក្រម

នស/រកម/១១០៩/០២២

## យើង

## ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
## សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមររដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
## ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
## ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

-បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែកញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យ ប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/១៩៦/០៤ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌

-បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និងរដ្ឋមន្ត្រី ក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី ១២ ខែតុលា ឆ្នាំ ២០០៩ នាសម័យប្រជុំរដ្ឋសភាលើកទី ៣ នីតិកាលទី ៤ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃច្បាប់នេះ ទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី ១៧ ខែវិច្ឆិកា ឆ្នាំ ២០០៩ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៦ នីតិកាលទី ២ ហើយ ដែលមានសេចក្តីទាំងស្រុង ដូចតទៅនេះ :

២-ពលរដ្ឋទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត មានន័យថា ជាសមាជិកព្រឹទ្ធសភា រដ្ឋសភា ក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ និងសមាជិកក្រុមប្រឹក្សាឃុំ សង្កាត់ ព្រមទាំងពលរដ្ឋដែលទទួលអាណត្តិសាធារណៈដោយការបោះឆ្នោត ដើម្បីបំពេញមុខងារសាធារណៈផ្សេងទៀត ។

## ជំពូកទី ២
## មូលហេតុនៃការមិនទទួលខុសត្រូវ ឬការសម្រាលនូវការទទួលខុសត្រូវព្រហ្មទណ្ឌ

**មាត្រា ៣១.-** ការមិនទទួលខុសត្រូវដោយសារមូលហេតុវិបល្លាសស្មារតី

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលធ្វើឱ្យបាត់បង់នូវការដឹងខុសត្រូវរបស់ខ្លួន ជននោះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដែលបន្ថយនូវការដឹងខុសត្រូវរបស់ខ្លួន ជននោះនៅតែទទួលខុសត្រូវព្រហ្មទណ្ឌដដែល ។ ប៉ុន្តែ តុលាការត្រូវគិតគូរអំពីបញ្ហានេះ កាលណាតុលាការកំណត់ទោស ។

កាលបើជនណាម្នាក់ប្រព្រឹត្តបទល្មើស នៅពេលដែលជននោះកើតវិបល្លាសស្មារតី ដោយសារការប្រើប្រាស់គ្រឿងស្រវឹង គ្រឿងញៀន ឬសារធាតុដែលច្បាប់ហាមឃាត់ មិនអាចរួចផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌឡើយ ។

**មាត្រា ៣២.-** ការអនុញ្ញាតដោយច្បាប់ ឬអាជ្ញាធរ

បុគ្គលណាដែលប្រព្រឹត្តអំពើដែលបានបញ្ញត្ត ឬអនុញ្ញាតតាមច្បាប់ បុគ្គលនោះ មិនប្រព្រឹត្តបទល្មើសទេ ។

បុគ្គលណាដែលប្រព្រឹត្តអំពើតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ បុគ្គលនោះមិនប្រព្រឹត្តបទល្មើសទេ លើកលែងតែអំពើនេះជាអំពើខុសច្បាប់យ៉ាងជាក់ច្បាស់ ។

ប៉ុន្តែ ចារី សហចារី អ្នកផ្តើមគំនិត ឬអ្នកសមគំនិតក្នុងបទប្រល័យពូជសាសន៍ បទឧក្រិដ្ឋប្រឆាំងនឹងមនុស្សជាតិ ឬបទឧក្រិដ្ឋសង្គ្រាម មិនអាចលើកលែងឱ្យផុតពីការទទួលខុសត្រូវព្រហ្មទណ្ឌរបស់ខ្លួនទេ ទោះបីជាក្នុងករណីមានមូលហេតុដូចខាងក្រោមក៏ដោយ :

១-ជនល្មើសនោះបានប្រព្រឹត្តអំពើដែលបញ្ញត្ត អនុញ្ញាត ឬមិនហាមឃាត់ដោយច្បាប់ជាធរមាន ។

២-បុគ្គលនោះបានប្រព្រឹត្តតាមបញ្ជារបស់អាជ្ញាធរស្របច្បាប់ ។

**មាត្រា ៣៣.-** ការការពារស្របច្បាប់

បុគ្គលណាដែលប្រព្រឹត្តបទល្មើសក្នុងសភាពការការពារស្របច្បាប់ មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ការការពារស្របច្បាប់ ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវចាត់ទុកថាត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិប្រឈមមុខនឹងការឈ្លានពានមួយដែលមិនត្រឹមត្រូវ

-បទល្មើស និងការឈ្លានពាន ត្រូវតែកើតឡើងក្នុងពេលជាមួយគ្នា និង

-គ្មានវិសមាមាត្រ រវាងមធ្យោបាយការពារដែលប្រើប្រាស់ និងទម្ងន់នៃការឈ្លានពាន ។

**មាត្រា ៣៤.-** សច្ចធារណីនៃការការពារស្របច្បាប់

ត្រូវសន្មតថាជាការការពារស្របច្បាប់ នៅក្នុងករណីដូចតទៅ :

១-បទល្មើសត្រូវបានប្រព្រឹត្ត ដើម្បីរុញច្រានការចូលក្នុងពេលយប់ ដោយការកាប់គាស់ទម្លុះទម្លាយ ដោយហិង្សា ឬដោយកលល្បិចនៅក្នុងទីកន្លែងដែលមានមនុស្សនៅ ។

២-បទល្មើសបានប្រព្រឹត្ត ដើម្បីការពារខ្លួនប្រឆាំងនឹងការលួច ឬការប្លន់ដែលអនុវត្តដោយហិង្សា ។

សច្ចធារណីនៃការការពារស្របច្បាប់ ពុំមានលក្ខណៈដាច់ខាតទេ ។ សច្ចធារណីនេះ អាចត្រូវរំលាយដោយភស្តុតាងផ្ទុយ ។

**មាត្រា ៣៥.-** ស្ថានភាពចាំបាច់

បុគ្គលដែលស្ថិតនៅក្នុងការចាំបាច់ត្រូវតែប្រព្រឹត្តបទល្មើស មិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

ស្ថានភាពចាំបាច់ត្រូវមានលក្ខខណ្ឌដូចខាងក្រោមនេះ :

-បទល្មើសត្រូវបានចាត់ទុកថា ត្រឹមត្រូវដោយការចាំបាច់ដើម្បីការពារខ្លួន ការពារអ្នកដទៃ ឬការពារទ្រព្យសម្បត្តិ ប្រឆាំងនឹងគ្រោះថ្នាក់ដែលកំពុងកើតមាន ឬដែលនឹងកើតមាន និង

-គ្មានវិសមាមាត្ររវាងមធ្យោបាយការពារនិងទម្ងន់នៃគ្រោះថ្នាក់ ។

**មាត្រា ៣៦.-** អានុភាពនៃកម្លាំង ឬការបង្ខិ

បុគ្គលដែលប្រព្រឹត្តបទល្មើសក្រោមអានុភាពនៃកម្លាំង ឬការបង្ខិ ដែលបុគ្គលនេះ មិនអាចទប់ទល់បាន បុគ្គលនេះមិនទទួលខុសត្រូវព្រហ្មទណ្ឌទេ ។

កម្លាំង និងការបង្ខិ អាចចេញមកពីព្រឹត្តិការណ៍ក្រៅឆន្ទៈរបស់មនុស្សតែប៉ុណ្ណោះ ។ កម្លាំង និងការបង្ខិនេះត្រូវតែមិនអាចមើលឃើញជាមុនបាន និងមិនអាចជៀសវាងបាន ។

**មាត្រា ៣៧.-** ការមិនទទួលខុសត្រូវព្រហ្មទណ្ឌ

បុគ្គលដែលមិនទទួលខុសត្រូវព្រហ្មទណ្ឌ មិនត្រូវទទួលទណ្ឌកម្មព្រហ្មទណ្ឌណាមួយទេ ។

## ជំពូកទី ៣

## ការទទួលខុសត្រូវព្រហ្មទណ្ឌរបស់អនីតិជន

**មាត្រា ៣៨.-** នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ

នីតិភាពនៃការទទួលខុសត្រូវព្រហ្មទណ្ឌ ត្រូវបានកំណត់អាយុចាប់ពី ១៨ (ដប់ប្រាំបី) ឆ្នាំ ឡើងទៅ ។

# ជំពូកទី ៦
# ទោសដែលអាចអនុវត្តចំពោះអនីតិជន
## ផ្នែកទី ១
## បទប្បញ្ញត្តិទូទៅ

**មាត្រា ១៦០.-** មូលទោសអនុវត្តចំពោះអនីតិជនអាយុចាប់ពី ១៤ ឆ្នាំ ឡើងទៅ

កាលណាតុលាការ សម្រេចផ្តន្ទាទោសព្រហ្មទណ្ឌទៅលើអនីតិជនអាយុចាប់ពី ១៤ (ដប់បួន) ឆ្នាំ ឡើងទៅ មូលទោសលើបទល្មើសដែលចោទប្រកាន់ ត្រូវបាន បន្ថយក្នុងលក្ខខណ្ឌដូចតទៅ :

១-អតិបរមានៃទោសដាក់ពន្ធនាគារត្រូវបន្ថយពាក់កណ្តាល ។

២-ប្រសិនបើអតិបរមានៃទោសនោះ គឺជាទោសដាក់ពន្ធនាគារអស់មួយជីវិត អតិបរមាត្រូវបន្ថយមកដាក់ពន្ធនាគារ ២០ (ម្ភៃ) ឆ្នាំ ។

៣-អប្បបរមានៃទោសដាក់ពន្ធនាគារ ត្រូវបន្ថយពាក់កណ្តាល ប្រសិនបើ អប្បបរមានេះលើសពី ១ (មួយ) ថ្ងៃ ។

៤-អប្បបរមា និងអតិបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្តាល ។

ក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ប្រសិនបើបទប្បញ្ញត្តិនៃមាត្រានេះមាន អានុភាពបន្ថយអតិបរមានៃទោសដាក់ពន្ធនាគារមកត្រឹមថិរវេលាមួយស្មើ ឬតិចជាង ៥ (ប្រាំ) ឆ្នាំ នោះបទល្មើសដែលចោទប្រកាន់នៅតែជាបទឧក្រិដ្ឋដដែល ។

**មាត្រា ១៦១.-** ទោសបន្ថែម

មានតែទោសបន្ថែមដូចតទៅនេះប៉ុណ្ណោះ ដែលអាចអនុវត្តទៅលើអនីតិជន :

១-ការរឹបអូសឧបករណ៍ សម្ភារៈ ឬវត្ថុអ្វីមួយដែលបានប្រើក្នុងការប្រព្រឹត្ត បទល្មើស ឬដែលមានគោលដៅប្រព្រឹត្តបទល្មើស ។

២-ការរឹបអូសវត្ថុ ឬមូលនិធិដែលជាកម្មវត្ថុនៃបទល្មើស ។

៣-ការរឹបអូសផលទុន ឬទ្រព្យសម្បត្តិដែលជាផលកើតចេញពីបទល្មើស ។

៤-ការរឹបអូសឧបភោគភណ្ឌ សម្ភារៈ ឬចលនវត្ថុនៅក្នុងទីកន្លែងដែលបទល្មើសត្រូវបានប្រព្រឹត្ត ។

៥-ការហាមឃាត់ចំពោះការកាន់កាប់ ឬការយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។

**មាត្រា ១៦២.-** ទោសការងារសហគមន៍

ទោសដែលជាការងារសហគមន៍ អាចអនុវត្តទៅលើអនីតិជនដែលមានអាយុយ៉ាងតិច ១៦ (ដប់ប្រាំមួយ) ឆ្នាំ ប៉ុន្តែ ចិរវេលានៃការងារមិនអាចលើសពី ១០០ (មួយរយ) ម៉ោង ។

ការងារសហគមន៍ត្រូវតែសម្របសម្រួលទៅលើអនីតិជន មានលក្ខណៈជាការបណ្ដុះបណ្ដាល និងសម្រួលដល់ការបញ្ចូលខ្លួនទៅរស់នៅក្នុងសង្គមវិញ ។

**មាត្រា ១៦៣.-** ការមិនអនុវត្តបទប្បញ្ញត្តិស្ដីពីការមិនរាងចាល

បទប្បញ្ញត្តិស្ដីពីការមិនរាងចាល មិនអនុវត្តទៅលើអនីតិជនទេ ។

**មាត្រា ១៦៤.-** ការទទួលប្រយោជន៍នៃស្ថានសម្រាលទោស

ស្ថានសម្រាលទោសត្រូវអនុវត្តទៅលើអនីតិជន ។

កាលបើតុលាការបានសម្រេចឱ្យមានស្ថានសម្រាលទោស អប្បបរមានៃមូលទោស លើអនីតិជនពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ត្រូវបន្ថយតាមខ្នាតដោយឡែកដូចតទៅ :

១-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកនៅត្រឹម ១ (មួយ) ឆ្នាំ ។

២-ប្រសិនបើអប្បបរមានៃទោសជាប់ពន្ធនាគារស្មើ ឬលើសពី ៥ (ប្រាំ) ឆ្នាំ និងតិចជាង ១០ (ដប់) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៦ (ប្រាំមួយ) ខែ ។

៣-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ២ (ពីរ) ឆ្នាំ និងតិចជាង ៥ (ប្រាំ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយមកត្រឹម ៣ (បី) ខែ ។

៤-ប្រសិនបើអប្បបរមានៃទោសដាក់ពន្ធនាគារស្មើ ឬលើសពី ៦ (ប្រាំមួយ) ថ្ងៃ និងតិចជាង ២ (ពីរ) ឆ្នាំ នោះអប្បបរមា ត្រូវបន្ថយត្រឹម ១ (មួយ) ថ្ងៃ ។

៥-អប្បបរមានៃទោសពិន័យជាប្រាក់ ត្រូវបន្ថយពាក់កណ្ដាល ។

**មាត្រា ១៦៥.-** កាតព្វកិច្ចដោយឡែកក្នុងករណីនៃការព្យួរទោសសាកល្បង

នៅក្នុងករណីនៃការព្យួរទោសសាកល្បង មានតែកាតព្វកិច្ចដោយឡែកដូចតទៅនេះប៉ុណ្ណោះដែលអាចអនុវត្តទៅលើអនីតិជន :

១-ទទួលការបង្ហាត់បង្រៀន ឬការបណ្ដុះបណ្ដាលវិជ្ជាជីវៈ ។

២-ស្ថិតនៅទីកន្លែងមួយជាកំណត់ ។

៣-ដាក់ខ្លួនឱ្យពេទ្យពិនិត្យ ឬព្យាបាល ។

៤-ជួសជុលល្យសនកម្មដែលបណ្ដាលមកអំពីបទល្មើស ទៅតាមធនធានរបស់ខ្លួន ។

៥-បង្ហាញភស្តុតាង បញ្ជាក់ថាខ្លួនបង់ទឹកប្រាក់ដែលជំពាក់ជូនរដ្ឋរួចហើយ តាមលទ្ធភាពនៃធនធានរបស់ខ្លួន បន្ទាប់ពីការផ្ដន្ទាទោស ។

៦-មិនត្រូវបង្ហាញមុខនៅទីកន្លែងខ្លះ ។

៧-មិនត្រូវសេពគប់ ទីកន្លែងលក់ភេសជ្ជៈស្រវឹង ។

៨-មិនត្រូវសេពគប់ជាមួយបុគ្គលខ្លះ ដោយឡែកជាមួយសហចារី អ្នកផ្ដើមគំនិត អ្នកសមគំនិត ឬជនរងគ្រោះនៃបទល្មើស ។

៩-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ។ជ

## ផ្នែកទី ២

## បទប្បញ្ញត្តិដោយឡែក

**មាត្រា ១៦៦.-** លក្ខខណ្ឌនៃការឃុំខ្លួនអនីតិជនក្នុងពន្ធនាគារ

អនីតិជនដែលជាប់ពន្ធនាគារ ត្រូវឃុំខ្លួននៅទីកន្លែងពិសេស ខណ្ឌដាច់ពីនីតិជន ។ អនីតិជនស្ថិតនៅក្រោមរបបដោយឡែកជាឯកត្តបុគ្គល ដែលជាទីកន្លែង

# ក្រមនីតិវិធីព្រហ្មទណ្ឌ

នស/រកម/០៨០៧/០២៤

# ព្រះរាជក្រម

## យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចនាយករដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា និង រដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមនីតិវិធីព្រហ្មទណ្ឌ ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៧ ខែមិថុនា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី ៦ នីតិកាលទី ៣ និងដែលព្រឹទ្ធសភាបានយល់ស្របតាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៣ នីតិកាលទី ២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ ៖

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL •

34/2007

# គន្ថីទី ៣
# ការស៊ើបអង្កេត
## មាតិកាទី ១
## បទប្បញ្ញត្តិទូទៅ
### ជំពូកទោល
### បទប្បញ្ញត្តិទូទៅ

**មាត្រា ៨៣.** – ការសម្ងាត់នៃការស៊ើបអង្កេត

ការស៊ើបអង្កេត ត្រូវតែជាការសម្ងាត់ ។ បុគ្គលទាំងឡាយ ដែលចូលរួមក្នុងការស៊ើបអង្កេត ជាពិសេសចៅក្រមខាងអយ្យការ មេធាវី ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ មន្ត្រីរាជការ អ្នកជំនាញ អ្នកបកប្រែ គ្រូពេទ្យ និងបុគ្គលដែលមានសមត្ថកិច្ចដូចមានចែងក្នុងមាត្រា ៩៥ (ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ) នៃក្រមនេះ ត្រូវរក្សាការសម្ងាត់នៃវិជ្ជាជីវៈ ។

ប៉ុន្តែ ការគោរពនូវការសម្ងាត់វិជ្ជាជីវៈ មិនមែនជាឧបសគ្គដល់ការប្រើសិទ្ធិនៃការការពារខ្លួនឡើយ ។

ម្យ៉ាងទៀត ព្រះរាជអាជ្ញាត្រូវបានអនុញ្ញាតឱ្យធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈ កាលណាខ្លួនយល់ឃើញថាព័ត៌មានដែលផ្សព្វផ្សាយពីរឿងណាមួយនោះ ជាព័ត៌មានមិនពិត ។

ការបំពានលើការសម្ងាត់នៃការស៊ើបអង្កេត គឺជាបទល្មើសដែលត្រូវផ្តន្ទាទោសតាមច្បាប់ព្រហ្មទណ្ឌជាធរមាន ។

**មាត្រា ៨៤.** – ភាពខុសគ្នានៃអំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ទៅតាមការស៊ើបអង្កេត

អំណាចទាំងឡាយ ដែលផ្តល់ឱ្យមន្ត្រីនគរបាលយុត្តិធម៌ ខុសគ្នាទៅតាមពេលដែលមន្ត្រីនោះបំពេញការក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ឬក្នុងក្របខ័ណ្ឌនៃការស៊ើបអង្កេតបឋម ។

## មាតិកាទី ២
## ការស៊ើបអង្កេតករណីជាក់ស្តែង
### ជំពូកទី ១
### បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

**មាត្រា ៨៥.** – អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងករណីស៊ើបអង្កេតបទល្មើសជាក់ស្តែង

ក្នុងករណីមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែគោរពតាម

បទប្បញ្ញត្តិនៃមាតិកានេះ ។

**មាត្រា ៨៦.** – និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

បទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងគឺ :

-បទល្មើសដែលកំពុងប្រព្រឹត្ត

-បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម ។

ត្រូវចាត់ទុកថា ជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក :

-ជនដែលគេសង្ស័យ ត្រូវបានសាធារណជនស្រែកដេញប្រដាប់ចាប់ប្រកឹង

-បុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឱ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស ។

**មាត្រា ៨៧.** – ការចាប់ខ្លួនក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់អាចចាប់ខ្លួនជនល្មើសហើយនាំខ្លួនជននោះទៅប្រគល់ជូនមន្ត្រីនគរបាលយុត្តិធម៌ដែលនៅជិតបំផុត ។

**មាត្រា ៨៨.** – ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ត្រូវបានចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែងផងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងក្នុងមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) ខាងលើនេះក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬបទមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែងដែលអ្នកកាន់កាប់នៅទីនោះ សុំឱ្យព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធម៌នៅទីកន្លែងនោះ ។ ក្នុងករណីចុងក្រោយនេះ ភ្នាក់ងារនគរបាលយុត្តិធម៌ត្រូវរាយការណ៍ជាបន្ទាន់ជូនដល់មន្ត្រីនគរបាលយុត្តិធម៌ ។

## ជំពូកទី ២
## វិធានការស្រាវជ្រាវ

**មាត្រា ៨៩.** – វិធានការដំបូងក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង

ក្នុងករណីបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ។

មន្ត្រីនគរបាលយុត្តិធម៌ចុះទៅកាន់ទីកន្លែងកើតហេតុ ដើម្បីធ្វើការពិនិត្យបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ធានារ៉ាប់រងរក្សាទុកនូវតម្រុយនៃភស្តុតាងទាំងឡាយណាដែលអាចបាត់បង់ ។ មន្ត្រីនគរបាលយុត្តិធម៌ អាចហាមឃាត់បុគ្គលគ្រប់រូបកុំឱ្យទៅទីណាឆ្ងាយពីកន្លែងបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន ។

ប្រសិនបើយល់ឃើញថាមានប្រយោជន៍ ព្រះរាជអាជ្ញាចុះទៅកាន់កន្លែងកើតហេតុ និងដឹកនាំការស៊ើបអង្កេត ។

ប្រសិនបើមានការបន្ទាន់ ព្រះរាជអាជ្ញាអាចអនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ធ្វើប្រតិបត្តិការលើវិសាលភាពទាំងមូលនៃដែនដីជាតិ ដោយគោរពតាមលក្ខខណ្ឌទាំងឡាយដែលមានចែងក្នុងមាត្រា ៦៨ (ការពន្លាតសមត្ថកិច្ចដែនដី) នៃក្រមនេះ ។

**មាត្រា ៩០.** – កំណត់ហេតុលើការស្រាវជ្រាវ និងការពិនិត្យ

មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន ។

**មាត្រា ៩១.** – ការឆែកឆេរ

មន្ត្រីនគរបាលយុត្តិធម៌អាចធ្វើការឆែកឆេរបាន ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវទទួលជាបឋមនូវការអនុញ្ញាតពីព្រះរាជអាជ្ញា ទោះបីជាការអនុញ្ញាតដោយផ្ទាល់មាត់ក៏ដោយ ។

មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការឆែកឆេរនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬបើគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់ ។ សាក្សីត្រូវចាត់តាំងដោយមន្ត្រីនគរបាលយុត្តិធម៌ ។ សាក្សីមិនអាចជានគរបាល ឬក៏ជាកងរាជអាវុធហត្ថ ដែលជាកងកម្លាំងរួមប្រតិបត្តិការក្នុងការឆែកឆេរនោះបានឡើយ ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចផ្តើមធ្វើការឆែកឆេរមុនម៉ោង ៦ (ប្រាំមួយ) ព្រឹក និងក្រោយម៉ោង ១៨ (ដប់ប្រាំបី) ឡើយ លើកលែងតែ :

-ក្នុងករណីដែលមានចែងដោយមាត្រា ៨៦ (និយមន័យបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ

-ក្នុងករណីដែលចែងដោយមាត្រា ៨៨ (ការចាត់ទុកដូចជាបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង) នៃក្រមនេះ

-ក្នុងករណីមានសំរែកស្រែកឱ្យគេជួយពីក្នុងទីកន្លែង

-ក្នុងករណីឆែកឆេរនៅទីកន្លែងក្នុងពេលម៉ោងដែលបើកចំហដល់សាធារណជន

-ក្នុងករណីឆែកឆេរនៅគ្រប់ទីកន្លែងដែលផលិត រក្សាទុក ជួញដូរ ចែកចាយ

ប្រើប្រាស់ គ្រឿងញៀន ។

មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្តីពីការឆែកឆេរដែលនៅក្នុងនោះមានចុះ :

-ការអនុញ្ញាតរបស់ព្រះរាជអាជ្ញាដោយប្រាប់ថ្ងៃ និងម៉ោងនៃការអនុញ្ញាតនេះ

-អត្តសញ្ញាណរបស់អ្នកកាន់កាប់ទីកន្លែង ឬរបស់សាក្សីនីមួយៗ ។

មន្ត្រីនគរបាលយុត្តិធម៌ មិនអាចធ្វើការឆែកឆេរនៅក្នុងការិយាល័យមេធាវីបានទេ ។ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរតែប៉ុណ្ណោះ ដែលអាចធ្វើការឆែកឆេរនេះបាន នៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី ។

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរនៅក្នុងអគារសារព័ត៌មាន សហគ្រាសនៃសារព័ត៌មានសរសេរ ឬសហគ្រាសសារព័ត៌មានសោតទស្សន៍ បានតែចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលជានាវ៉ាប់រងកុំឱ្យការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឱ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះដោយមិនត្រឹមត្រូវ ។

**មាត្រា ៩២.** – ការបិទស្លាកបោះត្រាលើវត្ថុតាង

មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់យកវត្ថុតាង ។ មន្ត្រីនគរបាលយុត្តិធម៌ត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ ។

ក្រោយពីបានបង្ហាញវត្ថុដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើលរួច មន្ត្រីនគរបាលយុត្តិធម៌ ធ្វើកំណត់ហេតុស្តីពីការចាប់យក ដែលរួមមានបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់ ។ កំណត់ហេតុស្តីពីការចាប់យក ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយអ្នកកាន់កាប់ទីកន្លែង ឬដោយសាក្សីពីរនាក់ ។

**មាត្រា ៩៣.** – កំណត់ហេតុលើការស្តាប់ចម្លើយ

មន្ត្រីនគរបាលយុត្តិធម៌អាចហៅ និងនាំមកកាន់អង្គភាពរបស់ខ្លួននូវបុគ្គលគ្រប់រូបដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើការស្តាប់ចម្លើយជនទាំងនោះ ។

ការស្តាប់ចម្លើយនីមួយៗ ត្រូវមានធ្វើកំណត់ហេតុ ។

កំណត់ហេតុត្រូវដកស្រង់តាមដោយត្រឹមត្រូវ នូវសេចក្តីរាយការណ៍របស់បុគ្គលដែលផ្តល់ចម្លើយ ។ ក្នុងករណីចាំបាច់មន្ត្រីនគរបាលយុត្តិធម៌ អាចរកអ្នកបកប្រែដែលស្បថថា និយាយការពិត ស្របតាមជំនឿ ឬសាសនារបស់ខ្លួន ។ អ្នកបកប្រែមិនអាចជ្រើសរើសយកពីក្នុងចំណោមនគរបាល កងរាជអាវុធហត្ថ ឬបុគ្គលដែលទាក់ទិនក្នុងរឿងជាមួយគ្នាបានទេ ។

ទំព័រនីមួយៗនៃកំណត់ហេតុ ត្រូវចុះហត្ថលេខា ឬផ្តិតម្រាមដៃដោយបុគ្គលដែលបានឆ្លើយ ។

មុននឹងចុះហត្ថលេខា ឬផ្តិតស្រាមដៃ បុគ្គលនោះត្រូវអានកំណត់ហេតុឡើងវិញ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានដោយសំលេងខ្លាំងៗ នូវខ្លឹមសារកំណត់ហេតុ ។ មន្ត្រីនគរបាលយុត្តិធម៌ អាចហៅអ្នកបកប្រែបាន ។ កាលណាបុគ្គលនោះមិនព្រមចុះហត្ថលេខា ឬមិនព្រមផ្តិតស្រាមដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុ ។

**មាត្រា ៩៤.** – បទបញ្ជាឱ្យចូលខ្លួនក្នុងករណីការស៊ើបអង្កេតបទល្មើសជាក់ស្តែង

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបាន ។

បុគ្គលដែលកោះហៅនោះ ត្រូវចូលបង្ហាញខ្លួន ។ ក្នុងករណីរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឱ្យចូលខ្លួនបាន ។ បញ្ជាឱ្យចូលខ្លួននេះ ត្រូវមានអត្តសញ្ញាណរបស់បុគ្គលដែលពាក់ព័ន្ធ មានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយព្រះរាជអាជ្ញា និងមានបោះត្រាផង ។ បញ្ជាឱ្យចូលខ្លួន អនុញ្ញាតឱ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈដើម្បីបង្ខំបុគ្គលនោះ ឱ្យចូលបង្ហាញខ្លួន ។ កថាខណ្ឌទី ២ ដល់ទី ៥ នៃមាត្រា ៩៣ (កំណត់ហេតុលើការស្តាប់ចម្លើយ) នៃក្រមនេះ ត្រូវយកមកអនុវត្ត ។

**មាត្រា ៩៥.** – ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ

ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌អាចពឹងដល់បុគ្គលគ្រប់រូបដែលមានមុខជំនាញ ។ ប្រសិនបើបុគ្គលនោះមិនទាន់បានចុះឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញដូចចែងនៅមាត្រា ១៦៣ (បញ្ជីថ្នាក់ជាតិនៃអ្នកជំនាញ) នៃក្រមនេះទេ បុគ្គលនេះត្រូវស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយដោយភក្តីភាពដល់តុលាការ ។

## ជំពូកទី ៣
## ការឃាត់ខ្លួន

**មាត្រា ៩៦.** – ការឃាត់ខ្លួន

ដើម្បីឆ្លើយតបនឹងតម្រូវការចាំបាច់នៃការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ អាចឃាត់ខ្លួនបុគ្គលដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស ។ មន្ត្រីនគរបាលយុត្តិធម៌ក៏អាចឃាត់ខ្លួនបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបានដែរ ប្រសិនបើលក្ខខណ្ឌខាងក្រោមនេះត្រូវបានបំពេញ :

-បុគ្គលដែលអាចផ្តល់ព័ត៌មានប្រកែកមិនព្រមផ្តល់ព័ត៌មាន

-មានការយល់ព្រមជាលាយលក្ខណ៍អក្សរឱ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា ។

មន្ត្រីនគរបាលយុត្តិធម៌ត្រូវរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា ព្រមទាំងត្រូវបញ្ជូនគ្រប់ភស្តុតាងទាំងអស់ដែលតម្រូវឱ្យមានការឃាត់ខ្លួននេះ ។ ការឃាត់ខ្លួនមានថិរវេលា ៤៨ (សែសិបប្រាំបី) ម៉ោង ។ ថិរវេលាត្រូវចាប់គិតពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ។

ចំពោះបទឧក្រិដ្ឋ កាលណាមានតម្រុយដែលបង្ហាញឱ្យឃើញថា មានពិរុទ្ធភាពលើបុគ្គលដែលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌អាចពន្យារពេលឃាត់ខ្លួនបាន ប្រសិនបើវិធានការនេះជាការចាំបាច់ដើម្បីឱ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ ។ ការពន្យារពេលនេះត្រូវសុំទៅព្រះរាជអាជ្ញាដែលត្រូវផ្ទៀងផ្ទាត់មើលមូលកភាព ។ ការអនុញ្ញាតឱ្យពន្យារពេលឃាត់ខ្លួនដែលធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ត្រូវដាក់បញ្ចូលទៅក្នុងសំណុំរឿង ។ ការពន្យារគឺជាវិធានការពិសេស ។ ការពន្យារនេះមិនអាចឱ្យលើសពី ២៤ (ម្ភៃបួន) ម៉ោង ឡើយ ដោយមិនគិតពីថិរវេលាចាំបាច់ក្នុងការដឹកជញ្ជូន ។

ការពន្យារមិនអាចត្រូវយល់ព្រមបានទេ ប្រសិនបើបុគ្គលដែលឃាត់ខ្លួននោះ ជាអនីតិជន ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៤ ឆ្នាំ ដល់ ក្រោម ១៦ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ២៤ ម៉ោងឡើយ ។

ចំពោះបទឧក្រិដ្ឋ អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៤៨ ម៉ោងឡើយ ។

ចំពោះបទមជ្ឈិម អនីតិជនដែលមានអាយុពី ១៦ ឆ្នាំ ដល់ក្រោម ១៨ ឆ្នាំ មិនអាចត្រូវគេឃាត់ខ្លួនហួសរយៈពេល ៣៦ ម៉ោងឡើយ ។

អនីតិជនដែលមានអាយុក្រោម ១៤ ឆ្នាំ ពុំអាចត្រូវគេឃាត់ខ្លួនបានឡើយ ។

**មាត្រា ៩៧.** – កំណត់ហេតុស្ដីពីការឃាត់ខ្លួន

កាលណាមានការឃាត់ខ្លួនបុគ្គលណាមួយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវឱ្យដំណឹងជាបន្ទាន់អំពីសេចក្ដីសម្រេចរបស់ខ្លួនដល់បុគ្គលនោះ ដោយប្រាប់ឱ្យបានដឹងអំពីមូលហេតុនៃសេចក្ដីសម្រេចឃាត់ខ្លួននេះ ។ មន្ត្រីនគរបាលយុត្តិធម៌ប្រាប់ដល់សាមីខ្លួនឱ្យបានដឹងផងដែរ អំពីសិទ្ធិដែលបានចែងនៅមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ ។ ក្នុងករណីចាំបាច់ មន្ត្រីនគរបាលយុត្តិធម៌អាចហៅអ្នកបកប្រែ ។ មន្ត្រីនគរបាលយុត្តិធម៌ធ្វើកំណត់ហេតុស្ដីពីការឃាត់ខ្លួនជាបន្ទាន់ ដោយមានចុះសេចក្ដីដូចតទៅ :

-ឈ្មោះ និងឋានៈរបស់មន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណនៃបុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្តើមឃាត់ខ្លួន

-ការឱ្យដំណឹងអំពីសិទ្ធិដែលបានបញ្ញត្តនៃមាត្រា ៩៨ (ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន) នៃក្រមនេះ

-ជាយថាហេតុ ឈ្មោះអ្នកបកប្រែ ។

កំណត់ហេតុនេះត្រូវមានចុះហត្ថលេខា ឬផ្តិតស្រាមមេដៃរបស់ជនឃាត់ខ្លួន ក្រោយពីបានអានកំណត់ហេតុរួច ឬបើសាមីខ្លួនមិនចេះអក្សរ មន្ត្រីនគរបាលយុត្តិធម៌ត្រូវអានកំណត់ហេតុឱ្យស្តាប់ ។ ប្រសិនបើជននេះប្រកែកមិនព្រមចុះហត្ថលេខា ឬផ្តិតស្រាមមេដៃទេ មន្ត្រីនគរបាលយុត្តិធម៌ត្រូវចុះនិទ្ទេស ។ កំណត់ហេតុត្រូវភ្ជាប់ជាមួយសំណុំរឿង ។

**មាត្រា ៩៨.** – ជំនួយរបស់មេធាវីនៅក្នុងពេលឃាត់ខ្លួន

ក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុតទៅ តាំងពីពេលផ្តើមនៃការឃាត់ខ្លួនមកនោះ បុគ្គលដែលឃាត់ខ្លួន អាចសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ដែលខ្លួនជ្រើសរើស កុំឱ្យតែជននេះមានការទាក់ទិននៅក្នុងរឿងជាមួយ ។ ជននេះត្រូវបានទទួលដំណឹងពីការស្នើសុំជ្រើសរើសនេះ តាមគ្រប់មធ្យោបាយ និងជាបន្ទាន់ ។ ជននេះអាចចូលទៅកាន់កន្លែងឃាត់ខ្លួន និងទាក់ទងជាមួយបុគ្គលសាមីខ្លួនបាន ៣០ (សាមសិប) នាទី ក្នុងលក្ខខណ្ឌធានាការសម្ងាត់នៃការសន្ទនានេះ ។ ក្រោយការសន្ទនាជននេះ អាចធ្វើកំណត់សម្គាល់ជាលាយលក្ខណ៍អក្សរដែលត្រូវភ្ជាប់ជាមួយសំណុំរឿង។

**មាត្រា ៩៩.** – ជំនួយរបស់គ្រូពេទ្យនៅក្នុងពេលឃាត់ខ្លួន

ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ សុំឱ្យគ្រូពេទ្យមកពិនិត្យបុគ្គលដែលឃាត់ខ្លួនបានគ្រប់ពេលវេលា ។ គ្រូពេទ្យផ្ទៀងផ្ទាត់មើលថា តើស្ថានភាពសុខភាពនៃបុគ្គលឃាត់ខ្លួននេះ សមស្របនឹងការឃាត់ខ្លួនដែរឬទេ ។

ប្រសិនបើគ្រូពេទ្យយល់ឃើញថា ស្ថានភាពសុខភាពរបស់បុគ្គលនោះ ពុំសមស្របជាមួយនឹងការឃាត់ខ្លួនទេនោះ មន្ត្រីនគរបាលយុត្តិធម៌រាយការណ៍ជាបន្ទាន់ដល់ព្រះរាជអាជ្ញា ។ គ្រូពេទ្យចេញវិញ្ញាបនប័ត្របញ្ជាក់សុខភាពដែលត្រូវភ្ជាប់ជាមួយសំណុំរឿង ។ មន្ត្រីនគរបាលយុត្តិធម៌ ចុះនិទ្ទេសនៅលើកំណត់ហេតុអំពីឈ្មោះរបស់គ្រូពេទ្យ ព្រមទាំងថ្ងៃ ខែ ឆ្នាំ និងម៉ោងនៃការពិនិត្យ

សុខភាព ។

ព្រះរាជអាជ្ញាអាចចុះទៅកាន់ទីកន្លែងផ្ទាល់ ដើម្បីផ្ទៀងផ្ទាត់លក្ខខណ្ឌនៃការឃាត់ខ្លួន ។

**មាត្រា ១០០.** – អនីតិជនដែលត្រូវបានឃាត់ខ្លួន

កាលណាបុគ្គលដែលត្រូវបានឃាត់ខ្លួនជាអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ឪពុក ម្ដាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកទទួលភារកិច្ចលើអនីតិជននេះ ។

**មាត្រា ១០១.** – បញ្ជីនៃការឃាត់ខ្លួន

នៅក្នុងកន្លែងនីមួយៗ របស់នគរបាល ឬកងរាជអាវុធហត្ថ ដែលសម្រាប់ទទួលជនដែលត្រូវឃាត់ខ្លួន ត្រូវមានបញ្ជីស្ដីពីការឃាត់ខ្លួនមួយ ។

គ្រប់ការឃាត់ខ្លួនត្រូវមានចុះនៅក្នុងបញ្ជីដោយមានសេចក្ដីដូចតទៅនេះ :

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបានបង្គាប់ឱ្យធ្វើការឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលចាប់ផ្ដើមឃាត់ខ្លួន និងបញ្ចប់ការឃាត់ខ្លួន

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលបានអនុញ្ញាតឱ្យបន្តការឃាត់ខ្លួន ជាយថាហេតុ

-ឈ្មោះរបស់គ្រូពេទ្យដែលបានពិនិត្យបុគ្គលឃាត់ខ្លួន ជាយថាហេតុ

-ប្រភេទនៃសេចក្ដីសម្រេចរបស់អាជ្ញាធរតុលាការនៅពេលផុតកំណត់ការឃាត់ខ្លួន ។

បញ្ជីនេះត្រូវកាន់កាប់ជាប្រចាំសម្រាប់ជូនអាជ្ញាធរតុលាការតាមត្រូវការ ។

**មាត្រា ១០២.** – កំណត់ហេតុសរុបនៃការឃាត់ខ្លួន

គ្រប់ការឃាត់ខ្លួនត្រូវតែមានធ្វើកំណត់ហេតុសរុបនៃការឃាត់ខ្លួន ។

កំណត់ហេតុសរុបនេះត្រូវមានចុះនិទ្ទេសដូចតទៅ :

-ឈ្មោះ និងឋានៈមន្ត្រីនគរបាលយុត្តិធម៌ដែលបង្គាប់ឱ្យឃាត់ខ្លួន

-អត្តសញ្ញាណរបស់បុគ្គលដែលត្រូវឃាត់ខ្លួន

-មូលហេតុនៃការឃាត់ខ្លួន

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងដែលផ្ដើមការឃាត់ខ្លួន

-បែបបទនៃការជូនដំណឹងដល់ព្រះរាជអាជ្ញា

-បែបបទនៃការជូនដំណឹងដោយអនុវត្តតាមមាត្រា ១០០ (អនីតិជនដែលត្រូវបានឃាត់ខ្លួន) នៃក្រមនេះ

## ផ្នែកទី ៥
## ការឃុំខ្លួនបណ្ដោះអាសន្ន

**មាត្រា ២០៣.** – គោលការណ៍នៃការឃុំខ្លួនបណ្ដោះអាសន្ន

ជាគោលការណ៍ ជនត្រូវចោទត្រូវតែមានសេរីភាព ។ ក្នុងករណីពិសេស ជនត្រូវចោទអាចត្រូវឃុំខ្លួនបណ្ដោះអាសន្ន នៅក្នុងលក្ខខណ្ឌដែលបានចែងនៅក្នុងផ្នែកនេះ ។

**មាត្រា ២០៤.** – ករណីនៃការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្ន អាចអនុវត្តបានតែក្នុងករណីចោទប្រកាន់ពីបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់កំណត់ផ្ដន្ទាទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ (មួយ) ឆ្នាំ ។

**មាត្រា ២០៥.** – មូលហេតុនៃការឃុំខ្លួនបណ្ដោះអាសន្ន

ការឃុំខ្លួនបណ្ដោះអាសន្នអាចត្រូវបានបង្គាប់ កាលណាការឃុំខ្លួនបណ្ដោះអាសន្ននេះជាការចាំបាច់ :

១-ដើម្បីបញ្ឈប់បទល្មើស ឬបង្ការបទល្មើសកុំឱ្យកើតជាថ្មី ។

២-ដើម្បីរារាំងកុំឱ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរារាំងកុំឱ្យមានការត្រូវរ៉ូវគ្នា រវាងជនត្រូវចោទ និងអ្នកសមគំនិត ។

៣-ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ ។

៤-ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធី ។

៥-ដើម្បីការពារសន្តិសុខឱ្យជនត្រូវចោទ ។

៦-ដើម្បីធានារក្សាសណ្ដាប់ធ្នាប់សាធារណៈកុំឱ្យមានការច្របូកច្របល់ ដែលបណ្ដាលមកពីបទល្មើស ។

**មាត្រា ២០៦.** – កំណត់សម្គាល់របស់ជនត្រូវចោទ និងការប្រាប់ហេតុផលនៃដីកា

ចៅក្រមស៊ើបសួរដែលសម្រេចថានឹងត្រូវឃុំខ្លួនបណ្ដោះអាសន្ន ដោយគំនិតផ្ដើមរបស់ខ្លួនផ្ទាល់ ឬ តាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ត្រូវឱ្យដំណឹងដល់ជនត្រូវចោទ និងទទួលការកត់សម្គាល់របស់ជនត្រូវចោទនេះ ។ កាលណាជនត្រូវចោទមានមេធាវីអមផងនោះ មេធាវីត្រូវបង្ហាញមធ្យោបាយការពារខ្លួន ។

ចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នតាមដីកាដោយមានសំអាងហេតុ ។ នៅក្នុងដីកានេះ ចៅក្រមស៊ើបសួរត្រូវយោងតាមបញ្ញត្តិនៃមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួន

បណ្ដោះអាសន្ន) នៃក្រមនេះ ។ ដីកាបង្គាប់ឱ្យឃុំខ្លួនបណ្ដោះអាសន្នត្រូវបានជូនដំណឹងភ្លាមដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ ។

ចៅក្រមស៊ើបសួរចេញដីកាបង្គាប់ឱ្យឃុំខ្លួន ដូចបានចែងនៅក្នុងមាត្រា ២២០ (និយមន័យដីកាបង្គាប់ឱ្យឃុំខ្លួន) មាត្រា ២២១ (និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឱ្យឃុំខ្លួន) និងមាត្រា ២២២ (ការអនុវត្តដីកាបង្គាប់ឱ្យឃុំខ្លួន) នៃក្រមនេះ ។

**មាត្រា ២០៧.** – ដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន

កាលណាចៅក្រមស៊ើបសួរដែលទទួលបណ្ដឹងតាមសេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ដែលសុំឱ្យឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្ននោះ មិនព្រមធ្វើតាមការសុំឱ្យឃុំខ្លួននោះទេ ចៅក្រមស៊ើបសួរត្រូវចេញក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ នូវដីកាសម្រេចមិនឃុំខ្លួនបណ្ដោះអាសន្ន ដោយមិនចាំបាច់មានសំអាងហេតុទេ ។ ដីកានេះត្រូវជូនដំណឹងជាបន្ទាន់ដល់អ្នកប្ដឹងសុំ ។

ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចនៅក្នុងរយៈពេល ៥ (ប្រាំ) ថ្ងៃ ព្រះរាជអាជ្ញាអាចធ្វើពាក្យប្ដឹងទៅសភាស៊ើបសួរ ដែលនឹងសម្រេចជំនួសចៅក្រមស៊ើបសួរ ។

**មាត្រា ២០៨.** – ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទឧក្រិដ្ឋ

ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋ ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ (ប្រាំមួយ) ខែ បានទេ ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ៦ (ប្រាំមួយ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

ចៅក្រមស៊ើបសួរអាចសម្រេចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានតែ ២ (ពីរ) ដងគត់ ។

**មាត្រា ២០៩.** – ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នក្នុងបទមជ្ឈិម

ចំពោះនីតិជនដែលត្រូវចោទប្រកាន់ពីបទមជ្ឈិម ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ (បួន) ខែ បានទេ ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរអាចពន្យារការឃុំខ្លួនបណ្ដោះអាសន្នបានតែម្ដងគត់ មិនឱ្យលើសពី ២ (ពីរ) ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ។

ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោសដែលច្បាប់បានកំណត់ឡើយ ។

**មាត្រា ២១០.** – ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងករណីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ជាអាទិ៍

# ក្រមរដ្ឋប្បវេណី

# ព្រះរាជក្រម

នស/រកម/១២០៧/០៣០

## យើង

**ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី**
**សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ**
**ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា**
**ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី**

- បានទ្រង់យល់ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ ព្រះរាជក្រមលេខ នស/រកម/០១៩៦/០៤ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងយុត្តិធម៌
- បានទ្រង់យល់ សេចក្តីក្រាបបង្គំទូលថ្វាយ របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និងរដ្ឋមន្ត្រីក្រសួងយុត្តិធម៌

## ប្រកាសឱ្យប្រើ

ក្រមរដ្ឋប្បវេណី ដែលរដ្ឋសភាបានអនុម័តកាលពីថ្ងៃទី០៥ ខែតុលា ឆ្នាំ២០០៧ នាសម័យប្រជុំរដ្ឋសភាលើកទី៧ នីតិកាលទី៣ និងដែលព្រឹទ្ធសភាបានយល់ស្រប តាមទម្រង់ និងគតិនៃក្រមនេះទាំងស្រុង ដោយគ្មានការកែប្រែអ្វីឡើយ កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០០៧ នាសម័យប្រជុំពេញអង្គព្រឹទ្ធសភាលើកទី ៤ នីតិកាលទី២ ហើយដែលមានសេចក្តីទាំងស្រុងដូចតទៅនេះ :

ROYAUME du CAMBODGE • LE MINISTRE du PALAIS ROYAL

**មាត្រា ២៧.–** ការលុបចោលការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៤ (ការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមអាណាព្យាបាលទូទៅ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

## កថាភាគទី ៣
## ជននៅក្រោមហិតូបត្ថម្ភ

**មាត្រា ២៨.–** ការប្រកាសការចាប់ផ្តើមហិតូបត្ថម្ភ

១-ចំពោះជនដែលមានសមត្ថភាពតិចតួចពេកក្នុងការយល់ដឹង និង វិនិច្ឆ័យអំពីលទ្ធផលតាមផ្លូវច្បាប់នៃសកម្មភាពរបស់ខ្លួន ដោយសារមានវិបត្តិផ្នែកបញ្ញាស្មារតី តុលាការអាចប្រកាសការចាប់ផ្តើមហិតូបត្ថម្ភលើជននោះបាន តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាល អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាល មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

២-ក្នុងករណីដែលធ្វើការប្រកាសដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើនេះ បើសាមីខ្លួនជាជននៅក្រោមអាណាព្យាបាលទូទៅ តុលាការត្រូវលុបចោលការប្រកាសការចាប់ផ្តើមអាណាព្យាបាលទូទៅចំពោះជននោះ ។

**មាត្រា ២៩.–** អត្ថន័យនៃជននៅក្រោមហិតូបត្ថម្ភ និង ការជ្រើសតាំងហិតូបត្ថម្ភកៈ

ជនដែលបានទទួលការប្រកាសចាប់ផ្តើមហិតូបត្ថម្ភ ត្រូវហៅថា ជននៅក្រោមហិតូបត្ថម្ភ ហើយត្រូវស្ថិតនៅក្រោមការថែរក្សាដោយហិតូបត្ថម្ភកៈ ។

**មាត្រា ៣០.–** សិទ្ធិលុបចោលសកម្មភាព

លើកលែងតែសកម្មភាពដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃ សកម្មភាពដែល

បានធ្វើឡើងដោយជននៅក្រោមហិត្ថបត្ថម្ភ ដោយគ្មានការយល់ព្រមពីហិត្ថបត្ថម្ភកៈដូចខាងក្រោមនេះ អាចលុបចោលបាន ៖

ក-ការទទួល ឬ ការប្រើប្រាស់ទុន ។

ខ-ការខ្ចីទ្រព្យ ឬ ការធានា ។

គ-ការធ្វើសកម្មភាពដែលមានគោលបំណងទទួលបាន ឬ ធ្វើឱ្យបាត់បង់សិទ្ធិដែលទាក់ទងនឹងអចលនវត្ថុ ឬ ទ្រព្យសម្បត្តិដែលមានសារៈសំខាន់ផ្សេងទៀត ។

ឃ-ការធ្វើសកម្មភាពបណ្តឹង ។

ង-ការធ្វើប្រទានកម្ម ឬ ធ្វើកិច្ចសន្យាស្រុះស្រួល ឬ កិច្ចសន្យាមជ្ឈត្តកម្ម ។

ច-ការទទួលស្គាល់នូវសន្តតិកម្ម ឬ ការបោះបង់ចោលនូវសិទ្ធិសន្តតិកម្ម ឬ ការបែងចែកនូវមត៌ក ។

ឆ-ការប្រកែកមិនទទួលប្រទានកម្មឬអច្ច័យទាន ឬ ការយល់ព្រមទទួលនូវប្រទានកម្មឬអច្ច័យទានដែលភ្ជាប់នឹងបន្ទុក ។

ជ-ការសាងសង់សំណង់ថ្មី ការសង់ឡើងវិញ ការសង់បន្ថែម ឬ ការជួសជុលធំ ។

ឈ-ការធ្វើភតិសន្យា ដែលមានអំឡុងពេលលើសពី ៣ (បី) ឆ្នាំ ចំពោះដីធ្លី លើសពី ២ (ពីរ) ឆ្នាំ ចំពោះអាគារ លើសពី ៦ (ប្រាំមួយ) ខែ ចំពោះចលនវត្ថុ ។

ញ-សកម្មភាពដែលតុលាការបានប្រកាសជាពិសេសថា ចាំបាច់ត្រូវមានការយល់ព្រមពីហិត្ថបត្ថម្ភកៈ តាមពាក្យសុំរបស់ជនដែលបានរៀបរាប់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្តើមហិត្ថបត្ថម្ភ) នៃក្រមនេះ ឬ ហិត្ថបត្ថម្ភកៈ ឬ អ្នកត្រួតពិនិត្យហិត្ថបត្ថម្ភកៈ ។

**មាត្រា ៣១.-** ការលុបចោលការប្រកាសចាប់ផ្តើមហិត្ថបត្ថម្ភ

បើមូលហេតុដែលបានកំណត់នៅក្នុងមាត្រា ២៨ (ការប្រកាសការចាប់ផ្តើមហិត្ថបត្ថម្ភ) នៃក្រមនេះ បានរលាយ តុលាការត្រូវលុបចោលនូវការប្រកាសចាប់ផ្តើមហិត្ថបត្ថម្ភ តាមពាក្យសុំរបស់សាមីខ្លួន សហព័ទ្ធ ញាតិដែលស្ថិតនៅក្នុង ៤ (បួន) ថ្នាក់ អ្នកអាណាព្យាបាលសម្រាប់អនីតិជន អ្នកត្រួតពិនិត្យអ្នកអាណាព្យាបាលសម្រាប់អនីតិជន

ហិតូបត្ថម្ភកៈ អ្នកត្រួតពិនិត្យហិតូបត្ថម្ភកៈ មេឃុំ ឬ ចៅសង្កាត់នៃលំនៅឋានរបស់ជននោះ ឬ តំណាងអយ្យការ ។

## កថាភាគទី ៤
## ការការពារភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព

**មាត្រា ៣២.–** សិទ្ធិដាស់តឿន

១-ភាគីម្ខាងទៀតនៃជនដែលត្រូវបានកម្រិតសមត្ថភាព អាចដាស់តឿនឱ្យជននោះ ឆ្លើយថាផ្តល់ ឬ មិនផ្តល់សច្ចានុមតិ លើសកម្មភាពដែលជននោះអាចលុបចោលបាន ក្នុងអំឡុងពេលលើសពី ១ (មួយ) ខែ ក្រោយពេលជននោះបានក្លាយជាសមត្ថជនវិញ ។ ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាពដែលបានក្លាយជាសមត្ថជនវិញនោះ មិន ឆ្លើយតបក្នុងអំឡុងពេលដែលបានកំណត់ទេ ត្រូវចាត់ទុកថា ជននោះផ្តល់សច្ចានុមតិលើ សកម្មភាពនោះ ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះ ត្រូវយកមកអនុវត្តផងដែរ ចំពោះករណី ដែលភាគីម្ខាងទៀតបានដាស់តឿន ដូចដែលបានកំណត់នៅក្នុងកថាខណ្ឌទី ១ ខាងលើ ទៅអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឬ ហិតូបត្ថម្ភកៈ អំពីសកម្មភាពដែល ស្ថិតនៅក្នុងទំហំនៃសិទ្ធិរបស់ខ្លួន នៅពេលដែលជនដែលត្រូវបានកម្រិតសមត្ថភាព មិន ទាន់ក្លាយជាសមត្ថជន តែអ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឬ ហិតូបត្ថម្ភកៈ មិនឆ្លើយតប ក្នុងអំឡុងពេលដែលបានកំណត់ទេ ។

៣-ភាគីម្ខាងទៀតអាចដាស់តឿនឱ្យជននៅក្រោមហិតូបត្ថម្ភទទួលយកសច្ចានុមតិ ពីហិតូបត្ថម្ភកៈ ក្នុងអំឡុងពេលដែលបានកំណត់ក្នុងកថាខណ្ឌទី ១ ខាងលើនេះ ។ ប្រសិន បើជននៅក្រោមហិតូបត្ថម្ភ មិនបានជូនដំណឹងថា ខ្លួនបានទទួលសច្ចានុមតិក្នុងអំឡុង ពេលនោះទេ ត្រូវចាត់ទុកថា ជននោះបានលុបចោលសកម្មភាពនោះ ។

**មាត្រា ៣៣.–** ការឆបោករបស់ជនដែលត្រូវបានកម្រិតសមត្ថភាព

ប្រសិនបើជនដែលត្រូវបានកម្រិតសមត្ថភាព បានប្រើប្រាស់មធ្យោបាយឆបោក

ដើម្បីឱ្យគេជឿជាក់ថា ខ្លួនជាសមត្ថជន ជននោះមិនអាចលុបចោលសកម្មភាពបានទេ ។

## ផ្នែកទី ៥
## លំនៅឋាន

**មាត្រា ៣៤.–** អត្ថន័យនៃលំនៅឋាន

កន្លែងដែលជាទីតាំងនៃជីវភាពរស់នៅរបស់បុគ្គលម្នាក់ៗ ត្រូវយកធ្វើជាលំនៅឋាន ។

**មាត្រា ៣៥.–** ទីសំណាក់

ក្នុងករណីដែលកន្លែងដែលជាទីតាំងនៃជីវភាពរស់នៅមិនច្បាស់លាស់ទេ ទីសំណាក់ត្រូវបានចាត់ទុកថាជាលំនៅឋាន ។

**មាត្រា ៣៦.–** ករណីដែលគ្មានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជា

ចំពោះបុគ្គលដែលគ្មានលំនៅឋាននៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ ទោះបីជាបុគ្គលនោះជាជនជាតិខ្មែរក៏ដោយ ជាជនជាតិបរទេសក៏ដោយ ទីសំណាក់របស់បុគ្គលនោះនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបានចាត់ទុកថាជាលំនៅឋាន ។ ប៉ុន្តែ បញ្ញត្តិនេះមិនត្រូវអនុវត្តឡើយ ចំពោះករណីដែលច្បាប់នៃលំនៅឋានត្រូវបានយកមកអនុវត្ត ។

## ផ្នែកទី ៦
## ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន និង ការប្រកាសអំពីការបាត់ខ្លួន

### កថាភាគទី ១
### ការគ្រប់គ្រងទ្រព្យសម្បត្តិរបស់បុគ្គលដែលអវត្តមាន

**មាត្រា ៣៧.–** ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ

ក្នុងករណីដែលបុគ្គលណាម្នាក់ដែលបានចេញពីលំនៅឋាន ឬ ទីសំណាក់ ហើយដែលគ្មានលទ្ធភាពនឹងត្រឡប់មកវិញដោយងាយស្រួលនោះ មិនបានចាត់តាំងអ្នកគ្រប់គ្រង

ទ្រព្យសម្បត្តិរបស់ខ្លួនទេ តុលាការអាចជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ឬ បង្គាប់ចាត់ចែងជាចាំបាច់ដើម្បីគ្រប់គ្រងទ្រព្យសម្បត្តិនោះបាន តាមពាក្យសុំរបស់បុគ្គលដែលមានទំនាក់ទំនងនឹងផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ ឬ តំណាងអយ្យការ ។ បញ្ញត្តិនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីដែលសិទ្ធិរបស់អ្នកគ្រប់គ្រងត្រូវបានរលត់ នៅក្នុងរយៈពេលដែលសាមីខ្លួនអវត្តមាន ។

**មាត្រា ៣៨.–** ការលុបចោលការបង្គាប់ឱ្យគ្រប់គ្រងទ្រព្យសម្បត្តិ

ក្នុងករណីដែលបានកំណត់នៅក្នុងមាត្រា ៣៧ (ការជ្រើសតាំងអ្នកគ្រប់គ្រងទ្រព្យសម្បត្តិដោយតុលាការ) នៃក្រមនេះ ប្រសិនបើក្រោយមក បុគ្គលដែលអវត្តមានបានចាត់តាំងអ្នកគ្រប់គ្រង តុលាការអាចលុបចោលនូវការបង្គាប់ តាមពាក្យសុំរបស់អ្នកគ្រប់គ្រង អ្នកដែលមានផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ ឬ តំណាងអយ្យការ ។

**មាត្រា ៣៩.–** ការផ្លាស់ប្តូរអ្នកគ្រប់គ្រង

ក្នុងករណីដែលបុគ្គលអវត្តមានបានចាត់តាំងអ្នកគ្រប់គ្រង ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននោះនៅរស់ ឬ ទទួលមរណភាពទេ តុលាការអាចផ្លាស់ប្តូរអ្នកគ្រប់គ្រងបាន តាមពាក្យសុំរបស់អ្នកដែលមានផលប្រយោជន៍ មេឃុំ ឬ ចៅសង្កាត់ដែលលំនៅឋានជននោះស្ថិតនៅ ឬ តំណាងអយ្យការ ។

**មាត្រា ៤០.–** សិទ្ធិរបស់អ្នកគ្រប់គ្រងទ្រព្យសម្បត្តិ ជាអាទិ៍

១-អ្នកគ្រប់គ្រងដែលបានជ្រើសតាំងមានសិទ្ធិធ្វើសកម្មភាពដែលបានកំណត់នៅក្នុងកថាខណ្ឌទី ២ មាត្រា ៣៦៦ (ទំហំនៃសិទ្ធិតំណាង) នៃក្រមនេះ ។ ប្រសិនបើចាំបាច់ត្រូវធ្វើសកម្មភាពផ្សេងទៀត អ្នកគ្រប់គ្រងនោះអាចធ្វើបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

២-ក្នុងករណីដែលពុំមានដំណឹងច្បាស់លាស់ថា បុគ្គលអវត្តមាននៅរស់ ឬ ទទួលមរណភាពទេ ហើយអ្នកគ្រប់គ្រងរបស់បុគ្គលអវត្តមាននោះចាំបាច់ត្រូវធ្វើសកម្មភាពដែល

ហួសសិទ្ធិដែលបុគ្គលអវត្តមានបានកំណត់ អ្នកគ្រប់គ្រងនោះអាចធ្វើបាន ដោយទទួលការអនុញ្ញាតពីតុលាការ ។

៣-បើយល់ឃើញថា សមរម្យក្នុងការផ្តល់កម្រៃដល់អ្នកគ្រប់គ្រង ដោយគិតពិចារណា នូវទំនាក់ទំនងរវាងអ្នកអវត្តមាន និង អ្នកគ្រប់គ្រង និង ស្ថានភាពផ្សេងទៀត តុលាការអាចផ្តល់កម្រៃចំនួនសមរម្យដល់អ្នកគ្រប់គ្រង ដោយយកពីទ្រព្យសម្បត្តិរបស់អ្នកអវត្តមានបាន ។

## កថាភាគទី ២

## ការប្រកាសអំពីការបាត់ខ្លួន

**មាត្រា ៤១.–** ល័ក្ខខ័ណ្ឌដើម្បីធ្វើការប្រកាសអំពីការបាត់ខ្លួន

១-ប្រសិនបើពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ៥ (ប្រាំ) ឆ្នាំ តុលាការអាចប្រកាសបានថា បុគ្គលនោះបានបាត់ខ្លួនតាមពាក្យសុំរបស់សហព័ទ្ធ អ្នកដែលត្រូវបានសន្មតថាជាសន្តតិជន អច្ច័យលាភី អ្នកទទួលប្រាក់ធានារ៉ាប់រង អ្នកមានសិទ្ធិអំណាចមេបា អ្នកអាណាព្យាបាល ឪពុកម្តាយ ឬ អ្នកផ្សេងទៀតដែលមានផលប្រយោជន៍សំខាន់តាមផ្លូវច្បាប់ក្នុងការប្រកាសអំពីការបាត់ខ្លួន ។

២-បញ្ញត្តិនៃកថាខណ្ឌទី ១ ខាងលើនេះត្រូវយកមកអនុវត្តផងដែរ ចំពោះករណីបុគ្គលដែលចូលទៅតំបន់ដែលមានសង្គ្រាម បុគ្គលដែលមានវត្តមាននៅក្នុងនាវាដែលបានលិច ឬ បុគ្គលដែលបានជួបប្រទះនឹងគ្រោះថ្នាក់ផ្សេងទៀតដែលអាចនាំឱ្យទទួលមរណភាព ហើយពុំមានដំណឹងច្បាស់លាស់ថា អ្នកអវត្តមាននៅរស់ ឬ ទទួលមរណភាពក្នុងអំឡុងពេល ១ (មួយ) ឆ្នាំ ក្រោយពីចប់សង្គ្រាម ក្រោយពីនាវាបានលិច ឬ ក្រោយពីគ្រោះថ្នាក់ផ្សេងទៀតនោះ បានកន្លងផុតទៅ ។

**មាត្រា ៤២.–** ការផ្សាយជាសាធារណៈ

ការប្រកាសអំពីការបាត់ខ្លួន ត្រូវធ្វើឡើង ដោយឆ្លងកាត់ទៅតាមនីតិវិធីនៃការផ្សាយជាសាធារណៈ ។

# ក្រមព្រហ្មទណ្ឌបារាំង

# *Code pénal*

droit.org
Institut Français d'Information Juridique

Dernière modification: 2024-07-27
Edition : 2024-08-28
1282 articles avec 2270 liens
515 références externes

Ce code ne contient que du droit positif français,
les articles et éléments abrogés ne sont pas inclus.
Il est recalculé au fur et à mesure des mises à jour.
Pensez à actualiser votre copie régulièrement à partir de codes.droit.org.

Ces codes ont pour objectif de démontrer l'utilité de l'ouverture des données publiques juridiques tant législatives que jurisprudentielles. Il s'y ajoute une promotion du mouvement Open Science Juridique avec une incitation au dépôt du texte intégral en accès ouvert des articles de doctrine venant du monde professionnel (Grande Bibliothèque du Droit) et universitaire (HAL-CNRS).

Traitements effectués à partir des données issues des APIs Legifrance et Judilibre. droit.org remercie les acteurs du Web qui autorisent des liens vers leur production : Dictionnaire du Droit Privé (réalisé par MM. Serge Braudo et Alexis Baumann), le Conseil constitutionnel, l'Assemblée Nationale, et le Sénat.

Avec l'aide de:



Habett

La Loi des Ours

# Chapitre II : Des causes d'irresponsabilité ou d'atténuation de la responsabilité

## 122-1 LOI n°2014-896 du 15 août 2014 - art. 17 - Conseil Constit. 2014-696 DC

Legif. Plan Jp.C.Cass. Jp.Appel Jp.Admin. Juricaf

N'est pas pénalement responsable la personne qui était atteinte, au moment des faits, d'un trouble psychique ou neuropsychique ayant aboli son discernement ou le contrôle de ses actes.
La personne qui était atteinte, au moment des faits, d'un trouble psychique ou neuropsychique ayant altéré son discernement ou entravé le contrôle de ses actes demeure punissable. Toutefois, la juridiction tient compte de cette circonstance lorsqu'elle détermine la peine et en fixe le régime. Si est encourue une peine privative de liberté, celle-ci est réduite du tiers ou, en cas de crime puni de la réclusion criminelle ou de la détention criminelle à perpétuité, est ramenée à trente ans. La juridiction peut toutefois, par une décision spécialement motivée en matière correctionnelle, décider de ne pas appliquer cette diminution de peine. Lorsque, après avis médical, la juridiction considère que la nature du trouble le justifie, elle s'assure que la peine prononcée permette que le condamné fasse l'objet de soins adaptés à son état.

**Récemment au Bulletin de la Cour de Cassation**

> Chambre criminelle, 14 Avril 2021, n°20-80.135, (B) *[ ECLI:FR:CCASS:2021:CR00404 ]*

## 122-1-1 LOI n°2022-52 du 24 janvier 2022 - art. 1 - Conseil Constit. 2021-834 DC

Legif. Plan Jp.C.Cass. Jp.Appel Jp.Admin. Juricaf

Le premier alinéa de l'article ***122-1*** n'est pas applicable si l'abolition temporaire du discernement de la personne ou du contrôle de ses actes au moment de la commission d'un crime ou d'un délit résulte de ce que, dans un temps très voisin de l'action, la personne a volontairement consommé des substances psychoactives dans le dessein de commettre l'infraction ou une infraction de même nature ou d'en faciliter la commission.

## 122-1-2 LOI n°2022-52 du 24 janvier 2022 - art. 1 - Conseil Constit. 2021-834 DC

Legif. Plan Jp.C.Cass. Jp.Appel Jp.Admin. Juricaf

La diminution de peine prévue au second alinéa de l'article ***122-1*** n'est pas applicable en cas d'altération temporaire du discernement de la personne ou du contrôle de ses actes au moment de la commission d'un crime ou d'un délit lorsque cette altération résulte d'une consommation volontaire, de façon illicite ou manifestement excessive, de substances psychoactives.

## 122-2 Loi n°92-683 du 22 juillet 1992 (V) - Conseil Constit. 2022-1023 QPC

Legif. Plan Jp.C.Cass. Jp.Appel Jp.Admin. Juricaf

N'est pas pénalement responsable la personne qui a agi sous l'empire d'une force ou d'une contrainte à laquelle elle n'a pu résister.

## 122-3 Loi n°92-683 du 22 juillet 1992 (V) - Conseil Constit. 2022-1023 QPC

Legif. Plan Jp.C.Cass. Jp.Appel Jp.Admin. Juricaf

N'est pas pénalement responsable la personne qui justifie avoir cru, par une erreur sur le droit qu'elle n'était pas en mesure d'éviter, pouvoir légitimement accomplir l'acte.

**Récemment au Bulletin de la Cour de Cassation**

> Chambre criminelle, 08 Novembre 2022, n°21-86.499, (B) *[ ECLI:FR:CCASS:2022:CR01353 ]*

## 122-4 Loi n°92-683 du 22 juillet 1992 (V) - Conseil Constit. 2022-1023 QPC

Legif. Plan Jp.C.Cass. Jp.Appel Jp.Admin. Juricaf

N'est pas pénalement responsable la personne qui accomplit un acte prescrit ou autorisé par des dispositions législatives ou réglementaires.
N'est pas pénalement responsable la personne qui accomplit un acte commandé par l'autorité légitime, sauf si cet acte est manifestement illégal.

**Récemment au Bulletin de la Cour de Cassation**

> Chambre criminelle, 08 Novembre 2022, n°21-86.499, (B) *[ ECLI:FR:CCASS:2022:CR01353 ]*

## 122-5 Loi n°92-683 du 22 juillet 1992 (V) - Conseil Constit. 2022-1023 QPC

Legif. Plan Jp.C.Cass. Jp.Appel Jp.Admin. Juricaf

N'est pas pénalement responsable la personne qui, devant une atteinte injustifiée envers elle-même ou autrui, accomplit, dans le même temps, un acte commandé par la nécessité de la légitime défense d'elle-même ou d'autrui, sauf s'il y a disproportion entre les moyens de défense employés et la gravité de l'atteinte.
N'est pas pénalement responsable la personne qui, pour interrompre l'exécution d'un crime ou d'un délit contre un bien, accomplit un acte de défense, autre qu'un homicide volontaire, lorsque cet acte est strictement nécessaire au but poursuivi dès lors que les moyens employés sont proportionnés à la gravité de l'infraction.

**Circulaires et Instructions**

> INSTRUCTION N° 18011/DEF/EMAT relative à la patrouille de la légion étrangère.

## 122-6 Loi n°92-683 du 22 juillet 1992 (V) - Conseil Constit. 2022-1023 QPC

Legif. Plan Jp.C.Cass. Jp.Appel Jp.Admin. Juricaf

Est présumé avoir agi en état de légitime défense celui qui accomplit l'acte :
1° Pour repousser, de nuit, l'entrée par effraction, violence ou ruse dans un lieu habité ;
2° Pour se défendre contre les auteurs de vols ou de pillages exécutés avec violence.

## 122-7 Loi n°92-683 du 22 juillet 1992 (V) - Conseil Constit. 2022-1023 QPC

Legif. Plan Jp.C.Cass. Jp.Appel Jp.Admin. Juricaf

N'est pas pénalement responsable la personne qui, face à un danger actuel ou imminent qui menace elle-même, autrui ou un bien, accomplit un acte nécessaire à la sauvegarde de la personne ou du bien, sauf s'il y a disproportion entre les moyens employés et la gravité de la menace.

**Récemment au Bulletin de la Cour de Cassation**

> Chambre criminelle, 22 Septembre 2021, n°20-80.489, (B) *[ ECLI:FR:CCASS:2021:CR00956 ]*

> Chambre criminelle, 15 Juin 2021, n°20-83.749, (B) *[ ECLI:FR:CCASS:2021:CR00743 ]*

## 122-8 Ordonnance n° 2019-950 du 11 septembre 2019 - art. 3

Legif. Plan Jp.C.Cass. Jp.Appel Jp.Admin. Juricaf

Les mineurs capables de discernement sont pénalement responsables des crimes, délits ou contraventions dont ils ont été reconnus coupables, en tenant compte de l'atténuation de responsabilité dont ils bénéficient en raison de leur âge, dans des conditions fixées par le code de la justice pénale des mineurs.

## 122-9 LOI n°2022-401 du 21 mars 2022 - art. 6

Legif. Plan Jp.C.Cass. Jp.Appel Jp.Admin. Juricaf

N'est pas pénalement responsable la personne qui porte atteinte à un secret protégé par la loi, dès lors que cette divulgation est nécessaire et proportionnée à la sauvegarde des intérêts en cause, qu'elle intervient dans le respect des conditions de signalement définies par la loi et que la personne répond aux critères de définition du lanceur d'alerte prévus à *l'article 6* de la loi n° 2016-1691 du 9 décembre 2016 relative à la transparence, à la lutte contre la corruption et à la modernisation de la vie économique.
N'est pas non plus pénalement responsable le lanceur d'alerte qui soustrait, détourne ou recèle les documents ou tout autre support contenant les informations dont il a eu connaissance de manière licite et qu'il signale ou divulgue dans les conditions mentionnées au premier alinéa du présent article.
Le présent article est également applicable au complice de ces infractions.

**Circulaires et Instructions**

> Circulaire du 26 juin 2024 relative à la procédure de signalement des alertes émises par les agents publics et aux garanties et protections qui leur sont accordées dans la fonction publique dans le cadre des articles 6 à 15 de la loi n° 2016-1691 du 9 décembre 2016 relative à la transparence, à la lutte contre la corruption et à la modernisation de la vie économique modifiée par la loi n° 2022-401 du 21 mars 2022 visant à améliorer la protection des lanceurs d'alerte